ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

(គ.ជ.អ.ប.)

# ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទីបី(ផអ៣ទី៣)
# ២០១៨-២០២០
# នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
# នៅថ្នាក់ក្រោមជាតិ

ខែតុលា ឆ្នាំ២០១៧

**អារម្ភកថា**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...........ខែ............ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប.**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា


អារម្ភកថា.................................................................................
មាតិកា .......................................................................................
បញ្ជីរូបភាព ..................................................................................
បញ្ជីតារាង ..................................................................................


## ជំពូកទី១

## និដ្ឋភាពទូទៅនៃកម្មវិធី


១. សេចក្តីផ្តើម................................................................ ០១
២. ចក្ខុវិស័យនៃផអ៣ទី៣..................................................០៣
៣. គោលបំណង និងគោលដៅនៃផអ៣ទី៣ ..............................០៣
៤. សមាសភាគ សមិទ្ធផល និងលទ្ធផលរំពឹងទុក ....................... ០៥
៥. គុណតម្លៃនៃផអ៣ទី៣.................................................. ០៨
៦. លក្ខណៈពិសេសនៃផអ៣ទី៣............................................ ១០
៧. បញ្ហាប្រឈម និងកាលានុវត្តភាពនៃផអ៣ទី៣ ........................ ១១
៨. កិច្ចដំណើរការរៀបចំតាក់តែងផអ៣ទី៣ ................................១២
៩. រចនាសម្ព័ន្ធនៃផអ៣ទី៣ .................................................. ១៤
១០.យុទ្ធសាស្រ្តគន្លឹះៗសម្រាប់ការគ្រប់គ្រងកម្មវិធី........................ ១៥
១១ ថវិកាប៉ាន់ស្មានរបស់ផអ៣ទី៣.........................................១៧


## ជំពូកទី២

## សមាសភាគនៃផអ៣ទី៣


សមាសភាគទី១ ៖ ការគ្រប់គ្រងការងារកំណែទម្រង់..............................២១
ក. សេចក្តីផ្តើម.............................................................២១
ខ. វឌ្ឍនភាព និងបញ្ហាប្រឈម ..............................................២១
គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក.........................................២២
ឃ. គម្រោងថវិកាប៉ាន់ស្មាន ....................................................៣៤
ង. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ ...............................៣៥
សមាសភាគទី២ ៖ អភិបាលកិច្ចល្អ............................................... ៣៧
ក. សេចក្តីផ្តើម............................................................. ៣៧

ខ. វឌ្ឍនភាព និងបញ្ហាប្រឈម ..... ៣៧
គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក ..... ៣៨
ឃ. គម្រោងថវិកាប៉ាន់ស្មាន ..... ៥២
ង. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ ..... ៥៣
សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ..... ៥៥
ក. សេចក្តីផ្តើម ..... ៥៥
ខ. វឌ្ឍនភាព និងបញ្ហាប្រឈម ..... ៥៥
គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក ..... ៥៧
ឃ. គម្រោងថវិកាប៉ាន់ស្មាន ..... ៦២
ង. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ ..... ៦២
សមាសភាគទី៤ ៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ..... ៦៤
ក. សេចក្តីផ្តើម ..... ៦៤
ខ. វឌ្ឍនភាព និងបញ្ហាប្រឈម ..... ៦៥
គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក ..... ៦៧
ឃ. គម្រោងថវិកាប៉ាន់ស្មាន ..... ៧៨
ង. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ ..... ៧៩
សមាសភាគទី៥ ៖ វិមជ្ឈការហិរញ្ញវត្ថុ ..... ៨១
ក. សេចក្តីផ្តើម ..... ៨១
ខ. វឌ្ឍនភាព និងបញ្ហាប្រឈម ..... ៨២
គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក ..... ៨៣
ឃ. គម្រោងថវិកាប៉ាន់ស្មាន ..... ៨៦
ង. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ ..... ៨៧

## ជំពូកទី៣

## ការគ្រប់គ្រងកម្មវិធី

ក. ការរៀបចំស្ថាប័នគ្រប់គ្រងកម្មវិធី ..... ៨៨
ខ. កិច្ចដំណើរការគ្រប់គ្រងកម្មវិធី. ..... ៨៩
គ. ការគ្រប់គ្រងហិរញ្ញវត្ថុ ..... ៩៤
ឃ. គម្រោងថវិកាកម្មវិធី ..... ៩៧

## ឧបសម្ព័ន្ធនានា


ឧបសម្ព័ន្ធទី១ ៖ សនិទានភាព និងមូលដ្ឋានសម្រាប់ការត្រួតពិនិត្យការអនុវត្តលទ្ធផល
រំពឹងទុកនីមួយៗនៃផអ៣ទី៣ ........................................................
ឧបសម្ព័ន្ធទី២ ៖ ក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ........................................
ឧបសម្ព័ន្ធទី៣ ៖ យុទ្ធសាស្ត្រស្តីពីការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមនៅក្នុងផអ៣ទី៣ .........
ឧបសម្ព័ន្ធទី៤ ៖ យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពនៅក្នុងផអ៣ទី៣..........................................
ឧបសម្ព័ន្ធទី៥ ៖ យុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងផអ៣ទី៣ .........
ឧបសម្ព័ន្ធទី៦ ៖ យុទ្ធសាស្ត្រស្តីពីនិរន្តរភាពហិរញ្ញវត្ថុសម្រាប់កម្មវិធី............................................
ឧបសម្ព័ន្ធទី៧ ៖ វាក្យសព្ទ និងនិយមន័យ.........................................................................


## បញ្ជីរូបភាព


រូបភាពទី១ ៖ ខ្សែចង្វាក់លទ្ធផលនៃផអ៣ទី៣.................................................................... ០៥
រូបភាពទី២ ៖ ប្រព័ន្ធរដ្ឋបាលមូលដ្ឋាន ............................................................................ ០៩


## បញ្ជីតារាង


តារាងទី១ ៖ សង្ខេបសមាសភាគ សមិទ្ធផល និងលទ្ធផលរំពឹងទុកនៃផអ៣ទី៣...................... ០៥
តារាងទី២ ៖ យុទ្ធសាស្ត្រគន្លឹះៗសម្រាប់គ្រប់គ្រងកម្មវិធី......................................... ១៥
តារាងទី៣ ៖ ថវិកាចំណាយប៉ាន់ស្មានសរុបសម្រាប់កម្មវិធី............................................ ១៨
តារាងទី៤ ៖ ការផ្ទេរធនធានមូលនិធិឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ................................ ១៩
តារាងទី៥ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់ជំនួយបច្ចេកទេស ....................................... ១៩
តារាងទី៦ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់សមាសភាគទី១ .........................................៣៤
តារាងទី៧ ៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគទី១ ........................៣៥
តារាងទី៨ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់សមាសភាគទី២ .........................................៥២
តារាងទី៩ ៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគទី២........................៥៣
តារាងទី១០ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់សមាសភាគទី៣..........................................៦២
តារាងទី១១ ៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគទី៣.........................៦៣
តារាងទី១២ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់សមាសភាគទី៤ ........................................៧៨
តារាងទី១៣ ៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគទី៤ .......................៧៩
តារាងទី១៤ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់សមាសភាគទី៥ ......................................... ៨៦
តារាងទី១៥ ៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគទី៥ .......................៨៧

តារាងទី១៦ ៖ បញ្ជីគម្រោងដែលអាចរៀបចំសម្រាប់អនុវត្តលទ្ធផលរំពឹងទុកនានា...................... ៩១
តារាងទី១៧ ៖ តារាងម៉ាទ្រិកស្ដីពីទំនាក់ទំនងនៃវិធីសាស្រ្តនានាក្នុងការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗ.......................................................................................... ៩២
តារាងទី១៨ ៖ ទិដ្ឋភាពទូទៅនៃថវិកាផអ៣ទី៣.................................................................. ៩៧
តារាងទី១៩ ៖ ចំណាយប៉ាន់ស្មានតាមលទ្ធផលរំពឹងទុកនីមួយៗ............................................ ៩៨
តារាងទី២០ ៖ ប្រភេទចំណាយ (មិនគិតបញ្ចូលគម្រោងដាច់ដោយឡែក និងថវិកាកម្ចី)............ ១០០
តារាងទី២១ ៖ ប្រភពនានានៃការផ្ដល់មូលនិធិគាំទ្រ ផអ៣ទី៣ ............................................ ១០០
តារាងទី២២ ៖ ការផ្ទេរធនធានមូលនិធិរបស់រាជរដ្ឋាភិបាល ................................................ ១០២

# ជំពូកទី១

# និន្នាការទូទៅនៃកម្មវិធី

# ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់អំពីគុណតម្លៃ និងតួនាទីដ៏មានសារៈសំខាន់របស់រដ្ឋបាលមូលដ្ឋានតាមបែបវិមជ្ឈការក្នុងការលើកកម្ពស់សិទ្ធិរបស់ប្រជាពលរដ្ឋ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយគុណភាព តម្លាភាព និងគណនេយ្យភាព ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។ រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាទីកន្លែងដែលប្រជាពលរដ្ឋធ្វើការប្រាស្រ័យទាក់ទងផ្ទាល់ដំបូងបំផុត និងមានតួនាទីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការសម្រុះសម្រួលដោះស្រាយវិវាទនានានៅមូលដ្ឋាន និងការសម្របសម្រួលឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការបំពេញការងាររបស់ខ្លួន។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានក្រុមប្រឹក្សាកើតឡើងពីការបោះឆ្នោតពិតជាមានលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

បច្ចុប្បន្ន ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាត្រូវបានបែងចែកជា៣ថ្នាក់ ពោលគឺរដ្ឋបាលថ្នាក់ឃុំ សង្កាត់ដែលមានក្រុមប្រឹក្សាកើតឡើងតាមរយៈការបោះឆ្នោតដោយផ្ទាល់ចាប់ពីឆ្នាំ២០០២មក (សរុបចំនួន១.៦៤៦ ដែលក្នុងនោះ រួមមាន ឃុំចំនួន១.៤០៩ និងសង្កាត់ចំនួន២៣៧) រដ្ឋបាលក្រុង ស្រុក ខណ្ឌ (សរុបចំនួន១៩៧ ដែលក្នុងនោះរួមមាន ក្រុងចំនួន ២៦ ស្រុកចំនួន១៥៩ និងខណ្ឌចំនួន១២) និងរដ្ឋបាលរាជធានី ខេត្ត (សរុបចំនួន២៥ ដែលក្នុងនោះរួមមាន រាជធានីចំនួន០១ និងខេត្តចំនួន២៤) ដែលមានក្រុមប្រឹក្សាកើតឡើងតាមរយៈការបោះឆ្នោតដោយអសកលចាប់ពីឆ្នាំ២០០៩ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ច្បាប់រៀបចំអង្គការ)។

ការធ្វើវិមជ្ឈការ គឺជាការផ្ទេរសិទ្ធិអំណាច ការធ្វើសេចក្តីសម្រេចចិត្ត មុខងារ ធនធាន និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានពីក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតនៅកៀកជិត និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ។ ក្នុងន័យនេះ ការធ្វើវិមជ្ឈការ គឺជាការធ្វើកំណែទម្រង់ទាំងផ្នែករដ្ឋបាល និងផ្នែកនយោបាយ ដើម្បីបង្កើតនូវប្រព័ន្ធគ្រប់គ្រងតាមបែបប្រជាធិបតេយ្យមួយ សំដៅលើកកម្ពស់ការចូលរួម និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋគ្រប់រូបតាមរយៈរដ្ឋបាលមូលដ្ឋាន។

នាពេលកន្លងមក តាមរយៈការអនុវត្តគោលនយោបាយវិសហមជ្ឈការ ពោលគឺការធ្វើប្រតិភូកម្មមុខងារ និងធនធានពីក្រសួង ស្ថាប័នទៅឱ្យមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ខ្លួននៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយដែលអាចឆ្លើយតបបានទៅនឹងការសម្រេចបាននូវគោលបំណងខាងលើនេះឡើយ។ ការអនុវត្តគោលនយោបាយនេះ ពុំបានលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ព្រមទាំងពុំបានលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្ត និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឡើយ។

ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលបាន និងកំពុងកែសម្រួលជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយទៅជាប្រព័ន្ធដែលមានលក្ខណៈវិមជ្ឈការកាន់តែប្រសើរឡើង។ អាស្រ័យហេតុនេះ ផអ៣ទី៣នឹងបន្តពង្រឹងនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិមួយដែលមានស្វ័យភាព និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ និងជាស្ថាប័នពុំមែនជាខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ហើយថ្នាក់រដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមិនចំណុះគ្នាទៅវិញទៅមក (លើកលែងទំនាក់ទំនងរវាងរដ្ឋបាលរាជធានី ខណ្ឌ សង្កាត់ និងរវាងរដ្ឋបាលក្រុង និងសង្កាត់) និងមានការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានតាមរយៈការអនុវត្តមុខងារនានាដែលបានផ្ទេរឱ្យ និងមុខងារជាអាណត្តិទូទៅសំដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ជាងនេះទៀត ផអ៣ទី៣នឹងបន្តពង្រឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការពោលគឺ ៖

- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពទាំងចំពោះប្រជាពលរដ្ឋ និងទាំងចំពោះរាជរដ្ឋាភិបាលក្នុងការអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋាននានា
- រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលបាននូវចំណូលពីប្រភពនៅមូលដ្ឋាន និងតាមរយៈការផ្ទេរថវិកាពីថ្នាក់ជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន រួមមានបុគ្គលិករបស់ក្រសួងដែលបានចាត់តាំងឱ្យទៅបម្រើការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកផ្តល់សេវាសាធារណៈតាមស្តង់ដាដែលកំណត់ដោយក្រសួងស្ថាប័នថ្នាក់ជាតិ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនៃផអ៣ទី៣ ក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការបង្កិតការធ្វើសេចក្តីសម្រេចចិត្តក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានឱ្យទៅកៀកជិតប្រជាពលរដ្ឋតាមរយៈអភិក្រមខាងលើនេះ អាចឆ្លងកាត់ដំណាក់កាលអន្តរកាលមួយចំនួន ដែលមានរួមទាំងការធ្វើប្រតិភូកម្មនូវសិទ្ធិអំណាចពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមបែបផែននៃការចុះកិច្ចសន្យាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ ក្រសួង ស្ថាប័ននានាអាចអនុវត្តកិច្ចការនេះក្នុងល្បឿនខុសៗគ្នា អាស្រ័យលើស្ថានភាពនៃការផ្ទេរមុខងារ និងធនធានរបស់ក្រសួង ស្ថាប័ននីមួយៗនោះ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ក្រសួង ស្ថាប័នទាំងនោះត្រូវតែប្រកាន់ខ្ជាប់នូវគុណតម្លៃ និងគោរពតាមគោលការណ៍នានានៃកំណែទម្រង់វិមជ្ឈការដែលបានកំណត់ក្នុងឯកសារនេះ។ នៅចុងបញ្ចប់នៃផអ៣ទី៣ រដ្ឋបាលរាជធានី ក្រុង ស្រុក និងឃុំនឹងក្លាយទៅជារដ្ឋបាលមូលដ្ឋាន ដែលមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តកាន់តែច្រើនឡើងក្នុងការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការគ្រប់គ្រងធនធាននានារបស់ខ្លួន។ ជាមួយគ្នានេះដែរ នៅពេលដែលសមត្ថភាពរបស់រដ្ឋបាលទាំងនេះត្រូវបានលើកកម្ពស់ ការដាក់ចេញនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាពីថ្នាក់ជាតិក៏

នឹងត្រូវបានកាត់បន្ថយ។ ក្នុងន័យនេះ ការធ្វើឱ្យមានតុល្យភាពរវាងស្វ័យភាពមូលដ្ឋាន និងការចេញលិខិតបទដ្ឋានណែនាំពីថ្នាក់ជាតិ គឺកិច្ចការដ៏សំខាន់នៃកំណែទម្រង់វិមជ្ឈការនាពេលអនាគត។

ដើម្បីអនុវត្តច្បាប់រៀបចំអង្គការ រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ (២០១០-២០១៩)។ កម្មវិធីជាតិនេះត្រូវបានចាប់ផ្តើមអនុវត្តជាក់ស្តែងពីឆ្នាំ២០១១ និងបានពន្យារពេលអនុវត្ត១ឆ្នាំរហូតដល់ឆ្នាំ២០២០។ កម្មវិធីជាតិត្រូវបានបែងចែកជា៣ដំណាក់កាលអនុវត្តដូចខាងក្រោម ៖

| ដំណាក់កាល | គោលដៅ |
|---|---|
| **ដំណាក់កាលទី១** (២០១១-២០១៤) | បង្កើតរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដើម្បីធានាដល់ការអនុវត្តគោលនយោបាយ ព្រមទាំងធានាដល់ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| **ដំណាក់កាលទី២** (២០១៥-២០១៧) | ពង្រឹង និងពង្រីករចនាសម្ព័ន្ធ និងប្រព័ន្ធដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពដាក់ចេញ និងអនុវត្តគោលនយោបាយសម្រាប់មូលដ្ឋានរបស់ខ្លួន សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ព្រមទាំងបង្កើនលទ្ធភាពដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងក្រុមជនងាយរងគ្រោះក្នុងការទទួលបាននូវសេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ |
| **ដំណាក់កាលទី៣** (២០១៨-២០២០) | លើកកម្ពស់គុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននៅរដ្ឋបាលរាជធានី ក្រុង ស្រុក និងឃុំ (រដ្ឋបាលមូលដ្ឋាន) តាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ មុខងារដែលបានផ្ទេរទៅឱ្យ និងការផ្តួចផ្តើមគំនិតក្នុងការផ្តល់សេវាសាធារណៈចាំបាច់នានាផ្សេងទៀត។ |

## ២. ចក្ខុវិស័យនៃផអ៣ទី៣

ចក្ខុវិស័យនៃផអ៣ទី៣គឺ **"រដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវាសាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានបានកាន់តែល្អប្រសើរ សំដៅរួមចំណែកលើកកម្ពស់សុខុមាលភាព និងគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន"**។

## ៣. គោលបំណង និងគោលដៅរបស់ផអ៣ទី៣

**គោលបំណងនៃផអ៣ទី៣គឺ "រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានស្វ័យភាព និងគណនេយ្យភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន"។**

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ផអ៣ទី៣មានគោលដៅដូចខាងក្រោម ៖

- ពង្រឹងការគ្រប់គ្រងការងារកំណែទម្រង់របស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- **ពង្រឹងអភិបាលកិច្ចល្អរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**
- **លើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធនមនុស្ស**
- **ជំរុញការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្តួចផ្តើមគំនិតប្រកបដោយភាពច្នៃប្រឌិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅ មុខងារដែលបានផ្ទេរ និងមុខងារដទៃទៀត**
- **បង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**
- **ពង្រឹងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។**

ខ្សែចង្វាក់លទ្ធផលនៃផអ៣ទី៣បង្ហាញអំពីលទ្ធផលដែលមានការផ្លាស់ប្តូរជាដំណាក់ៗ រហូតដល់ទីបញ្ចប់នៃផអ៣ទី៣។ ផអ៣ទី៣នឹងដាក់ចេញលិខិតបទដ្ឋានគតិយុត្ត និងកែលម្អប្រព័ន្ធ ព្រមទាំងផ្តល់ការអភិវឌ្ឍសមត្ថភាព និងធនធាននានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ នៅពេលសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង នោះការគ្រប់គ្រង អភិបាលកិច្ច និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះត្រូវបានលើកកម្ពស់ ហើយប្រការនេះនឹងនាំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពផ្តល់សេវាសាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានបានកាន់តែមានភាពល្អប្រសើរឡើង។ ជាលទ្ធផលចុងក្រោយ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានត្រូវបានកែលម្អ នាំឱ្យប្រជាពលរដ្ឋមានជីវភាពធូរធារ កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន សមធម៌សង្គម និងមានចីរភាព។ ដើម្បីសម្រេចបាននូវខ្សែចង្វាក់នៃលទ្ធផលខាងលើ តម្រូវឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ និងការពង្រឹងភាពជាដៃគូជាមួយសង្គមស៊ីវិល និងវិស័យឯកជននានា។

ជារួម លទ្ធផលនៃផអ៣ទី៣ ចែកចេញជា៤ប្រភេទគឺ ៖

១. **លទ្ធផលសម្រាប់ការអនុវត្តកម្មវិធីថ្នាក់ជាតិ** ៖ រួមមានសកម្មភាពនានាដែលអនុវត្តដោយថ្នាក់ជាតិក្នុងការលើកកម្ពស់កិច្ចអភិវឌ្ឍមូលដ្ឋាន និងវិមជ្ឈការ។ នេះគឺជាលទ្ធផលក្នុងកម្រិតលទ្ធផលរំពឹងទុកនៃកម្មវិធីផអ៣ទី៣។

២. **លទ្ធផលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ** ៖ រួមមាន អភិបាលកិច្ច ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ នេះគឺជាលទ្ធផលក្នុងកម្រិតសមិទ្ធផលរំពឹងទុកនៃកម្មវិធីផអ៣ទី៣។

៣. **លទ្ធផលសម្រាប់ប្រជាពលរដ្ឋ** ៖ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការសាធារណៈ និងកិច្ចការនយោបាយ និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ។ នេះគឺជាលទ្ធផលនៃការជះឥទ្ធិពល ឬផលប៉ះពាល់នៅមូលដ្ឋានរបស់កម្មវិធីផអ៣ទី៣។

៤. **លទ្ធផលសម្រាប់ដៃគូពាក់ព័ន្ធផ្សេងៗ** ៖ រួមមានការចូលរួមរបស់សង្គមស៊ីវិល និងវិស័យឯកជនក្នុងការលើកកម្ពស់អភិបាលកិច្ច ការកៀរគរធនធាន ការបំពេញការងាររបស់រដ្ឋបាល

ថ្នាក់ក្រោមជាតិ ព្រមទាំងការរួមគ្នាក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងភាពជាដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ នេះគឺជាលទ្ធផលក្នុងកម្រិតសមិទ្ធផលរំពឹងទុកនៃកម្មវិធីផអ៣ទី៣។

**រូបភាពទី១ ៖ ខ្សែចង្វាក់លទ្ធផលនៃផអ៣ទី៣**




## ៤. សមាសភាគ សមិទ្ធផល និងលទ្ធផលរំពឹងទុកនៃផអ៣ទី៣

ផអ៣ទី៣រួមមានសមាសភាគចំនួន៥ សមិទ្ធផលរំពឹងទុកចំនួន១៦ និងលទ្ធផលរំពឹងទុកចំនួន៤៤ ដែលមានបរិយាយដោយសង្ខេបក្នុងតារាងខាងក្រោម ៖

**តារាងទី១៖ សង្ខេបសមាសភាគ សមិទ្ធផល និងលទ្ធផលរណពឹងទុកនៃផអ៣ទី៣**

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក |
|---|---|
| **សមាសភាគទី១÷ ការគ្រប់គ្រងការងារកំណែទម្រង់** | |
| ១.១. ការលើកកម្ពស់និរន្តរភាព និងស្ថាប័នភាវូបនីយកម្មនៃការងារកំណែទម្រង់នានាត្រូវបានធានា | ១.១.១. រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ លេខាធិការដ្ឋានគ.ជ.អ.ប រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រសួង ស្ថាប័នដែលបានផ្ទេរមុខងារត្រូវបានពិនិត្យ និងកែសម្រួល ដើម្បីធានាដល់ការគាំទ្រ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ<br>១.១.២. កម្មវិធីជាតិដំណាក់កាលបន្ទាប់ត្រូវបានរៀបចំកាត់តែង និងអនុម័ត<br>១.១.៣. យុទ្ធសាស្ត្រស្តីពីនិរន្តរភាពផ្នែកហិរញ្ញវត្ថុនៃកម្មវិធីត្រូវបានអនុវត្ត |

| **សមិទ្ធផលរំពឹងទុក** | **លទ្ធផលរំពឹងទុក** |
|---|---|
| ១.២ . ភាពជាម្ចាស់ និងការគាំទ្រដល់កំណែទម្រង់ត្រូវបានពង្រឹងយ៉ាងទូលំទូលាយ | ១.២.១. បរិយាកាសសមស្របត្រូវបានបង្កើតឡើងសម្រាប់ការពិភាក្សាផ្ទៃក្នុងរាជរដ្ឋាភិបាលឱ្យកាន់តែស៊ីជម្រៅអំពីកំណែទម្រង់វិមជ្ឈការ<br>១.២.២.យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានត្រូវបានអនុវត្តដោយផ្តោតជាសំខាន់លើការផ្លាស់ប្តូរឥរិយាបថ និងការបង្កើនការយល់ដឹងអំពីកំណែទម្រង់<br>១.២.៣.កម្មវិធីសាកល្បងយន្តការនានានៃកំណែទម្រង់វិមជ្ឈការ និងកម្មវិធីសិក្សារៀនសូត្រពីមេរៀនបទពិសោធន៍ល្អៗរបស់រដ្ឋបាលថ្នាក់ក្រោម ជាតិត្រូវបានអនុវត្ត ដើម្បីបង្ហាញឱ្យឃើញពីលទ្ធផល និងដើម្បីជាមូលដ្ឋានក្នុងការរៀបចំកែលម្អគោលនយោបាយ និងសេចក្តីសម្រេចនានា<br>១.២.៤. តួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់យោបល់ត្រឡប់ត្រូវបានពង្រឹង |
| ១.៣. សង្គមស៊ីវិល និងផ្នែកឯកជនក្លាយជាដៃគូជាមួយរដ្ឋាភិបាលក្នុងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ១.៣.១. បែបផែននៃកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូត្រូវបានរៀបចំ និងអនុវត្ត |
| ១.៤. ផអ៣ទី៣ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព | ១.៤.១. កិច្ចដំណើរការគ្រប់គ្រងគម្រោង និងកិច្ចការដទៃទៀតៗ ព្រមទាំងការលើកកម្ពស់ការរៀបចំផែនការ ការត្រួតពិនិត្យនិងវាយតម្លៃ និងការគ្រប់គ្រងផ្អែកលើលទ្ធផលត្រូវបានអនុវត្ត<br>១.៤.២.គម្រោងនានារបស់ដៃគូអភិវឌ្ឍន៍ត្រូវធ្វើសុខដុមនីយកម្ម និងកម្មវិធីកំណែទម្រង់នានារបស់រដ្ឋត្រូវបានធ្វើឱ្យមានសង្គតិភាពគ្នា ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការនានា<br>១.៤.៣.ការចាត់ចែងផ្នែកហិរញ្ញវត្ថុនិងការគាំទ្រផ្នែករដ្ឋបាលត្រូវបានផ្តល់ជាប្រចាំដល់ស្ថាប័ន អនុវត្ត ផអ៣ទី៣នានា |
| **សមាសភាគទី២៖ អភិបាលកិច្ចល្អ** | |
| ២.១.រដ្ឋបាលថ្នាក់ក្រោមជាតិមានការប្រាស្រ័យទាក់ ទង និងឆ្លើយតបចំពោះប្រជាពលរដ្ឋកាន់តែល្អប្រសើរ | ២.១.១. ការងារគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងពង្រីក<br>២.១.២. យន្តការទទួលនិងសម្រុះសម្រួលដោះស្រាយមតិយោបល់ និងបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកែសម្រួល និងអនុវត្ត ដើម្បីបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ |
| ២.២.ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិជាតំណាងប្រជាពលរដ្ឋ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងគោលនយោបាយនានា | ២.២.១. កម្មវិធីនានាត្រូវបានរៀបចំ និងអនុវត្តដើម្បីពង្រឹងតួនាទីរបស់ក្រុមប្រឹក្សារបស់រដ្ឋបាលក្រុង ស្រុក និងពង្រឹងទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ |
| ២.៣.រដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាព និងអនុវត្តបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្ត និងស្តង់ដានានារបស់ថ្នាក់ជាតិ ដោយផ្សារភ្ជាប់នឹងការវិភាជធនធាន និងការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើលទ្ធផលការងារ | ២.៣.១. អធិការកិច្ច ដែលមានលក្ខណៈជាប្រព័ន្ធទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តលិខិតបទដ្ឋានរបស់ក្រសួង ស្ថាប័នត្រូវបានរៀបចំ និងអនុវត្ត<br>២.៣.២. ការវាយតម្លៃប្រចាំឆ្នាំលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ធៀបទៅនឹងស្តង់ដា ត្រូវបានអនុវត្ត និងផ្សារភ្ជាប់ជាមួយការលើកទឹកចិត្ត |
| ២.៤. រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រងការងាររបស់ខ្លួនបានល្អប្រសើរ និងមានប្រសិទ្ធភាព | ២.៤.១. ការពិនិត្យមើលប្រចាំឆ្នាំរួមគ្នាទៅលើប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបាន អនុវត្ត<br>២.៤.២. ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ និងប្រព័ន្ធព័ត៌សម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោម ជាតិត្រូវបានរៀបចំ និងអនុវត្ត |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក |
|---|---|
| | ២.៤.៣. ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអភិវឌ្ឍបន្ថែម<br>២.៤.៤. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួលបន្ថែម និងអនុវត្ត |
| ២.៥. រដ្ឋបាលថ្នាក់ក្រោមជាតិដោះស្រាយ និងលើកកម្ពស់សុខុមាលភាពរបស់ក្រុមជនងាយរងគ្រោះនានា | ២.៥.១. កម្មវិធីនានាត្រូវបានអនុវត្តដើម្បីលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈភាពជាអ្នកដឹកនាំដ៏ល្អរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>២.៥.២. បរិយាប័ន្ន និងសមធម៌សង្គមត្រូវបានបញ្ជ្រាបទៅក្នុងកិច្ចប្រតិបត្តិការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>២.៥.៣. តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសុវត្ថិភាពសង្គមត្រូវបានគាំទ្រ<br>២.៥.៤. ការអភិវឌ្ឍសមត្ថភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងបរិយាប័ន្ន និងសមធម៌សង្គមត្រូវបានគាំទ្រ |
| **សមាសភាគទី៣៖ការគ្រប់គ្រង និងការអភិវឌ្ឍធនធាន មនុស្ស** | |
| ៣.១. រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិអំណាច និងស្វ័យភាពក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន | ៣.១.១. ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សបែបវិមជ្ឈការត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការតែងតាំង ការផ្ទេរ ការដាក់ពិន័យនិងកិច្ចការដទៃទៀតនៃការងារគ្រប់គ្រងបុគ្គលិករបស់ខ្លួន |
| ៣.២. បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនគ្រប់គ្រាន់ មានចំណេះដឹង និងមានសមត្ថភាពសមស្របក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួន | ៣.២.១. អភិក្រមនៃការអភិវឌ្ឍសមត្ថភាពត្រូវបានកែលម្អដោយរួមបញ្ចូលទាំងវិធីសាស្ត្រ ការធានាគុណភាព និងគណនេយ្យភាពរវាងអ្នកផ្តល់ និងអ្នកទទួលសេវាអភិវឌ្ឍសមត្ថភាព<br>៣.២.២. កម្មវិធីអភិវឌ្ឍន៍សមត្ថភាពត្រូវបានអនុវត្ត<br>៣.២.៣. ស្ថាប័នទទួលខុសត្រូវលើការអភិវឌ្ឍសមត្ថភាពត្រូវបានរៀបចំ រួមបញ្ចូលទាំងការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន |
| **សមាសភាគទី៤ ៖ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន** | |
| ៤.១. រដ្ឋបាលថ្នាក់ក្រោមជាតិមានការផ្តួចផ្តើមគំនិតដោះស្រាយបញ្ហាជាអាទិភាពនានារបស់មូលដ្ឋាន និងផ្តល់សេវានានា តាមរយៈមុខងារជាអាណត្តិទូទៅរបស់ខ្លួន | ៤.១.១. លិខិតបទដ្ឋាននានាសម្រាប់គាំទ្រដល់ការអនុវត្តមុខងារជាអាណត្តិទូទៅ និងការផ្តល់ សេវារួមគ្នានៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ<br>៤.១.២. សេចក្តីណែនាំស្តីពីបទពិសោធន៍ល្អផ្អែកលើភស្តុតាងជាក់លាក់ក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅត្រូវបានរៀបចំ និងផ្សព្វផ្សាយ<br>៤.១.៣. ការផ្តល់មូលនិធិគាំទ្រដល់ការអនុវត្តមុខងារជាអាណត្តិទូទៅត្រូវបានអនុវត្តសាកល្បង រួមបញ្ចូលទាំងធនធានសម្រាប់ការផ្តល់សេវារួមគ្នាដែលជាគំនិតផ្តួចផ្តើមរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន<br>៤.១.៤. រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ត្រូវបានគាំទ្រ ដើម្បីលើកកម្ពស់ការអនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន<br>៤.១.៥. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ សេវាសង្គម និងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានត្រូវបានអនុវត្ត និងដាក់បញ្ចូលទៅក្នុងប្រព័ន្ធរបស់រដ្ឋ |
| ៤.២. ប្រសិទ្ធភាពនៃការផ្តល់សេវាត្រូវបានបង្កើន តាមរយៈការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ៤.២.១. លិខិតបទដ្ឋានគតិយុត្ត និងឧបករណ៍នានាសម្រាប់ការផ្ទេរ និងការអនុវត្តមុខងារនានាត្រូវបានរៀបចំបញ្ចប់<br>៤.២.២. ផែនការសកម្មភាព និងថវិកាត្រូវបានរៀបចំ និងអនុម័តសម្រាប់ការ |

| សមិទ្ធផលរំពឹងទុក | លទ្ធផលរំពឹងទុក |
|---|---|
| | អនុវត្តអនុក្រឹត្យ ឬប្រកាស និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការផ្ទេរមុខងារ<br>៤.២.៣. មុខងារដែលបានផ្ទេរត្រូវបានអនុវត្តតាមវិធីសាស្ត្រនៃការគ្រប់គ្រងតាមបែបផែនជាគម្រោង<br>៤.២.៤.យន្តការច្រកចេញចូលតែមួយត្រូវបានពង្រីកទាំងតំបន់គោលដៅ និងប្រភេទសេវា |
| ៤.៣. ក្រសួង ស្ថាប័ននានារៀបចំ និងអនុវត្តគោលនយោបាយ លិខិតបទដ្ឋាន និងស្តង់ដានានាស្របតាមគោលនយោបាយវិមជ្ឈការ | ៤.៣.១. យុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងស្តង់ដានានារបស់ក្រសួង ស្ថាប័នត្រូវបានពិនិត្យមើល និងកែសម្រួលឡើងវិញស្របតាមគោលនយោបាយនៃវិមជ្ឈការ |
| ៤.៤. ខេត្តផ្តល់អន្តរាគមន៍ដល់ក្រុង ស្រុក និងឃុំ សង្កាត់ ដោយឡែកក្រុង ស្រុកផ្តល់ការគាំទ្រផ្នែករដ្ឋបាលដល់ឃុំ សង្កាត់ | ៤.៤.១. រចនាសម្ព័ន្ធ និងតួនាទីរបស់ខេត្តត្រូវបានកែសម្រួល និងពង្រឹងដើម្បីផ្តល់អន្តរាគមន៍ និងត្រួតពិនិត្យការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន<br>៤.៤.២. រដ្ឋបាលក្រុង ស្រុកត្រូវបានពង្រឹងដើម្បីផ្តល់អន្តរាគមន៍ និងគាំទ្រផ្នែករដ្ឋបាលដល់ឃុំ សង្កាត់ |
| **សមាសភាគទី៥៖ វិមជ្ឈការហិរញ្ញវត្ថុ** | |
| ៥.១. ការផ្តល់ធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកទៅលើលទ្ធផលនៃការបំពេញការងារ ក្នុងបែបផែនជាធន្ទានុសិទ្ធផ្តោតទៅលើការអភិវឌ្ឍ និងមានចំនួនសមស្រប ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងស្តង់ដារនៃការផ្តល់សេវា | ៥.១.១. មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ត្រូវបានវិភាជដោយផ្តោតលើការចំណាយផ្នែកអភិវឌ្ឍ<br>៥.១.២. បែបផែនចំណូលចែករំលែក (ពន្ធ និងមិនមែនពន្ធ) ត្រូវបានពិនិត្យ និងកែសម្រួល ដើម្បីបង្កើនការផ្តល់ធនធានក្រុង ស្រុក និងឃុំ សង្កាត់<br>៥.១.៣. មូលនិធិមានភ្ជាប់លក្ខខណ្ឌត្រូវបានដាក់ឱ្យដំណើរការ ដើម្បីអនុវត្តមុខងារដែលបានផ្ទេរ<br>៥.១.៤. មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដាក់ឱ្យដំណើរការដើម្បីគាំទ្រគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

# ៥. គុណតម្លៃនៃផអ៣ទី៣

ក្នុងការអនុវត្តផអ៣ទី៣ ចាំបាច់ត្រូវប្រកាន់ខ្ជាប់នូវគុណតម្លៃស្នូលចំនួន៤នៃកំណែទម្រង់វិមជ្ឈការដូចខាងក្រោម ៖

- **ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ៖ ផអ៣ទី៣ប្រកាន់ខ្ជាប់នូវគោលការណ៍នានានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានចែងនៅក្នុងច្បាប់រៀបចំអង្គការរួមមាន៖
  - ភាពជាតំណាងសាធារណៈ
  - ស្វ័យភាពមូលដ្ឋាន
  - ការពិគ្រោះយោបល់ និងការចូលរួម
  - ការឆ្លើយតប និងគណនេយ្យភាព
  - ការលើកស្ទួយគុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

- ➢ ការលើកស្ទួយសមធម៌
- ➢ តម្លាភាព និងសុចរិតភាព
- ➢ វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

- **ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ៖ ផអ៣ទី៣ផ្តល់នូវសិទ្ធិអំណាច និងឆន្ទានុសិទ្ធិច្បាស់លាស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីមានលទ្ធភាពក្នុងការផ្តួចផ្តើមគំនិតដោះស្រាយបញ្ហានានាដែលជាតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- **ធនធានសមស្រប** ៖ ផអ៣ទី៣នឹងធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានសមស្របសម្រាប់អនុវត្តមុខងារនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- **ភាពជាដៃគូ** ៖ ផអ៣ទី៣ អនុវត្តដោយសហការក្នុងភាពជាដៃគូជាមួយសង្គមស៊ីវិល និងវិស័យឯកជននានា។ រាជរដ្ឋាភិបាលចាត់ទុក សង្គមស៊ីវិល និងវិស័យឯកជនជាដៃគូដ៏សំខាន់ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ។

ក្នុងបរិបទនៃផអ៣ទី៣ រដ្ឋបាលថ្នាក់ក្រោមជាតិតាមលំដាប់ថ្នាក់រដ្ឋបាលនីមួយៗនឹងប្រតិបត្តិការការងាររបស់ខ្លួនដោយមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក។ ក្នុងន័យនេះ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់បង្កើតបានជាប្រព័ន្ធរដ្ឋបាលចំនួន៣ ប្រភេទផ្សេងគ្នា (***ប្រព័ន្ធរដ្ឋបាលដែនដី*** ) គឺ **ទីក្រុង** **ទីប្រជុំជន** និង**ជនបទ**។ ក្នុងប្រព័ន្ធទាំង៣នេះ តួនាទីរបស់រដ្ឋបាលខេត្តដែលធ្លាប់បានចាត់ទុកជារដ្ឋបាលមូលដ្ឋាន ក៏ដូចជាតួនាទីរបស់ឃុំ សង្កាត់ដែលស្ថិតនៅក្នុងដែនដីរដ្ឋបាលក្រុង និងស្រុកចាំបាច់ត្រូវធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ។ អាស្រ័យហេតុនេះ ចក្ខុវិស័យនៃប្រព័ន្ធរដ្ឋបាលមូលដ្ឋាននាពេលអនាគតមានទិដ្ឋភាពដូចរូបភាពខាងក្រោម ៖

***រូបភាពទី២៖ ប្រព័ន្ធរដ្ឋបាលមូលដ្ឋាន***




ប្រព័ន្ធរដ្ឋបាលមូលដ្ឋាននេះ គឺជាទិដ្ឋភាពរួមនៃការងារកំណែទម្រង់ដែលគ្រប់ភាគីទាំងអស់ត្រូវចងចាំ និងយល់ដឹងទាំងអស់គ្នា។ ដូចគ្នានេះដែរ ស្ថាប័នអនុវត្តទាំងអស់ត្រូវយល់ដឹង និងមានលទ្ធភាពក្នុងការបកស្រាយអំពីទស្សនទាននៃវិមជ្ឈការ និងកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កិច្ចដំណើរការអនុវត្ត និងផលប្រយោជន៍នៃកំណែទម្រង់នេះចំពោះប្រជាពលរដ្ឋ។

ដើម្បីសម្រេចនូវកិច្ចការខាងលើនេះ ចាំបាច់ត្រូវពង្រឹងការអនុវត្តយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងនិងការផ្សព្វផ្សាយព័ត៌មាន រួមជាមួយនឹងការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពជាប្រចាំនូវគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រោះឯកសារទាំងនេះមានសារសំខាន់សម្រាប់ (១) ការពន្លឿនការផ្ទេរមុខងារ (២) ការគូសបញ្ជាក់ពីតួនាទី និងការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត និងក្រុង ស្រុក ខណ្ឌ ឱ្យបានសមស្របជាមួយនឹងការទទួលខុសត្រូវក្នុងការផ្តល់សេវា (៣) ការពង្រឹងសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅ (៤) ការផ្តល់ធនធានសមស្របឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និង (៥) ការរៀបចំលិខិតបទដ្ឋាននានារួមបញ្ចូលទាំងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដែលលក្ខណៈសមស្របជាមួយនឹងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៦. លក្ខណៈពិសេសនៃផអ៣ទី៣

ផអ៣ទី៣ គឺជាផែនការអនុវត្តរយៈពេល៣ឆ្នាំដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ផែនការនេះផ្តោតជាសំខាន់លើការគាំទ្រដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស៖

*ការផ្តួចផ្តើមគំនិតរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក និងឃុំ ដែលជារដ្ឋបាលមូលដ្ឋានក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ មុខងារដែលបានផ្ទេរ និងមុខងារចាំបាច់នានាផ្សេងទៀត។*

ផអ៣ទី៣ចាំបាច់ត្រូវផ្តោតលើការបង្កើតសមិទ្ធផលជាក់ស្តែង ដែលផ្តល់ផលប្រយោជន៍យ៉ាងពិតប្រាកដជូនប្រជាពលរដ្ឋ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ចាំបាច់ត្រូវពិនិត្យមើលឡើងវិញ និងផ្តោតការយកចិត្តទុកដាក់បន្ថែមចំពោះរដ្ឋបាលក្រុង ស្រុក និងឃុំ ព្រមទាំងទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់ ពីព្រោះរដ្ឋបាលទាំងពីរថ្នាក់នេះមានតួនាទីសំខាន់ណាស់ក្នុងការកៀរគរការចូលរួមរបស់ប្រជាពលរដ្ឋ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ ជាមួយគ្នានេះដែរ ក៏ត្រូវផ្តោតការយកចិត្តទុកដាក់គាំទ្រដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលរាជធានី ដែលជារដ្ឋបាលមូលដ្ឋានមានលក្ខណៈពិសេសមួយ និងទំនាក់ទំនងរវាងរដ្ឋបាលរាជធានី រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ក្នុងរាជធានីផងដែរ។

ក្រៅពីនេះ ផអ៣ទី៣ ចាំបាច់ត្រូវផ្លាស់ប្តូរយុទ្ធសាស្ត្រនៃការប្រើប្រាស់ធនធាន និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិពីបែបផែននៃការអភិវឌ្ឍសមត្ថភាព ដែលផ្តោតទៅលើការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទៅជាបែបផែននៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានជាក់ស្តែង។

ការផ្លាស់ប្តូរនេះ ត្រូវផ្សារភ្ជាប់ជាមួយនឹងការវិភាជធនធាននានាឡើងវិញ ដើម្បីមានលទ្ធភាពបង្កើនធនធានគាំទ្រដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានជាក់ស្តែង។ អាស្រ័យ

ហេតុនេះ ការវិភាជធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវមានការពិនិត្យឡើងវិញ ដើម្បីឱ្យមានលក្ខណៈសមស្របជាមួយនឹងចក្ខុវិស័យនៃកំណែទម្រង់វិមជ្ឈការ។ ការវិភាជធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ប្រភេទ ចាំបាច់ត្រូវផ្អែកទៅលើមុខងាររដោយឡែកៗពីគ្នារបស់ថ្នាក់រដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ក្នុងនាមជាអ្នកគាំទ្រ តាមដាន ត្រួតពិនិត្យ និងក្នុងនាមជាអ្នកផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋាន។

## ៧. បញ្ហាប្រឈម និងកាលានុវត្តភាពនៃផអ៣ទី៣

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានាបានជ្រួតជ្រាបជាបណ្តើរៗអំពីចក្ខុវិស័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈកា តាមរយៈបទពិសោធន៍ និងការរៀនសូត្រនានាចាប់តាំងពីការអនុវត្តផអ៣ទី១ និងផអ៣ទី២។ ទោះបីជាយ៉ាងនេះក៏ដោយ ក្នុងការអនុវត្តផអ៣ទី៣នេះអាចនឹងមានបញ្ហាប្រឈមចំនួន៣ដែលត្រូវដោះស្រាយ រួមមាន ៖

**ទី១ ៖ ការពុំទាន់ស្រុះស្រួលមូលគំនិតគ្នាអំពីការអនុវត្តគោលនយោបាយវិមជ្ឈការ** ជាពិសេសក្នុងក្របខ័ណ្ឌនៃស្វ័យភាព និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការអនុវត្តកំណែទម្រង់វិមជ្ឈការតម្រូវឱ្យមានការចូលរួមពីក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលទាំងមូល ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ក្រសួង ស្ថាប័នមួយចំនួននៅមានភាពស្ទាក់ស្ទើរក្នុងការអនុវត្តតាមគោលនយោបាយវិមជ្ឈការនេះ។ ទន្ទឹមនេះ ទោះបីក្រសួង ស្ថាប័នមួយចំនួនដែលស្រុះស្រួលឯកភាពក្នុងការអនុវត្តគោលនយោបាយនេះក៏ដោយ ក៏ល្បឿន និងបែបផែននៃការអនុវត្តកិច្ចការនេះមានភាពខុសៗគ្នាដែរ។ បញ្ហាទាំងនេះមិនអាចដោះស្រាយបានដោយគ្រាន់តែផ្អែកលើច្បាប់រៀបចំអង្គការនោះទេ អាស្រ័យហេតុនេះ ចាំបាច់ត្រូវមានការសម្របសម្រួលដោះស្រាយក្នុងកម្រិតនយោបាយ។ កន្លងមកនេះ ផអ៣ទី២បានបង្កើតកាលានុវត្តភាពនានាសម្រាប់ការពិភាក្សាកម្រិតនយោបាយដើម្បីដោះស្រាយបញ្ហាខាងលើ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ការពិភាក្សាកម្រិតនយោបាយទាំងនេះ រួមបញ្ចូលទាំងតួនាទីរបស់ គ.ជ.អ.ប. ចាំបាច់ត្រូវមានការពង្រឹងបន្ថែមទៀត។

**ទី២ ៖ ការអនុវត្តគោលនយោបាយ កម្មវិធី និងលិខិតបទដ្ឋាននានានៅពុំទាន់បានផ្តោតទៅលើមូលដ្ឋានឱ្យបានស៊ីជម្រៅ** ជាក់ស្តែង ការអនុវត្តផអ៣ទី១ និងផអ៣ទី២កន្លងមក ពុំទាន់បានផ្តោតការយកចិត្តទុកដាក់ឱ្យបានស៊ីជម្រៅក្នុងការប្រែក្លាយគោលនយោបាយ កម្មវិធី និងលិខិតបទដ្ឋាននានាឱ្យទៅជាការអនុវត្តជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតបាននូវសមិទ្ធផលនានាឱ្យបានច្រើនតាមដែលអាចធ្វើបានក្នុងការផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋនោះឡើយ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ចាំបាច់ត្រូវរៀបចំជាកម្មវិធី និងគម្រោងនានាដោយផ្តោតទៅលើការដោះស្រាយបញ្ហាជាក់លាក់ ឬការជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថតាមបែបផែនដ៏ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។

**ទី៣ ៖ ការចូលរួមរបស់សង្គមស៊ីវិល និងវិស័យឯកជនក្នុងការអនុវត្តកំណែទម្រង់នៅពុំទាន់មានភាពគ្រប់គ្រាន់** កន្លងមក ការចូលរួមរបស់សង្គមស៊ីវិល និងវិស័យឯកជនមានវឌ្ឍនភាពជាច្រើន តាម រ

យៈការចូលរួមក្នុងកិច្ចដំណើរការរៀបចំតាក់តែងគោលនយោបាយ ការកសាងផែនការ ការអនុវត្តគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការអភិវឌ្ឍសមត្ថភាព និងជាពិសេសការអនុវត្តការងារគណនេយ្យភាពសង្គម។ ប៉ុន្តែការចូលរួមរបស់សង្គមស៊ីវិល និងវិស័យឯកជនក្នុងភាពជាដៃគូនៅពុំទាន់មានភាពគ្រប់គ្រាន់នៅឡើយ។ អាស្រ័យហេតុនេះ ផអ៣ទី៣ចាំបាច់ត្រូវបន្តលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយសង្គមស៊ីវិល និងវិស័យឯកជននានាក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ព្រមទាំងរួមចំណែកលើកកម្ពស់អភិបាលកិច្ចល្អ ការអភិវឌ្ឍសមត្ថភាព និងលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោះបីមានបញ្ហាប្រឈមដូចបានរៀបរាប់ខាងលើក៏ដោយ ក៏ប៉ុន្តែមានកាលានុវត្តភាពជាច្រើនសម្រាប់ភាពជោគជ័យនៃការអនុវត្តផអ៣ទី៣ ដូចជា ៖

**ទីមួយ**៖ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងក្នុងការដោះស្រាយបញ្ហា និងតម្រូវការអភិវឌ្ឍនៅតាមមូលដ្ឋាន ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការប្រែក្លាយសិទ្ធិអំណាចទាំងនេះឱ្យទៅជាលទ្ធផលជាក់ស្តែង។ អាស្រ័យហេតុនេះ ផអ៣ទី៣ត្រូវប្រើប្រាស់កាលានុវត្តភាពនេះដើម្បីបង្កើនតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងបន្តអនុវត្តកម្មវិធីសាកល្បងនានា ដើម្បីបង្ហាញឱ្យឃើញពីផលប្រយោជន៍ជាក់ស្តែង។

**ទីពីរ** ៖ តាមរយៈការអនុវត្តផអ៣ទី១ និងផអ៣ទី២ ភាគីពាក់ព័ន្ធទាំងអស់មានការយល់ដឹងកាន់តែច្បាស់អំពីចក្ខុវិស័យនៃកំណែទម្រង់វិមជ្ឈការ ហើយសមត្ថភាពរបស់ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិបានកើនឡើងគួរឱ្យកត់សម្គាល់។

**ទីបី** ៖ កម្មវិធីកំណែទម្រង់ទាំង៣ រួមមាន កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបាន និងកំពុងសហការគ្នាកាន់តែជិតស្និទ្ធ និងធ្វើសុខដុមនីយកម្មនូវផែនការសកម្មភាពនៃកម្មវិធីកំណែទម្រង់ទាំងនេះ។

**ទីបួន** ៖ ប្រព័ន្ធព័ត៌មានសង្គម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានាដែលធ្វើឱ្យមានការកើនឡើងនូវការប្រាស្រ័យទាក់ទងគ្នារបស់សាធារណជន គឺជាកាលានុវត្តភាពដ៏ធំធេងមួយ ក្នុងការផ្តល់ព័ត៌មានផ្សេងៗតាមគ្រប់រូបភាព ដើម្បីជំរុញឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើរការកំណែទម្រង់កាន់តែច្រើនឡើង។

## ៨. កិច្ចដំណើរការរៀបចំតាក់តែងផអ៣ទី៣

ផអ៣ទី៣ត្រូវបានរៀបចំឡើងក្នុងគោលបំណងបន្តលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរ និងការផ្តួចផ្តើមគំនិតថ្មីៗក្នុងការដោះស្រាយបញ្ហានានានៅមូលដ្ឋាន។ កិច្ចដំណើរការនៃការរៀបចំកាត់តែងផអ៣ទី៣

មានលក្ខណៈខុសប្លែកពីការរៀបចំកាត់តែងផអ៣ទី១ និងផអ៣ទី២ ព្រោះឯកសារនេះត្រូវបានរៀបចំតាក់តែងដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ផ្អែកលើរបាយការណ៍នៃការសិក្សាវាយតម្លៃរបស់ក្រុមទីប្រឹក្សាឯករាជ្យលើសេចក្តីព្រាងបឋមនៃផអ៣ទី៣ ដែលបានរៀបចំផ្ទៃក្នុងដោយក្រុមការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។ ឯកសារផអ៣ទី៣ត្រូវបានរៀបចំដោយផ្អែកជាមូលដ្ឋានលើឯកសារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- របាយការណ៍ស្តីពីការវាយតម្លៃពាក់កណ្តាលកម្មវិធីនៃកម្មវិធីជាតិ
- ឯកសារបំពេញបន្ថែមចំពោះកម្មវិធីជាតិ
- របាយការណ៍អង្កេតអភិបាលកិច្ចឆ្នាំ២០១៦ និងឆ្នាំ២០១៧
- របាយការណ៍សវនកម្មយេនឌ័រឆ្នាំ២០១៦
- របាយការណ៍ស្តីពីការសិក្សាវាយតម្លៃអំពីយុទ្ធសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពផអ៣ទី២
- ឯកសារពាក់ព័ន្ធផ្សេងទៀត។

ជារួម កិច្ចដំណើរការនៃការរៀបចំតាក់តែងឯកសារផអ៣ទី៣ត្រូវបានចាប់ផ្តើមពី ខែមីនាដល់ខែតុលា ឆ្នាំ២០១៧ និងបែងចែកជា៤ជំហានសំខាន់ៗ គឺ ៖

**ជំហានទី១** ការរៀបចំឯកសារទស្សនទានស្តីពីកិច្ចដំណើរការសម្រាប់ការរៀបចំតាក់តែងផអ៣ទី៣ ដែលបានរៀបចំឡើងក្នុងខែមីនា ឆ្នាំ២០១៧។ ឯកសារនេះ រៀបរាប់អំពីចរិកលក្ខណៈនៃផអ៣ទី៣ ឯកសារយោងដែលត្រូវប្រើប្រាស់ក្នុងការរៀបចំកាត់តែង កិច្ចដំណើរការរៀបចំតាក់តែង ឯកសារដែលត្រូវរៀបចំជាឧបសម្ព័ន្ធ កម្មវិធីនិងពេលវេលា តម្រូវការទីប្រឹក្សាឯករាជ្យ និងថវិកាពាក់ព័ន្ធនឹងការរៀបចំ។ ឯកសារទស្សនទាននេះក៏បានផ្ញើជូនដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពិនិត្យ និងផ្តល់យោបល់ផងដែរ។

**ជំហានទី២** ការរៀបចំសេចក្តីព្រាងបឋមនៃឯកសារផអ៣ទី៣ បានរៀបចំផ្ទៃក្នុងដោយក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងអំឡុងខែមេសា-ឧសភា ឆ្នាំ២០១៧ និងបានចែកជូនដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាពិនិត្យ និងផ្តល់យោបល់។

**ជំហានទី៣** ការសិក្សាវាយតម្លៃលើសេចក្តីព្រាងបឋមនៃឯកសារផអ៣ទី៣ ដោយក្រុមទីប្រឹក្សាឯករាជ្យរួមមានសមាជិកចំនួន៥រូប (ស្ត្រី៣រូប) ដែលក្នុងមានទីប្រឹក្សាជាតិចំនួន២រូប។ ផ្អែកលើសេចក្តីព្រាងបឋមនៃឯកសារផអ៣ទី៣ ដែលបានរៀបចំផ្ទៃក្នុងដោយក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងជំហានទី២ ក្រុមទីប្រឹក្សាឯករាជ្យបានធ្វើការសិក្សាវាយតម្លៃក្នុងអំឡុងខែឧសភា-មិថុនា ឆ្នាំ២០១៧ រួមបញ្ចូលទាំងការប្រឹក្សាយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត។ សេចក្តីព្រាងនៃរបាយការណ៍នៃការសិក្សាវាយតម្លៃបានរៀបចំ និងបង្ហាញក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប. ពិនិត្យ និងផ្តល់យោបល់ជាបន្តបន្ទាប់។ របាយការណ៍ចុងក្រោយនៃការសិក្សាវាយតម្លៃបានរៀបចំ និងផ្ញើជូនលេខាធិការដ្ឋាន គ.ជ.អ.ប. នៅចុងខែកក្កដា ឆ្នាំ ២០១៧។ ជាមួយគ្នានេះដែរ ក្រុមសិក្សាវាយតម្លៃក៏បានរៀបចំ និងផ្ញើជូនលេខាធិការ

ដ្ឋាន គ.ជ.អ.ប. ជាបន្តបន្ទាប់នូវឯកសារឧបសម្ព័ន្ធនានានៃ ផអ៣ទី៣ក្នុងអំឡុងខែសីហា ឆ្នាំ២០១៧។

**ជំហានទី៤** ការរៀបចំសេចក្តីព្រាងលម្អិតនៃឯកសារផអ៣ទី៣។ ផ្អែកលើរបាយការណ៍សិក្សាវាយតម្លៃលើសេចក្តីព្រាងបឋមនៃឯកសារផអ៣ទី៣ និងឯកសារឧបសម្ព័ន្ធនានាដែលបានរៀបចំដោយក្រុមទីប្រឹក្សាឯករាជ្យ ក្រុមការងារនៃលេខាធិការដ្ឋាន គ.ជ.អ.ប. បានពិនិត្យ និងរៀបចំជាសេចក្តីព្រាងលម្អិតនៃឯកសារផអ៣ទី៣ រួមបញ្ចូលទាំងឧបសម្ព័ន្ធនានា ក្នុងអំឡុងខែសីហា-តុលា ឆ្នាំ២០១៧។ សេចក្តីព្រាងលម្អិតនៃឯកសារផអ៣ទី៣ ត្រូវបានពិភាក្សា និងពិគ្រោះយោបល់យ៉ាងផុលផុស និងទូលំទូលាយជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ក្នុងអំឡុងខែតុលា ឆ្នាំ ២០១៧ តាមរយៈកិច្ចប្រជុំ និងសិក្ខាសាលានានា។

## ៩. រចនាសម្ព័ន្ធនៃផអ៣ទី៣

ឯកសារផអ៣ទី៣បែងចែកជា៣ជំពូកធំៗ និងមានឧបសម្ព័ន្ធចំនួន៧។ ជំពូកទី១អំពីទិដ្ឋភាពទូទៅនៃកម្មវិធី ជំពូកទី២អំពីសមាសភាគទាំង៥នៃផអ៣ទី៣ និងជំពូកទី៣អំពីការគ្រប់គ្រងកម្មវិធី។

**ជំពូកទី១** បរិយាយអំពីសេចក្តីផ្តើម ចក្ខុវិស័យ គោលបំណងនិងគោលដៅ សមិទ្ធផលនិងលទ្ធផលរំពឹងទុក គុណតម្លៃ លក្ខណៈពិសេស បញ្ហាប្រឈមនិងកាលានុវត្តភាព កិច្ចដំណើរការរៀបចំតាក់តែង រចនាសម្ព័ន្ធនៃផអ៣ទី៣ យុទ្ធសាស្ត្រគន្លឹះៗសម្រាប់គ្រប់គ្រងកម្មវិធី និងថវិកាប៉ាន់ស្មាននៃកម្មវិធី។

**ជំពូកទី២** ជាផ្នែកមួយដ៏សំខាន់នៃផអ៣ទី៣ រៀបរាប់អំពីសមាសភាគទាំង៥នៃផអ៣ទី៣ ហើយព័ត៌មានសំខាន់ៗដែលបានបរិយាយក្នុងសមាសភាគនីមួយៗរួមមាន សេចក្តីផ្តើម វឌ្ឍនភាពនិងបញ្ហាប្រឈម សមិទ្ធផលនិងលទ្ធផលរំពឹងទុក គម្រោងថវិកា និងហានិភ័យនិងការកាត់បន្ថយហានិភ័យ។ ជាទូទៅ លទ្ធផលរំពឹងទុកនីមួយៗត្រូវបានរៀបចំក្នុងទម្រង់ជា**គម្រោង** ដើម្បីធានាការទទួលខុសត្រូវច្បាស់លាស់ ការត្រួតពិនិត្យការអនុវត្ត និងការសម្រេចបានលទ្ធផលរំពឹងទុកស្របតាមផែនការ និងពេលវេលាដែលបានកំណត់។ ក្នុងលទ្ធផលរំពឹងទុកនីមួយៗមានបរិយាយអំពីគោលដៅ សកម្មភាពជាចម្បង ចំណុចដៅ និងការទទួលខុសត្រូវក្នុងការអនុវត្ត។ ព័ត៌មានបន្ថែមអំពីលទ្ធផលរំពឹងទុកដែលពាក់ព័ន្ធនឹងសនិទានភាព និងមូលដ្ឋានសម្រាប់ការត្រួតពិនិត្យគុណភាពការងារមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធទី១។ បញ្ហាអន្តរវិស័យដូចជា បរិយាប័ន្ននិងសមធម៌សង្គម ការប្រាស្រ័យទាក់ទងនិងការផ្សព្វផ្សាយព័ត៌មាន និងការចូលរួមរបស់សង្គមស៊ីវិល និងវិស័យឯកជនត្រូវបានបញ្ជ្រាបក្នុងគ្រប់សមាសភាគទាំងអស់។

**ជំពូកទី៣** រៀបរាប់អំពីបែបផែនផ្នែកស្ថាប័នសម្រាប់ការគ្រប់គ្រងកម្មវិធីកិច្ចដំណើរការគ្រប់គ្រងកម្មវិធី ការគ្រប់គ្រងហិរញ្ញវត្ថុ និងគម្រោងថវិកាកម្មវិធី។

ទោះបីលទ្ធផលរំពឹងទុកនីមួយៗ ត្រូវបានរៀបចំក្នុងទម្រង់ជាគម្រោងដែលមានយុទ្ធសាស្ត្រអនុវត្តច្បាស់លាស់ក៏ដោយ ក៏លទ្ធផលរំពឹងទុកមួយចំនួនដែលមានវិសាលភាពធំទូលាយ មានលក្ខណៈស្មុគស្មាញ និងមានភាគីពាក់ព័ន្ធច្រើន ទាមទារនូវយុទ្ធសាស្ត្រអនុវត្តន៍ដាច់ដោយឡែក និងមានលក្ខណៈស៊ីជម្រៅ ដើម្បីធានាការសម្រេចបានលទ្ធផលរំពឹងទុកទាំងនោះ។ អាស្រ័យហេតុនេះ ឯកសារផអ៣ទី៣

បានរៀបចំ និងបញ្ចូលយុទ្ធសាស្ត្រទាំងនោះជាឧបសម្ព័ន្ធរួមមានដូចខាងក្រោម ៖

**ឧបសម្ព័ន្ធទី ១** អំពីសនិទានភាព និងមូលដ្ឋានសម្រាប់ការត្រួតពិនិត្យការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗរបស់ផអ៣ទី៣

**ឧបសម្ព័ន្ធទី ២** អំពីក្របខ័ណ្ឌលទ្ធផល និងយុទ្ធសាស្ត្រត្រួតពិនិត្យ និងវាយតម្លៃ

**ឧបសម្ព័ន្ធទី ៣** យុទ្ធសាស្ត្រស្តីពីការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម

**ឧបសម្ព័ន្ធទី ៤** យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាព

**ឧបសម្ព័ន្ធទី ៥** យុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការចូលរួមរបស់សង្គមស៊ីវិលនិងវិស័យឯកជន

**ឧបសម្ព័ន្ធទី ៦** យុទ្ធសាស្ត្រស្តីពីនិរន្តរភាពផ្នែកហិរញ្ញវត្ថុរបស់កម្មវិធី

**ឧបសម្ព័ន្ធទី ៧** អំពីវាក្យសព្ទសំខាន់ៗ និងនិយមន័យ

## ១០. យុទ្ធសាស្ត្រគន្លឹះៗសម្រាប់គ្រប់គ្រងកម្មវិធី

ភាពជោគជ័យនៃការអនុវត្តផអ៣ទី៣ អាស្រ័យទាំងស្រុងទៅលើបែបផែននៃការគ្រប់គ្រងដែលចាំបាច់ត្រូវប្រើប្រាស់នូវកិច្ចដំណើរការនានា ដើម្បីសម្របសម្រួល និងធ្វើឱ្យមានសង្គតិភាពជាមួយគ្នារវាងស្ថាប័នអនុវត្តថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងអ្នកពាក់ព័ន្ធនានា។ ជារួម យុទ្ធសាស្ត្រគន្លឹះៗដែលត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការអនុវត្តផអ៣ទី៣ មានដូចខាងក្រោម៖

**តារាងទី២ ៖យុទ្ធសាស្ត្រគន្លឹះៗសម្រាប់គ្រប់គ្រងកម្មវិធី**

| យុទ្ធសាស្ត្រ | ការបរិយាយ |
|---|---|
| ការពង្រឹងគណនេយ្យភាពសម្រាប់ការអនុវត្តការងារ | ក្នុងអំឡុងពេលនៃផអ៣ទី១ និងផអ៣ទី២ មានបញ្ហាប្រឈមមួយចំនួនដែលបានជួបប្រទះពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (ផ.ស.ថ) មានដូចជា លទ្ធផលរំពឹងទុក និងសកម្មភាពមួយចំនួនបានពន្យារពេលអនុវត្តជាបន្តបន្ទាប់ ឬពុំបានអនុវត្ត ឬបន្តអនុវត្តរយៈពេល២-៣ឆ្នាំជាប់គ្នា ដោយពុំមានកាលបរិច្ឆេទបញ្ចប់ច្បាស់លាស់។ អាស្រ័យហេតុនេះ ផអ៣ទី៣ នឹងពង្រឹងការត្រួតពិនិត្យ និងតាមដានការអនុវត្តសកម្មភាពរបស់ស្ថាប័នអនុវត្តនានា ដើម្បីលើកកម្ពស់គណនេយ្យភាពនៃការអនុវត្តការងាររបស់ខ្លួន។ |
| ការបញ្ជ្រាបក្នុងប្រព័ន្ធរដ្ឋដើម្បីធានានិរន្តរភាព | ជាបណ្តើរៗ ការងារកំណែទម្រង់ត្រូវបានទទួលខុសត្រូវកាន់តែច្រើនឡើងដោយមន្ត្រីរាជការ ដូច្នេះ ជំនួយបច្ចេកទេសនឹងត្រូវធ្វើការកាត់បន្ថយជាបន្តបន្ទាប់ ស្របតាមផែនការ និងយុទ្ធសាស្ត្រច្បាស់លាស់។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ .ប.អ.ជ.នឹងពង្រឹងតួនាទីអភិវឌ្ឍន៍គោលនយោបាយរបស់ខ្លួន និងផ្ទេរបន្តិចម្តងៗនូវតួនាទីអនុវត្តទៅឱ្យក្រសួងមហាផ្ទៃ ព្រមទាំងបង្កើនការប្រើប្រាស់ថវិការដ្ឋ ដើម្បីគាំទ្រ |

| យុទ្ធសាស្ត្រ | ការបរិយាយ |
|---|---|
| | សកម្មភាពនានានៃកំណែទម្រង់។ អាស្រ័យហេតុនេះ ត្រូវរៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីនិរន្តរភាពឱ្យបានច្បាស់លាស់។ |
| ការសាកល្បង ការសិក្សារៀនសូត្រ និងការបង្កើតបរិយាកាស សមស្រប សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការសាកល្បង | ផអ៣ទី៣នឹងបង្កើនការយកចិត្តទុកដាក់លើការសាកល្បង និងការសិក្សារៀនសូត្រ។ ការសាកល្បងផ្តល់នូវភស្តុតាងអំពីភាពដែលអាចដំណើរការទៅបានចំពោះទស្សនទានណាមួយ។ កិច្ចការនេះផ្តោតលើការសាកល្បងនូវជម្រើសនានា ដើម្បីកែលម្អការផ្តល់សេវា និងជាមូលដ្ឋានសម្រាប់រៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនានា។ |
| ការធ្វើឱ្យមានលក្ខណៈសាមញ្ញនូវការងារកំណែទម្រង់ និងការប្រាស្រ័យទាក់ទងនិងការផ្សព្វផ្សាយព័ត៌មាន | កន្លងមកមានសេចក្តីណែនាំ សៀវភៅណែនាំ និងឯកសារបច្ចេកទេសជាច្រើនបានរៀបចំ និងដាក់ឱ្យអនុវត្ត។ ឯកសារមួយចំនួនមានភាពស្មុគស្មាញដែលលើសពីសមត្ថភាពស្រូបយករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងពុំទាន់មានលក្ខណៈសមស្របទៅនឹងគោលការណ៍ស្វ័យភាពមូលដ្ឋាន។ អាស្រ័យហេតុនេះ ផអ៣ទី៣នឹងរៀបចំសារអប់រំ ផ្សព្វផ្សាយដែលមានលក្ខណៈសាមញ្ញ និងងាយយល់ ដោយផ្តោតលើគោលការណ៍ជាគន្លឹះនានា ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តបានតាមគោលការណ៍ទាំងនោះ ប្រកបដោយភាពបត់បែន មានប្រសិទ្ធភាព និងតម្លាភាព។ |
| ការប្រែក្លាយពីគោលនយោបាយមកជាការអនុវត្តជាក់ស្តែង និងការអនុវត្តលទ្ធផលរំពឹងទុកតាមបែបផែននៃការអនុវត្តគម្រោង | លទ្ធផលរំពឹងទុកនានានឹងត្រូវអនុវត្តតាមបែបផែនជាគម្រោង ដែលផ្តោតលើការដោះស្រាយបញ្ហាជាក់លាក់ និងចំណុចដៅច្បាស់លាស់ពាក់ព័ន្ធនឹងការផ្លាស់ប្តូរឥរិយាបថណាមួយ។ គម្រោងនីមួយៗត្រូវមានគោលដៅ ចំណុចដៅ អ្នកទទួលខុសត្រូវ និងសកម្មភាពច្បាស់លាស់ ដើម្បីធានាការគ្រប់គ្រង និងការសម្រេចបាននូវលទ្ធផលនានាតាមការគ្រោងទុក។ ការអនុវត្តគម្រោងនានានឹងត្រូវផ្សារភ្ជាប់ជាមួយកិច្ចការអន្តរវិស័យ ដូចជា ការអភិវឌ្ឍសមត្ថភាព ការប្រាស្រ័យទាក់ទងនិងការផ្សព្វផ្សាយព័ត៌មាន បរិយាប័ន្ន និងសមធម៌សង្គម និងភាពជាដៃគូជាមួយសង្គមស៊ីវិល និងវិស័យឯកជននានាជាដើម។ អភិក្រមនេះ ត្រូវបានអនុវត្តប្រកបដោយជោគជ័យក្នុងការងារគណនេយ្យភាពសង្គម និងការិយាល័យច្រកចេញចូលតែមួយ។ |
| ការធ្វើសុខដុមនីយកម្មរវាងកម្មវិធីកំណែទម្រង់នានា និងគម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍ | ផអ៣ទី៣នឹងបន្តពង្រឹងការធ្វើសុខដុមនីយកម្មរវាងកម្មវិធីកំណែទម្រង់ទាំង៣ រួមមាន កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីបន្សីគ្នា កាត់បន្ថយចំណាយប្រតិបត្តិការ និងលើកកម្ពស់អនុវត្តការងារ។ ក្នុងន័យនេះ កម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនឹងបន្តពង្រឹងកិច្ចសហការជាមួយកម្មវិធីកំណែទម្រង់រដ្ឋបាល |

| យុទ្ធសាស្ត្រ | ការបរិយាយ |
|---|---|
| | សាធារណៈ ដើម្បីលើកកម្ពស់ ការអនុវត្តមុខងារពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយ ការត្រួតពិនិត្យមើលពីលើ និងការគាំទ្រនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការកែសម្រួលរចនាសម្ព័ន្ធរបស់អង្គភាពនានានៃក្រសួង ស្ថាប័ន និងខេត្ត ស្របតាមការវិវត្តនៃវិមជ្ឈការ។ ជាមួយគ្នានេះដែរ កម្មវិធី កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនឹងបន្តពង្រឹងកិច្ចសហការជាមួយកម្មវិធីកំណែ ទម្រង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនប្រសិទ្ធភាព និងកិច្ចប្រតិបត្តិការរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ ព្រមទាំងធានាបាននូវគុណតម្លៃនៃថវិកាក្នុងការចំណាយ។<br>បច្ចុប្បន្ន មានគម្រោង កម្មវិធីរបស់ដៃគូអភិវឌ្ឍន៍មួយចំនួនពុំទាន់បានបន្សុី និងឆ្លើយតប បានសមស្របជាមួយកម្មវិធីជាតិ និងផអ៣នៅឡើយទេដូចជា ការអនុវត្តតាមបែបផែន ដោយឡែក ឬត្រូវការការពេលវេលា និងការគាំទ្រជាច្រើនពីថ្នាក់ដឹកនាំ និងបុគ្គលិកនៃលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ។ អាស្រ័យហេតុនេះ ផអ៣ទី៣នឹង ជំរុញលើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍន៍ទាំងនោះ យកចិត្តទុកដាក់ក្នុងការប្រើប្រាស់ប្រព័ន្ធ របស់រដ្ឋ ឬអនុវត្តគម្រោងរបស់ខ្លួនតាមរយៈបែបផែននៃថវិកាកញ្ចប់រួម។ |

## ១១. ថវិកាប៉ាន់ស្មានសរុបរបស់ផអ៣ទី៣

ផ្នែកនេះសង្ខេបអំពីការប៉ាន់ស្មានថវិកាចំណាយ និងប្រភពមូលនិធិនានាសម្រាប់គាំទ្រផអ៣ទី៣។ ព័ត៌មានលម្អិតអំពីថវិកាប៉ាន់ស្មានរបស់ផអ៣ទី៣នឹងមានអធិប្បាយនៅក្នុងជំពូកទី៣នៃឯកសារនេះ។

### ក. ថវិកាប៉ាន់ស្មានសម្រាប់កម្មវិធី

ថវិកាចំណាយសម្រាប់ការអនុវត្តផអ៣ទី៣ បែងចែកជា២ប្រភេទធំៗពោលគឺ ការចំណាយសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ និងការផ្ទេរធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

១). ការចំណាយសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ រួមបញ្ចូលទាំងការវិនិយោគទៅលើសមត្ថភាព ការអភិវឌ្ឍគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ប្រព័ន្ធ នីតិវិធី និងសេចក្តីណែនាំនានា និងការចំណាយសម្រាប់ការគ្រប់គ្រង និងកិច្ចប្រតិបត្តិការនានានៃកម្មវិធី

២). ការផ្ទេរធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាការផ្ទេរធនធានមូលនិធិពីថវិការដ្ឋ និងមូលនិធិពីដៃគូអភិវឌ្ឍន៍នានាទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ដោយផ្ទាល់។

ថវិកាចំណាយសរុបសម្រាប់កម្មវិធីត្រូវបានប៉ាន់ស្មានចំនួន១.៩០០លានដុល្លារអាមេរិក ដែលក្នុងនោះរួមមានថវិកាចំនួនប្រមាណ២៣៤លានដុល្លារអាមេរិក សម្រាប់ការចំណាយទៅលើសកម្មភាព

ស្នូលនៃកំណែទម្រង់ និងថវិកាប្រមាណ១.៦៦៤លានដុល្លារអាមេរិក សម្រាប់ការផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនានា។ ថវិកាចំណាយលើសកម្មភាពស្នូលនៃកំណែទម្រង់ត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាល និងការផ្តល់ហិរញ្ញប្បទានជាផន្ទានុសិទ្ធិពីដៃគូអភិវឌ្ឍន៍មួយចំនួន តាមរយៈថវិកាកញ្ចប់រួម និងគម្រោងនានា ព្រមទាំងការផ្តល់ហិរញ្ញប្បទានកម្ចីរបស់ដៃគូមួយចំនួនដល់រាជរដ្ឋាភិបាល។ ថវិកាចំណាយប៉ាន់ស្មានសរុបសម្រាប់ផអ៣ទី៣មានសង្ខេបដូចក្នុងតារាងខាងក្រោម។

### តារាងទី៣ ៖ ថវិកាចំណាយប៉ាន់ស្មានសរុបសម្រាប់កម្មវិធី (គិតជាដុល្លារអាមេរិក)

| ការបរិយាយ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | សរុប |
|---|---|---|---|---|
| **ក. ការចំណាយលើសកម្មភាពស្នូលនៃកំណែទម្រង់** | | | | |
| ១. ការគ្រប់គ្រងកំណែទម្រង់ | 5,777,696 | 3,930,746 | 4,007,296 | 13,715,738 |
| ២. អភិបាលកិច្ចល្អ | 11,464,200 | 12,254,550 | 11,838,200 | 35,556,950 |
| ៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | 11,998,998 | 8,816,249 | 7,509,550 | 28,324,797 |
| ៤. ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន | 40,072,936 | 39,720,658 | 47,530,471 | 127,324,064 |
| ៥. វិមជ្ឈការហិរញ្ញវត្ថុ | 6,130,462 | 10,907,191 | 12,234,130 | 29,271,782 |
| **សរុបក** | **75,444,291** | **75,629,394** | **83,119,646** | **234,193,331** |
| **ខ. ការផ្ទេរធនធានមូលនិធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | |
| ធនធានមូលនិធិរាជរដ្ឋាភិបាល | 465,474,390 | 553,730,297 | 641,709,184 | 1,660,913,870 |
| ធនធានមូលនិធិគាំទ្រដោយសហភាពអឺរ៉ុប | 4,000,000 | 0 | 0 | 4,000,000 |
| **សរុបខ** | **469,474,390** | **553,730,297** | **641,709,184** | **1,664,913,870** |
| **សរុបរួម** | **544,918,681** | **629,359,691** | **724,828,830** | **1,899,107,202** |

## ខ. ការផ្ទេរធនធានមូលនិធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

ធនធានមូលនិធិប៉ាន់ស្មានសរុបសម្រាប់រយៈពេលបីឆ្នាំនៃកម្មវិធី ដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិពីឆ្នាំ២០១៨-២០២០មានចំនួនប្រមាណ១.៦៦៤លានដុល្លារអាមេរិក។ ធនធានមូលនិធិនេះរួមបញ្ចូលទាំងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ មានចំនួនប្រមាណ១៧,៥លានដុល្លារអាមេរិក ដែលគ្រោងសម្រាប់គាំទ្រគម្រោងវិនិយោគសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈសំណើគម្រោង (ថវិកានេះបានគិតបញ្ចូលទៅក្នុងផ្នែកសកម្មភាពស្នូលនៃកំណែទម្រង់)។ ធនធានមូលនិធិប៉ាន់ស្មានសរុបសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ថវិកាចំនួនប្រមាណ១.០៨៤លានដុល្លារអាមេរិកសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ថវិកាចំនួនប្រមាណ២១១លានដុល្លារអាមេរិកសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក និងថវិកាចំនួនប្រមាណ៣៨២លានដុល្លារអាមេរិកសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលឃុំ សង្កាត់។

**តារាងទី៤ ៖ ការផ្ទេរធនធានមូលនិធិឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ (គិតដុល្លារអាមេរិក)**

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | សរុប |
|---|---|---|---|---|
| ថវិការាជធានី ខេត្ត | 310,365,425 | 360,018,016 | 418,200,450 | **1,088,583,891** |
| ថវិកាក្រុង ស្រុក | 52,437,923 | 74,032,786 | 84,707,833 | **211,178,541** |
| ថវិកាឃុំ សង្កាត់ | 110,171,042 | 126,679,495 | 145,800,901 | **382,651,438** |
| **សរុប** | **472,976,408** | **560,732,316** | **648,711,204** | **1,682,419,927** |

## គ. ថវិកាចំណាយសម្រាប់ជំនួយបច្ចេកទេស

ជំនួយបច្ចេកទេសរួមមានបុគ្គលិកជាទីប្រឹក្សា និងជាបុគ្គលិកកិច្ចសន្យានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលជ្រើសរើសដោយ គ.ជ.អ.ប។ តួនាទីដ៏សំខាន់របស់ទីប្រឹក្សា គឺការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការ និងការផ្តួចផ្តើមគំនិតនានាក្នុងការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានា។ បុគ្គលិកកិច្ចសន្យាត្រូវបានជ្រើសរើសដើម្បីជួយបំពេញការងារប្រចាំថ្ងៃរបស់ស្ថាប័ននានា ជាពិសេសនៅរដ្ឋបាលក្រុង និង ស្រុកដែលមានការខ្វះខាតធនធានមនុស្ស។

ក្នុងអំឡុងពេលនៃផអ៣ទី៣ការចំណាយសម្រាប់ជំនួយបច្ចេកទេសត្រូវបានកាត់បន្ថយជាច្រើនក្នុងចំនួនប្រមាណ៥០០.០០០ដុល្លារអាមេរិកជាមធ្យមក្នុងមួយឆ្នាំ។

ថវិកាចំណាយប៉ាន់ស្មានសរុបសម្រាប់ជំនួយបច្ចេកទេសនៃផអ៣ទី៣ក្នុងរយៈពេល៣ឆ្នាំពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០ មានចំនួនប្រមាណ១១,៥លានដុល្លារអាមេរិក។

**តារាងទី៥ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់ជំនួយបច្ចេកទេស (គិតជាដុល្លារអាមេរិក)**

| ជំនួយបច្ចេកទេសសម្រាប់ថ្នាក់រដ្ឋបាលនីមួយៗ | ២០១៨ | ២០១៩ | ២០២០ | សរុប |
|---|---|---|---|---|
| ថ្នាក់ជាតិ | 1,262,400 | 1,227,600 | 1,117,200 | **3,607,200** |
| ថ្នាក់រាជធានី ខេត្ត | 2,320,080 | 2,122,080 | 1,924,080 | **6,366,240** |
| ថ្នាក់ក្រុង ស្រុក | 672,000 | 504,000 | 336,000 | **1,512,000** |
| **សរុប** | **4,254,480** | **3,853,680** | **3,377,280** | **11,485,440** |

# ជំពូកទី២

# សមាសភាគនានានៃផ្អកទឹក

ជំពូកនេះ គឺជាជំពូកមួយដ៏សំខាន់នៃឯកសារផអ៣ទី៣ ដែលរៀបរាប់អំពីសមាសភាគទាំង**៥** នៃផអ៣ទី៣ ព្រមទាំងសមិទ្ធផល និងលទ្ធផលរំពឹងទុកនានាដែលត្រូវសម្រេចឱ្យបានក្នុងរយៈពេល៣ ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០។ សមាសភាគទាំង៥រួមមាន ៖

**១. ការគ្រប់គ្រងការងារកំណែទម្រង់**

**២. អភិបាលកិច្ចល្អ**

**៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

**៤. ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន**

**៥. វិមជ្ឈការហិរញ្ញវត្ថុ**

ក្នុងសមាសភាគនីមួយៗ រួមមានសេចក្តីផ្តើម និងការបរិយាយអំពីវឌ្ឍនភាព និងបញ្ហាប្រឈម សមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក គម្រោងថវិកា និងការគ្រប់គ្រងហានិភ័យ។

ក្នុងលទ្ធផលរំពឹងទុកនីមួយៗមានសង្ខេបអំពីគោលដៅ សកម្មភាពជាចម្បងៗ និងស្ថាប័ន ទទួលខុសត្រូវក្នុងការអនុវត្ត ដើម្បីធានាឱ្យសម្រេចបាននូវលទ្ធផលរំពឹងទុកទាំងនោះ។

ការលើកកម្ពស់បរិយាប័ន្ននិងសមធម៌សង្គម និងបញ្ហាពាក់ព័ន្ធមួយចំនួនទៀតដូចជា យុទ្ធសាស្ត្រ នៃការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន ការអភិវឌ្ឍសមត្ថភាព ភាពជាដៃគូជាមួយសង្គម ស៊ីវិលនិងវិស័យឯកជននានាត្រូវបានបញ្ជ្រាបក្នុងលទ្ធផលរំពឹងទុកពាក់ព័ន្ធនានា ផ្អែកតាមចរិកលក្ខណៈរបស់លទ្ធផលរំពឹងទុកនីមួយៗនោះ។

# សមាសភាគទី ១

# ការគ្រប់គ្រងការងារកំណែទម្រង់

## ក. សេចក្តីផ្តើម

ភាពជោគជ័យនៃការអនុវត្តជអ៣ទី៣ អាស្រ័យលើការគ្រប់គ្រងការងារកំណែទម្រង់ទាំងអស់បានល្អប្រសើរ។ សមាសភាគទី១នេះមានគោលបំណងលើកកម្ពស់ការគ្រប់គ្រងកំណែទម្រង់ប្រកបដោយសុខដុមនីយកម្ម និរន្តរភាព និងការផ្លាស់ប្តូរជាវិជ្ជមាន។ យុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងកម្មវិធីជអ៣ទី៣មានបរិយាយលម្អិតបន្ថែមនៅក្នុងជំពូកទី៣។

## ខ. វឌ្ឍនភាព និងបញ្ហាប្រឈម

គ.ជ.អ.ប. បានរៀបចំកិច្ចប្រជុំទៅតាមផែនការដែលបានគ្រោងដើម្បីពិភាក្សា និងអនុម័តគោលនយោបាយ លិខិតបទដ្ឋាន កម្មវិធី ផែនការសកម្មភាពនានាពាក់ព័ន្ធនឹងការងារកំណែទម្រង់ និងដើម្បីតាមដានត្រួតពិនិត្យលើការអនុវត្តកិច្ចដំណើរការកំណែទម្រង់។ កិច្ចប្រជុំពិភាក្សារវាងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការផ្ទេរមុខងារត្រូវបានរៀបចំតាមផែនការ និងប្រកបដោយការស្ថាបនា។ ជាមួយគ្នានេះ កិច្ចសហការ និងការសម្របសម្រួលរវាងកំណែទម្រង់ទាំង៣ រួមមានកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏ត្រូវបានពង្រឹងផងដែរ។

ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានវាយតម្លៃពាក់កណ្តាលកម្មវិធីនៅក្នុងឆ្នាំ២០១៦ ដោយក្រុមវាយតម្លៃឯករាជ្យពីខាងក្រៅ ហើយលទ្ធផលនៃការវាយតម្លៃនេះបានបង្ហាញឱ្យឃើញពីភាពវិជ្ជមាននៃការអនុវត្តជអ៣ទី២ ដែលបានអនុវត្តចំទិសដៅ និងបានលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិប្រសើរជាងការអនុវត្តក្នុងជអ៣ទី១។

យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មានត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដើម្បីបង្កើនការផ្សព្វផ្សាយព័ត៌មានស្តីពីកំណែទម្រង់វិមជ្ឈការឱ្យបានកាន់តែទូលំទូលាយ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ជំនួយបច្ចេកទេសសម្រាប់ការគាំទ្រកម្មវិធី ត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ពីចំនួនប្រមាណ១០,២លានដុល្លារក្នុងឆ្នាំ២០១២ មកចំនួនប្រមាណ៤,៥លានដុល្លារក្នុងឆ្នាំ២០១៧។ ជាមួយគ្នានេះ ការចំណាយថវិកាសម្រាប់គាំទ្រកម្មវិធីទាំងមូលក៏បានថយចុះពីចំនួនប្រមាណ២០,២លានដុល្លារក្នុងឆ្នាំ២០១១ មកចំនួនប្រមាណ១១,៩លានដុល្លារ ក្នុងឆ្នាំ២០១៧

ពេលគឺមានការថយចុះប្រមាណ៥០%នៃធនធានសរុបដែលបានប្រើប្រាស់ក្នុងបណ្តាឆ្នាំដំបូងៗនៃការអនុវត្តកម្មវិធីជាតិ។ ទោះបីមានការថយចុះថវិកាគាំទ្រទាំងនេះក៏ដោយ ក៏ការអនុវត្តកម្មវិធីជាតិបានដំណើរការដោយរលូន និងសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើននៃផែនការដែលបានគ្រោងទុក។

ជាមួយនឹងវឌ្ឍនភាពជាច្រើនដូចបានរៀបរាប់ខាងលើ ក៏នៅមានបញ្ហាប្រឈម និងការងារជាអាទិភាពមួយចំនួនដែលត្រូវដោះស្រាយ និងសម្របសម្រួលដូចខាងក្រោម ៖

- ការសម្របសម្រួលដោះស្រាយនូវភាពពុំទាន់ស្រុះស្រួលមូលគំនិតគ្នាក្នុងចំណោមក្រសួង ស្ថាប័នពាក់ព័ន្ធអំពីការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ
- ការលើកកម្ពស់ភាពជាដៃគូរបស់សង្គមស៊ីវិល និងវិស័យឯកជនក្នុងកំណែទម្រង់
- ការពង្រឹងការគ្រប់គ្រងរបស់ស្ថាប័នដោយផ្តោតលើលទ្ធផល
- ការពង្រឹងភាពជាម្ចាស់របស់ក្រសួង ស្ថាប័នអនុវត្តក្នុងការគ្រប់គ្រងកម្មវិធី និងការបញ្ជ្រាបកម្មវិធីក្នុងប្រព័ន្ធរាជរដ្ឋាភិបាលជាបណ្តើរៗដើម្បីលើកកម្ពស់និរន្តរភាពនៃកិច្ចដំណើរការកំណែទម្រង់
- ការធ្វើឱ្យមានលក្ខណៈសាមញ្ញ និងងាយយល់អំពីគោលនយោបាយ លិខិតបទដ្ឋាន ឯកសារបច្ចេកទេស បែបបទ និងនីតិវិធីនានាពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកំណែទម្រង់
- ការផ្សព្វផ្សាយឱ្យមានការយល់ដឹងអំពីចក្ខុវិស័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យបានកាន់តែទូលំទូលាយ
- ការសាកល្បង និងការសិក្សារៀនសូត្រពីបទពិសោធន៍នៃការអនុវត្តកម្មវិធី
- ការរៀបចំគោលការណ៍ និងវិធីសាស្ត្រចាំបាច់នានាសម្រាប់គ្រប់គ្រងការអនុវត្តគម្រោងនានា
- ការធ្វើសុខដុមនីកម្មកម្មវិធីកំណែទម្រង់នានា និងការផ្តល់ការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍។

## គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក

ដើម្បីដោះស្រាយបញ្ហាប្រឈម និងសម្របសម្រួលការងារជាអាទិភាពខាងលើ សមិទ្ធផល និងលទ្ធផលរំពឹងទុកពាក់ព័ន្ធនឹងការគ្រប់គ្រងការងារកំណែទម្រង់បានកំណត់ និងបរិយាយខាងក្រោម។ លទ្ធផលរំពឹងទុកភាគច្រើនមានលក្ខណៈអន្តរវិស័យ និងគាំទ្រដល់លទ្ធផលរំពឹងទុកក្នុងសមាសភាគផ្សេងៗទៀត។

### សមិទ្ធផលរំពឹងទុក ១.១ ៖ ការលើកកម្ពស់និរន្តរភាព និងស្ថាប័នភាវូបនីយកម្មនៃការងារកំណែទម្រង់នានាត្រូវបាននានា

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន៣ដូចខាងក្រោម៖

**លទ្ធផលរំពឹងទុក ១.១.១ ៖ រចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រសួង ស្ថាប័នដែលបានផ្ទេរមុខងារត្រូវបានពិនិត្យ និងកែសម្រួល ដើម្បីធានាដល់ការគាំទ្រ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ។**

***គោលដៅ***

- ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន គុណតម្លៃថវិកា និងសង្គតិភាពជាមួយនឹងចក្ខុវិស័យនៃការធ្វើវិមជ្ឈការ ។

***សកម្មភាពជាចម្បង***

- ការរៀបចំសិក្សា វិភាគផ្នែកស្ថាប័នដើម្បីកំណត់ជម្រើសនានាសម្រាប់ការកែសម្រួលរចនាសម្ព័ន្ធរបស់ស្ថាប័នពាក់ព័ន្ធ
- ការរៀបចំបញ្ចប់ឯកសារយុទ្ធសាស្រ្តស្តីពីការកែសម្រួលរចនាសម្ព័ន្ធអគ្គនាយកដ្ឋានរដ្ឋបាល និងអង្គភាពពាក់ព័ន្ធនានានៃក្រសួងមហាផ្ទៃ រដ្ឋបាលថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋាន គ.ជ.អ.ប
- ការរៀបចំលេខាធិការដ្ឋាន គ.ជ.អ.ប ឱ្យក្លាយជាអង្គភាពថវិកា
- ការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធនៃអគ្គនាយដ្ឋានរដ្ឋបាលនិងអង្គភាពពាក់ព័ន្ធនានានៃក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប
- ការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ននីមួយៗដែលបានផ្ទេរមុខងារ រួមទាំងមន្ទីរ អង្គភាពជំនាញរបស់ខ្លួននៅពេលដែលមុខងារត្រូវបានផ្ទេរ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលបានផ្ទេរមុខងារដែលផ្ទេរឱ្យ
- ការពិនិត្យ និងកែសម្រួលប្រព័ន្ធអធិការកិច្ចទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការសិក្សាបទពិសោធន៍ពីបណ្តាប្រទេសនានាពាក់ព័ន្ធនឹងអាណត្តិ មុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យមើលពីលើរដ្ឋបាលមូលដ្ឋាន និងលើកអនុសាសន៍នានាជូនរាជរដ្ឋាភិបាលអំពីបែបផែននានាដែលសមស្របសម្រាប់កម្ពុជា។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនការសិក្សាវិភាគផ្នែកស្ថាប័នដែលបានបញ្ចប់ | ១ | ២ | ៣ |
| ចំនួនស្ថាប័នបានកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួន | | ក្រសួងចំនួន១ (មហាផ្ទៃ) | ក្រសួងចំនួន ៣ និងខេត្ត |
| លេខាធិការដ្ឋាន គ.ជ.អ.ប. ក្លាយជាអង្គភាពថវិកា | | បានអនុវត្ត | |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ច

សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

## លទ្ធផលរំពឹងទុក ១.១.២ ៖ កម្មវិធីជាតិដំណាក់កាលបន្ទាប់ត្រូវបានរៀបចំតាក់តែង និងអនុម័ត

***គោលដៅ***

- ការរៀបចំតាក់តែង និងអនុម័តកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលបន្ទាប់ តាមរយៈកិច្ចដំណើរការដែលមានការចូលរួម និងដោយផ្អែកលើទិន្នន័យ និងភស្តុតាងច្បាស់លាស់។

***សកម្មភាពជាចម្បង***

- ការវាយតម្លៃចុងបញ្ចប់នៃការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ការរៀបចំឯកសារទស្សនទានសម្រាប់ការរៀបចំតាក់តែងកម្មវិធីជាតិដំណាក់កាលបន្ទាប់
- ការរៀបចំកិច្ចប្រជុំ និងការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាអំពីលទ្ធផលនៃការវាយតម្លៃកម្មវិធីជាតិ និងឯកសារទស្សនទានសម្រាប់ការរៀបចំតាក់តែងកម្មវិធីជាតិដំណាក់កាលបន្ទាប់
- ការរៀបចំតាក់តែងកម្មវិធីជាតិដំណាក់កាលបន្ទាប់ តាមរយៈកិច្ចដំណើរការដែលមានការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា
- ការរៀបចំផែនការអនុវត្តដំណាក់កាលទី១នៃកម្មវិធីជាតិដំណាក់កាលបន្ទាប់។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ការរៀបចំកម្មវិធីជាតិដំណាក់កាលបន្ទាប់ | | ការបញ្ចប់ការសិក្សាការវិភាគ | ការរៀបចំ និងអនុម័ត (ត្រីមាសទី២) |
| ការរៀបចំផែនការអនុវត្តដំណាក់កាលទី១នៃកម្មវិធីជាតិដំណាក់កាលបន្ទាប់ | | | ការរៀបចំបញ្ចប់ និងអនុម័ត (ត្រីមាសទី៣) |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប ដោយមានការសហការពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា។

## លទ្ធផលរំពឹងទុក ១.១.៣ ៖ យុទ្ធសាស្ត្រស្តីពីនិរន្តរភាពផ្នែកហិរញ្ញវត្ថុនៃកម្មវិធីត្រូវបានអនុវត្ត

***គោលដៅ***

- ការធានាឱ្យកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមាននិរន្តរភាព ដោយ

កាត់បន្ថយជាបណ្តើរៗនូវការពឹងផ្អែកទៅលើហិរញ្ញប្បទានគាំទ្រពីខាងក្រៅ និងការបង្កើនគុណតម្លៃនៃថវិកាក្នុងការអនុវត្តកម្មវិធី។

***សកម្មភាពចម្បង***

- ការប្រើប្រាស់ការចំណាយលើជំនួយបច្ចេកទេស និងប្រតិបត្តិការរបស់កម្មវិធីឱ្យបានសមស្រប និងការបង្កើនការប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការចំណាយទៅលើបុគ្គលិកកិច្ចសន្យា និងការចំណាយលើផ្នែកប្រតិបត្តិការក្នុងការអនុវត្តកម្មវិធី
- ការបង្កើនការប្រើប្រាស់ថវិការបស់ក្រសួង ស្ថាប័នសម្រាប់កិច្ចដំណើរការផ្ទេរមុខងារ
- ការតម្រឹមការប្រើប្រាស់ជំនួយបច្ចេកទេស និងការចំណាយផ្នែកកិច្ចប្រតិបត្តិការរបស់គម្រោងដាច់ដោយឡែកនានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ឱ្យឆ្លើយតបទៅនឹងយុទ្ធសាស្ត្រស្តីពីនិរន្តរភាពហិរញ្ញវត្ថុនៃកម្មវិធី
- ការរៀបចំផែនការនិរន្តរភាពថវិកាសម្រាប់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនថវិការបស់រាជរដ្ឋាភិបាលដែលផ្តល់សម្រាប់ចំណាយលើប្រតិបត្តិការនៃកិច្ចដំណើរការកំណែទម្រង់ (គិតជាលានដុល្លា) | ១ | ១,២៥ | ១,៥០ |
| ចំនួនថវិកាគាំទ្រដោយដៃគូអភិវឌ្ឍន៍សម្រាប់ជំនួយបច្ចេកទេស (គិតជាលានដុល្លា) | ៤ | ៣,៥០ | ៣ |
| ចំនួនថវិកាគាំទ្រដោយដៃគូអភិវឌ្ឍន៍សម្រាប់ចំណាយផ្នែកប្រតិបត្តិការនៃផអ៣ទី៣ | ២ | ១,៨០ | ១,៦០ |
| ភាគរយនៃការចំណាយរបស់សមាគមក្រុមប្រឹក្សាទទួលបានពីកម្រៃសមាជិក និងពីរដ្ឋបាលថ្នាក់ក្រោមជាតិនានា | ១០% | ២០% | ២០% |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប ស្ថាប័នអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ។

## សមិទ្ធផលរំពឹងទុក ១.២ ៖ ភាពជាម្ចាស់ និងការគាំទ្រដល់កំណែទម្រង់ត្រូវបានពង្រឹងយ៉ាងទូលំទូលាយ

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន៤ដូចខាងក្រោម៖

### លទ្ធផលរំពឹងទុក ១.២.១ ៖ បរិយាកាសសមស្របត្រូវបានបង្កើតឡើងសម្រាប់ការពិភាក្សាផ្ទៃក្នុងរាជរដ្ឋាភិបាលឱ្យកាន់តែស៊ីជម្រៅអំពីកំណែទម្រង់វិមជ្ឈការ

### គោលដៅ

- ការលើកកម្ពស់ភាពជាម្ចាស់ និងការចូលរួមក្នុងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ការកំណត់ និងដំណោះស្រាយបញ្ហាប្រឈមនានា តាមរយៈកិច្ចដំណើរការដោយមានការចូលរួម និងប្រកបដោយតម្លាភាព
- ការពង្រឹងការគ្រប់គ្រងរបស់ គ.ជ.អ.ប ក្នុងការរៀបចំ និងការអនុវត្តគោលនយោបាយនៃកំណែទម្រង់ប្រកបដោយគណនេយ្យភាព។

### សកម្មភាពជាចម្បង

- ការរៀបចំកិច្ចប្រជុំចំនួន៣ក្នុង១ឆ្នាំៗ ដើម្បីពិភាក្សាអំពីបញ្ហាប្រឈម និងដំណោះស្រាយក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ រួមមាន ៖
  ១. កិច្ចប្រជុំជាមួយមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញសំខាន់ៗរបស់ក្រសួង ស្ថាប័ន
  ២. កិច្ចប្រជុំជាមួយថ្នាក់ដឹកនាំរដ្ឋបាលរាជធានី ខេត្ត និង
  ៣. កិច្ចប្រជុំជាមួយថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ខណ្ឌ។
- ការរៀបចំកិច្ចប្រជុំពិភាក្សារបស់ គ.ជ.អ.ប យ៉ាងតិច១ដងក្នុង១ឆ្នាំ លើបញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងផ្នែកនយោបាយ រដ្ឋបាល ហិរញ្ញវត្ថុ និងការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមដែលមានផលប៉ះពាល់ដល់វឌ្ឍនភាពនៃកំណែទម្រង់។
- ការរៀបចំក្រុមការងារ ដែលមានសមាសភាពពីលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងគោលនយោបាយតាមការណែនាំ និងការតម្រង់ទិសរបស់ គ.ជ.អ.ប.។ ជាមួយគ្នាដែរ ត្រូវធ្វើការសិក្សារួមគ្នា ដើម្បីរិះរក និងលើកឡើងនូវជម្រើស និងដំណោះស្រាយនានា ក្នុងករណីចាំបាច់ត្រូវរៀបចំ និងអនុវត្តសាកល្បងនូវជម្រើស និងដំណោះស្រាយទាំងនោះ។
- ការរៀបចំកិច្ចប្រជុំ គ.ជ.អ.ប យ៉ាងតិច១ដងក្នុង១ឆ្នាំ ដើម្បីពិនិត្យ និងពិភាក្សាទៅលើរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធីកំណែទម្រង់។

### ចំណុចដៅ

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនកិច្ចប្រជុំប្រចាំឆ្នាំពាក់ព័ន្ធកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដោយមានការចូលរួមពីអ្នកពាក់ព័ន្ធយ៉ាងតិច៨០% | ៣ | ៣ | ៣ |
| ចំនួនកិច្ចប្រជុំរបស់ គ.ប.អ.ជ. ដែលបានពិភាក្សាលើបញ្ហាប្រឈមផ្នែកនយោបាយ រដ្ឋបាល ហិរញ្ញវត្ថុ និងការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមដែលមានផលប៉ះពាល់ដល់វឌ្ឍនភាពនៃកំណែទម្រង់ | ២ | ២ | ២ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

- លេខាធិការដ្ឋាន គ.ជ.អ.ប. រៀបចំចងក្រងរាល់ធាតុចូលសំខាន់ៗសម្រាប់កិច្ចប្រជុំ គ.ជ.អ.ប និងកិច្ចប្រជុំប្រចាំឆ្នាំនានា
- គ.ជ.អ.ប ប្រជុំពិភាក្សាដើម្បីសម្របសម្រួល និងសម្រេចដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងកំណែទម្រង់

**លទ្ធផលរំពឹងទុក ១.២.២ ៖ យុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានត្រូវបានអនុវត្តដោយផ្ដោតជាសំខាន់លើការផ្លាស់ប្ដូរឥរិយាបថ និងការបង្កើនការយល់ដឹងអំពីកំណែទម្រង់នានា**

***គោលដៅ***

- ការបង្កើនការយល់ដឹង ការផ្លាស់ប្ដូរអកប្បកិរិយានិងឥរិយាបថ ព្រមទាំងការកសាងទំនុកចិត្តក្រុមគោលដៅ និងអ្នកពាក់ព័ន្ធនានា ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងសមិទ្ធផលរំពឹងទុករបស់ផអ៣ទី៣។

***សកម្មភាពចម្បង***

- ការអនុវត្តគម្រោងសកម្មភាពយ៉ាងតិចចំនួនមួយអំពីយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនិងការផ្សព្វផ្សាយព័ត៌មានជារៀងរាល់ឆ្នាំ ក្នុងគោលបំណងផ្លាស់ប្ដូរឥរិយាបថរបស់ក្រុមគោលដៅ និងអ្នកពាក់ព័ន្ធនានា ដែលបានរៀបចំផ្អែកលើការយល់ដឹងអំពីស្ថានភាពនៃក្រុមគោលដៅនីមួយៗ និងតាមរយៈការធ្វើតេស្តសារអប់រំផ្សព្វផ្សាយទាំងនោះ
- ការបញ្ចូលសារអប់រំផ្សព្វផ្សាយព័ត៌មានអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅក្នុងសកម្មភាពនៃការអភិវឌ្ឍសមត្ថភាពឱ្យបានចំនួន៣ដងក្នុងមួយឆ្នាំ ដល់អ្នកចូលរួមយ៉ាងតិចចំនួន២.០០០នាក់ ដើម្បីបន្តផ្សព្វផ្សាយឱ្យមានការយល់ដឹងកាន់តែទូលំទូលាយអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពង្រឹងបណ្ដាញព័ត៌មានសង្គមរបស់ គ.ជ.អ.ប. និងបន្តធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់ គ.ជ.អ.ប ជាប្រចាំ
- ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ដើម្បីបង្កើនការយល់ដឹងជាសាធារណៈអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចជា ការរៀបចំសន្និសីទសារព័ត៌មាន សេចក្ដីប្រកាសព័ត៌មាន អត្ថបទតាមកាសែត កម្មវិធីតាមទូរទស្សន៍ និងវិទ្យុជាដើម
- ការរៀបចំឯកសារព័ត៌មានអំពីការទទួលខុសត្រូវសំខាន់ៗក្នុងការគ្រប់គ្រង និងអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈសាមញ្ញ ខ្លី និងងាយយល់
- ការអនុវត្តគម្រោងសកម្មភាពជាគន្លឹះផ្សេងៗទៀត ដូចមានចែងនៅក្នុងយុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មានរបស់ គ.ជ.អ.ប.។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ជារៀងរាល់ឆ្នាំ ត្រូវអនុវត្តគម្រោងសកម្មភាពផ្សព្វផ្សាយព័ត៌មានដើម្បីផ្លាស់ប្តូរឥរិយាបថយ៉ាងតិចចំនួន១ កម្មវិធីទូរទស្សន៍ចំនួន១ សន្និសីទសារព័ត៌មានចំនួន២ សេចក្តីប្រកាសព័ត៌មានចំនួន៣ និងសកម្មភាពនៃការអភិវឌ្ឍន៍សមត្ថភាពចំនួន៣ ដែលមានអ្នកចូលរួមចំនួន២.០០០នាក់ | បញ្ចប់ | បញ្ចប់ | បញ្ចប់ |
| ចំនួនលទ្ធផលរំពឹងទុករបស់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលបានអនុវត្តដែលមានការគាំទ្រពីសកម្មភាពនៃការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន | ៥ | ៥ | ៥ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

- លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការដឹកនាំអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន។
- អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធត្រូវចូលរួមអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន។

**លទ្ធផលរំពឹងទុក ១.២.៣ ៖ កម្មវិធីសាកល្បងនូវយន្តការនានានៃកំណែទម្រង់វិមជ្ឈការ និងកម្មវិធីសិក្សារៀនសូត្រពីមេរៀនបទពិសោធន៍ល្អៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត ដើម្បីបង្ហាញឱ្យឃើញពីលទ្ធផល និងធ្វើជាមូលដ្ឋានក្នុងការរៀបចំកែលម្អគោលនយោបាយ និងសេចក្តីសម្រេចនានា**

***គោលដៅ***

- លទ្ធផលល្អៗនៃការអនុវត្តកម្មវិធីសាកល្បងនានាត្រូវបានយកទៅអនុវត្តយ៉ាងទូលំទូលាយដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្តល់ជាធាតុចូលសម្រាប់ការកែលម្អនូវគោលនយោបាយ និងនីតិវិធីនានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

***សកម្មភាពជាចម្បង***

- ការរៀបចំសេចក្តីណែនាំ បែបបទ នីតិវិធីនានាក្នុងការរៀបចំ និងការអនុវត្តកម្មវិធីសាកល្បង
- ការអនុវត្តកម្មវិធីសាកល្បង និងការប្រើប្រាស់លទ្ធផលនៃការសាកល្បងនេះសម្រាប់ធ្វើជាមូលដ្ឋានក្នុងការរៀបចំ ឬកែសម្រួលគោលនយោបាយ និងសេចក្តីសម្រេចនានា
- ការកែសម្រួលតួនាទីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការសម្របសម្រួលផ្នែកគោលនយោបាយ និងកិច្ចដំណើរការនានា ដើម្បីធានាដល់ការលើកកម្ពស់ដល់ការរៀបចំគោលនយោបាយ ដោយមានការវិភាគ ការជជែកពិភាក្សា ការចូលរួម និងការដាក់បញ្ចូលនូវបញ្ហាបរិយាប័ន្ន និងសមធម៌សង្គម
- ការរៀបចំ និងអនុវត្តកម្មវិធីរៀនសូត្រពីមេរៀនបទពិសោធន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ការរៀបចំវេទិកាពិគ្រោះយោបល់ស្តីពីគោលនយោបាយប្រចាំឆ្នាំ ដោយប្រើប្រាស់ធាតុចូលពីការអនុវត្តកម្មវិធីសាកល្បង ការអនុវត្តកម្មវិធីសិក្សារៀនសូត្រមេរៀនបទពិសោធន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិលពាក់ព័ន្ធ ព្រមទាំងឯកសារគោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា
- ការផ្សព្វផ្សាយ និងការពង្រីកការអនុវត្តនូវលទ្ធផលជាវិជ្ជមាននានា ដែលទទួលបានពីការអនុវត្តសាកល្បង និងកម្មវិធីរៀនសូត្រមេរៀនបទពិសោធន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនកម្មវិធីសាកល្បងដែលបានអនុវត្ត និងបានបង្ហាញក្នុងវេទិកាពិគ្រោះយោបល់ស្តីពីគោលនយោបាយប្រចាំឆ្នាំ | ២ | ៣ | ៣ |
| ចំនួនកម្មវិធីសាកល្បងដែលឈានទៅដល់ការទទួលយកមកកែសម្រួលលិខិតគោលនយោបាយ និងលិខិតបទដ្ឋាន | ១ | ១ | ២ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

- លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការដឹកនាំការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា។

### លទ្ធផលរំពឹងទុក ១.២.៤ ៖ តួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់យោបល់ត្រឡប់ត្រូវបានពង្រឹង

***គោលដៅ***

សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិរួមចំណែកធ្វើឱ្យមានកែសម្រួលគោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការប្រកបដោយប្រសិទ្ធភាព ។

***សកម្មភាពជាចម្បង***

- ការផ្តល់យោបល់ត្រឡប់នានាដើម្បីបង្កើនចំនួនសមាជិកក្រុមប្រឹក្សាជាស្ត្រីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំវេទិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាក្រុង ស្រុក នីមួយៗជាមួយគណៈអភិបាល តំណាងការិយាល័យជំនាញ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអង្គការសង្គមស៊ីវិលផងដែរ
- ការរៀបចំជាឯកសារគោលនយោបាយយ៉ាងតិចចំនួន១រៀងរាល់ឆ្នាំ ផ្អែកលើបញ្ហាប្រឈមដែលបានកំណត់ក្នុងវេទិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ដើម្បីយកទៅបង្ហាញនៅវេទិកាពិគ្រោះយោបល់គោលនយោបាយប្រចាំឆ្នាំ
- ការរៀបចំយុទ្ធនាការស្តីពីការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានយ៉ាងតិចចំនួន១

ដងក្នុងមួយឆ្នាំពាក់ព័ន្ធនឹងការផ្តល់យោបល់ទៅលើកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

- ការរៀបចំ និងអនុវត្តបញ្ចប់នូវការសិក្សាវាយតម្លៃអំពីជម្រើសនានាដើម្បីកំណត់អំពីឋានៈផ្លូវច្បាប់របស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដែលគប្បីជាតំណាងឱ្យតែក្រុមប្រឹក្សា ឬក៏តំណាងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| សមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិបានធ្វើបទបង្ហាញឯកសារគោលនយោបាយយ៉ាងតិចចំនួន១ | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត |
| ការអនុវត្តយុទ្ធនាការនៃការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានយ៉ាងតិចចំនួន១ក្នុង១ឆ្នាំ | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

- អគ្គលេខាធិការនៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការសម្របសម្រួលការអនុវត្តលទ្ធផលរំពឹងទុកនេះ

## សមិទ្ធផលរំពឹងទុក ១.៣ ៖ សង្គមស៊ីវិល និងផ្នែកឯកជនក្លាយជាដៃគូជាមួយរដ្ឋាភិបាលក្នុងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរពឹងទុកចំនួន១ដូចខាងក្រោម ៖

### លទ្ធផលរំពឹងទុក ១.៣.១ ៖ ផែនការនៃកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូត្រូវបានរៀបចំ និងអនុវត្ត

***គោលដៅ***

- ការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការចូលរួមរបស់ប្រជាពលរដ្ឋ ការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព បរិយាប័ន្ននិងសមធម៌សង្គម ការប្រាស្រ័យទាក់ទងនិងការផ្សព្វផ្សាយព័ត៌មាន ការរៀបចំគោលនយោបាយ និងការផ្តល់យោបល់អំពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ តាមរយៈកិច្ចសហការក្នុងភាពជាដៃគូជាមួយសង្គមស៊ីវិល និងវិស័យឯកជនប្រកបដោយការស្ថាបនា។

***សកម្មភាពជាចម្បង***

- ការកំណត់អំពីវិស័យសំខាន់ៗសម្រាប់កិច្ចសហការប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិលនានា និងវិស័យឯកជន
- ការរៀបចំផែនការសកម្មភាពនិងថវិការួមគ្នាមួយសម្រាប់កិច្ចសហប្រតិបត្តិការជាមួយសង្គម

ស៊ីវិល និងវិស័យឯកជន រួមបញ្ចូលទាំងការកំណត់នូវប្រភពធនធានហិរញ្ញវត្ថុនានា។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| កម្មវិធីនានាសម្រាប់ភាពជាដៃគូជាមួយសង្គមស៊ីវិល និងវិស័យឯកជន ត្រូវបានរៀបចំ និងផ្តល់ហិរញ្ញប្បទានសម្រាប់ការអនុវត្ត | បានរៀបចំ | បានផ្តល់ហិរញ្ញប្បទាន | បានអនុវត្ត |
| ចំនួនលទ្ធផលរំពឹងទុកនៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលសង្គមស៊ីវិល និងវិស័យឯកជនបានចូលរួមអនុវត្ត | ៥ | ៧ | ១០ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ។

## សមិទ្ធផលរំពឹងទុក ១.៤ ៖ ផអពទី៣ត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន៣ដូចខាងក្រោម៖

### លទ្ធផលរំពឹងទុក ១.៤.១ ៖ កិច្ចដំណើរការគ្រប់គ្រងគម្រោង និងកិច្ចការដទៃទៀតៗ ព្រមទាំងការលើកកម្ពស់ការរៀបចំផែនការ ការត្រួតពិនិត្យនិងវាយតម្លៃ និងការគ្រប់គ្រងផ្អែកលើលទ្ធផលត្រូវបានអនុវត្ត

***គោលដៅ***

- ការពង្រឹងប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងលទ្ធផលរំពឹងទុកនៃផអពទី៣។

***សកម្មភាពជាចម្បង***

- ការរៀបចំឯកសារគម្រោងសម្រាប់លទ្ធផលរំពឹងទុកសំខាន់ៗ និងការគ្រប់គ្រងផអពទី៣ ដោយប្រើប្រាស់តារាងម៉ាទ្រីកសម្រាប់ការគ្រប់គ្រងគម្រោង និងដោយមានការចាត់តាំងមន្ត្រីទទួលបន្ទុកគម្រោងនីមួយៗឱ្យបានច្បាស់លាស់
- ការកែសម្រួលកិច្ចដំណើរការនៃការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំឱ្យមានភាពសមស្របជាមួយនឹងគោលការណ៍នៃការគ្រប់គ្រងគម្រោង
- ការគ្រប់គ្រងក្របខ័ណ្ឌលទ្ធផលនៃផអពទី៣ រួមបញ្ចូលទាំងការកែសម្រួលប្រព័ន្ធទិន្នន័យគ្រប់គ្រងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ការសិក្សាវាយតម្លៃអំពីគុណភាព និងរៀបចំគោលការណ៍ណែនាំសម្រាប់ការផ្សព្វផ្សាយទិន្នន័យ និងលទ្ធផលនៃការវាយតម្លៃនានា
- ការអភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកអនុវត្តគម្រោងអំពីបែបផែននៃការគ្រប់គ្រងគម្រោង រួមមានដូចជា ការរៀបចំតាក់តែង និងការត្រួតពិនិត្យវាយតម្លៃគម្រោង ព្រមទាំងការប្រើប្រាស់

តារាងម៉ាទ្រីកសម្រាប់ការគ្រប់គ្រងគម្រោងដែលពាក់ព័ន្ធនឹងការសាកល្បង ការចូលរួមរបស់សង្គមស៊ីវិល ការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន។ល។

- ការកែសម្រួលឡើងវិញនូវការវិភាជធនធានពីកម្មវិធីសម្រាប់គាំទ្រដល់ក្រុមអន្តរាគមន៍នានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| %នៃឯកសារគម្រោងនៃលទ្ធផលរំពឹងទុកសំខាន់ៗរបស់ផអ៣ទី៣ ដែលបានរៀបចំ និងអនុម័ត | ៦០% | ១០០% | |
| %នៃទិន្នន័យនៃសូចនាករលទ្ធផលរំពឹងទុកក្នុងផអ៣ទី៣ ដែលបានប្រមូលចងក្រង | ៩០% | ៩០% | ៩០% |
| %នៃចំណុចដៅនៃផអ៣ទី៣ដែលបានសម្រេច | ៥០% | ៦០% | ៧០% |
| %នៃចំណុចដៅនៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដែលបានសម្រេច | ៨០% | ៨០% | ៨០% |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងផ្ទៃរមុខងារនានា។

**លទ្ធផលរំពឹងទុក ១.៤.២ ៖ គម្រោងនានារបស់ដៃគូអភិវឌ្ឍន៍ត្រូវធ្វើសុខដុមនីយកម្ម និងកម្មវិធីកំណែទម្រង់នានារបស់រដ្ឋត្រូវបានធ្វើឱ្យមានសង្គតិភាពគ្នា ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការនានា**

***គោលដៅ***

- ការកាត់បន្ថយនូវភាពត្រួតជាន់គ្នានៃគម្រោងនានា ការធ្វើឱ្យកាន់តែមានសុខដុមនីយកម្មរវាងគម្រោងនានា ការកាត់បន្ថយនូវចំណាយប្រតិបត្តិការ និងការលើកកម្ពស់ការអនុវត្តគម្រោងទាំងនោះ។

***សកម្មភាពជាចម្បង***

- ការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រនានាដើម្បីបន្សីគម្រោងដាច់ដោយឡែកនានាជាមួយនឹងផអ៣ទី៣
- ការរៀបចំ និងអនុវត្តនូវការសិក្សាវិភាគឯករាជ្យដើម្បីអំពីកំណត់អំពីនីតិវិធី និងបែបផែនអភិបាលកិច្ចដែលមានលក្ខណៈខុសៗគ្នារបស់គម្រោងដៃគូអភិវឌ្ឍន៍នានា ដោយធ្វើការប៉ាន់ស្មានអំពីគុណតម្លៃគម្រោងទាំងនោះចំពោះផអ៣ទី៣ និងបង្ហាញលទ្ធផលនៃការសិក្សាវិភាគនេះជូនកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- ការពិនិត្យ ការកែសម្រួលឡើងវិញ ការរៀបចំកិច្ចប្រជុំ និងការអនុវត្តសកម្មភាពរួមគ្នាដទៃទៀតរបស់លេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់ទាំង៣ ដើម្បីធ្វើសុខដុមនីយកម្មនៃកិច្ចដំណើរការកំណែទម្រង់ទាំង៣
- ការរៀបចំឱ្យមានភាពសមស្របនូវការគ្រប់គ្រងហិរញ្ញវត្ថុ ការអនុវត្ត និងអភិបាលកិច្ចរបស់គម្រោងដៃគូអភិវឌ្ឍន៍នានា ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ ចែករំលែកបទពិសោធន៍ និងបង្កឱ្យមានភាពស៊ីសង្វាក់គ្នាក្នុងការអនុវត្ត។
- ការរៀបចំវេទិកាប្រចាំឆ្នាំជាមួយគម្រោងដាច់ដោយឡែកទាំងអស់ ដើម្បីផ្លាស់ប្តូរមេរៀនបទពិសោធន៍ទាក់ទងនឹងការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមដែលនាំឱ្យមានការផ្លាស់ប្តូរ ឬកែសម្រួលសកម្មភាពនានារបស់គម្រោង។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ការសិក្សាឯករាជ្យដើម្បីធ្វើសុខដុមនីយកម្មគម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍ត្រូវបានអនុម័តដោយក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | អនុម័ត | | |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប ទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ។

### លទ្ធផលរំពឹងទុក ១.៤.៣ ៖ ការចាត់ចែងផ្នែកហិរញ្ញវត្ថុ និងការគាំទ្រផ្នែករដ្ឋបាលត្រូវបានផ្តល់ជាប្រចាំដល់ស្ថាប័នអនុវត្ត ផអពទី៣នានា

***គោលដៅ***

- ការអនុវត្តផអពទី៣កាន់តែមានប្រសិទ្ធផល តាមរយៈការផ្តល់សេវាគាំទ្រផ្នែករដ្ឋបាល និងហិរញ្ញវត្ថុដែលឆ្លើយតបទៅនឹងតម្រូវការរបស់ស្ថាប័នអនុវត្តនានា។

***សកម្មភាពជាចម្បង***

- ការរៀបចំកិច្ចដំណើរការគ្រប់គ្រងសំខាន់ៗនានា រួមមាន ការរៀបចំផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ ការបញ្ជាបយេនឌ័រ និងការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌចាំបាច់នានារបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍
- ការពិនិត្យកែសម្រួល អនុម័ត និងដាក់ឱ្យអនុវត្តនូវសៀវភៅណែនាំនានាស្តីពីកិច្ចប្រតិបត្តិការរបស់ គ.ជ.អ.ប.
- ការផ្តល់ថវិកាប្រតិបត្តិការបន្ថែមដល់ស្ថាប័នអនុវត្តសំខាន់ៗនានា
- ការអនុវត្តនូវរាល់កិច្ចការគ្រប់គ្រងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ រួមបញ្ចូលទាំងកិច្ចការសវនកម្មផ្ទៃក្នុង និងសវនកម្មពីខាងក្រៅ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនហានិភ័យកម្រិតខ្ពស់ និងមធ្យមដែលបានរកឃើញដោយសវនកម្មពីខាងក្រៅទៅលើប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ | ១១ | ៧ | ៥ |

# ឃ. គម្រោងថវិកាប៉ាន់ស្មាន

ថវិកាប៉ាន់ស្មានសម្រាប់ការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗនៃសមាសភាគនេះ រួមមានដូចខាងក្រោម ៖

**តារាងទី៦ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់សមាសភាគទី១ (គិតដុល្លារអាមេរិក)**

| លទ្ធផលរំពឹងទុក | ថវិកា (គិតជាដុល្លា) | | | |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | សរុប |
| ១.១.១. រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គបរដ្ឋបាលរាជធានី .អ.ជ. ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រសួង ស្ថាប័នដែលបានផ្ទេរមុខងារត្រូវបានពិនិត្យ និងកែសម្រួល ដើម្បីជានាដល់ការគាំទ្រ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ | 161,200 | 209,600 | 348,200 | **719,000** |
| ១.១.២. កម្មវិធីជាតិដំណាក់កាលបន្ទាប់ត្រូវបានរៀបចំកាត់តែង និងអនុម័ត | 0 | 99,000 | 236,500 | **335,500** |
| ១.១.៣. យុទ្ធសាស្ត្រស្តីពីនិរន្តរភាពផ្នែកហិរញ្ញវត្ថុនៃកម្មវិធីត្រូវបានអនុវត្ត | 50,000 | 100,000 | 50,000 | **200,000** |
| ១.២.១. បរិយាកាសសមស្របត្រូវបានបង្កើតឡើងសម្រាប់ការពិភាក្សាផ្ទៃក្នុងរាជរដ្ឋាភិបាលឱ្យកាន់តែស៊ីជម្រៅអំពីកំណែទម្រង់វិមជ្ឈការ | 489,900 | 489,900 | 489,900 | **1,469,700** |
| ១.២.២. យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានត្រូវបានអនុវត្តដោយ ផ្តោតជាសំខាន់លើការផ្លាស់ប្តូរឥរិយាបថ និងការបង្កើនការយល់ដឹងអំពីកំណែទម្រង់នានា | 328,100 | 446,250 | 523,200 | **1,297,550** |
| ១.២.៣. កម្មវិធីសាកល្បងនូវយន្តការនានានៃកំណែទម្រង់វិមជ្ឈការ និងកម្មវិធីសិក្សារៀនសូត្រពីមេរៀនបទពិសោធន៍ល្អៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត ដើម្បីបង្ហាញឱ្យឃើញពីលទ្ធផល និងដើម្បីជាមូលដ្ឋានក្នុងការរៀបចំកែលម្អគោលនយោបាយ និងសេចក្តីសម្រេចនានា | 2,524,800 | 153,500 | 153,500 | **2,831,800** |
| ១.២.៤. តួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់យោបល់ត្រឡប់ត្រូវបានពង្រឹង | 416,596 | 389,096 | 289,096 | **1,094,788** |
| ១.៣.១. បែបផែននៃកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូត្រូវ | 135,900 | 135,900 | 66,600 | **338,400** |

| លទ្ធផលរំពឹងទុក | ថវិកា (គិតជាដុល្លា) | | | |
| --- | --- | --- | --- | --- |
| | ២០១៨ | ២០១៩ | ២០២០ | សរុប |
| បានរៀបចំ និងអនុវត្ត | | | | |
| ១.៤.១. កិច្ចដំណើរការគ្រប់គ្រងគម្រោង និងកិច្ចការដទៃទៀតៗ ព្រមទាំងការលើកកម្ពស់ការរៀបចំផែនការ ការត្រួតពិនិត្យនិងវាយតម្លៃ និងការគ្រប់គ្រងផ្អែកលើលទ្ធផលត្រូវបានអនុវត្ត | 491,820 | 665,520 | 534,420 | **1,691,760** |
| ១.៤.២. គម្រោងនានារបស់ដៃគូអភិវឌ្ឍន៍ត្រូវធ្វើសុខដុមនីយកម្ម និងកម្មវិធីកំណែទម្រង់នានារបស់រដ្ឋត្រូវបានធ្វើឱ្យមានសង្គតិភាពគ្នា ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការនានា | 78,700 | 33,000 | 16,500 | **128,200** |
| ១.៤.៣. ការចាត់ចែងផ្នែកហិរញ្ញវត្ថុនិងការគាំទ្រផ្នែករដ្ឋបាលត្រូវបានផ្តល់ជាប្រចាំដល់ស្ថាប័ន អនុវត្ត ផអពទីពនានា | 1,100,680 | 1,208,980 | 1,299,380 | **3,609,040** |
| **សរុប** | **5,777,696** | **3,930,746** | **4,007,296** | **13,715,738** |

## ខ. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ

ហានិភ័យសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងការងារកំណែទម្រង់ និងវិធានការកាត់បន្ថយហានិភ័យទាំងនោះត្រូវបានកំណត់ដូចមានបរិយាយក្នុងតារាងខាងក្រោម ៖

### តារាងទី៧៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគទី១

| ល.រ | ហានិភ័យ | កម្រិត | វិធានការកាត់បន្ថយហានិភ័យ |
| --- | --- | --- | --- |
| ១. | ការពុំទាន់ស្រុះស្រួលមូលគំនិតគ្នាអំពីគោលនយោបាយ | មធ្យម | ➢ ការរៀបចំឱ្យមានកិច្ចពិភាក្សាកម្រិតនយោបាយដើម្បីធ្វើឱ្យមានការឯកភាពគ្នាទៅលើបញ្ហាសំខាន់នានា និងការអនុវត្តសាកល្បងនូវសេចក្តីសម្រេចចិត្តដែលបានឯកភាពគ្នាក្នុងកម្រិតនយោបាយនោះ<br>➢ ការប្រើប្រាស់ធនធានរបស់ផអពទីព ដើម្បីអនុវត្តនូវសកម្មភាពនានាដែលពុំមានបញ្ហាប្រទាំងប្រទើសគ្នា ដូចជាការអនុវត្តមុខងារជាអាណត្តិទូទៅ ការងារគណនេយ្យភាពសង្គម និងការិយាល័យច្រកចេញចូលតែមួយជាដើម។ |
| ២. | ការថយចុះស័ក្តិសិទ្ធិភាពនៃកំណែទម្រង់ដោយសារការពន្យារការអនុវត្ត | មធ្យម | ➢ ការបន្តពង្រឹងតួនាទីរបស់លេខាធិការ ដ្ឋាន គ.ជ.អ.ប. ក្នុងដំណាក់កាលនៃផអពទីពក្នុងការគ្រប់គ្រងផ្អែកលើលទ្ធផល ដែលត្រូវធានាថាលទ្ធផលរំពឹងទុកនានាត្រូវបានសម្រេចដោយឆាប់រហ័ស និងមានគុណភាព។<br>➢ ការរៀបចំ និងអនុវត្តប្រព័ន្ធលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់ការបំពេញការងាររបស់បុគ្គលិកផ្អែកលើលទ្ធផលដែលសម្រេចបាន។ |

| ល.រ | ហានិភ័យ | កម្រិត | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|
| ៣. | ធនធានសម្រាប់ការអនុវត្តកម្មវិធីមានចំនួនមិនគ្រប់គ្រាន់សមស្រប | មធ្យម | ➢ ការសន្យាផ្តល់ហរិញ្ញប្បទានពីដៃគូនានាទៅក្នុងថវិកាកញ្ចប់រួម គប្បីមានភាពច្បាស់លាស់ និងមានចំនួនគ្រប់គ្រាន់<br>➢ ការកំណត់វិធានការជាក់លាក់នានាដើម្បីធានាថា គម្រោងដាច់ដោយឡែកនានាបានចូលរួមសម្រេចនូវគោលបំណង និងសមិទ្ធផលនានារបស់ផអ៣ទី៣ និងបង្កើនគុណតម្លៃនៃថវិកា។<br>➢ ការកៀរគរការចូលរួម ចំណេះដឹង និងធនធាននានាពីអង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។ |

# សមាសភាគទី ២
# អភិបាលកិច្ចល្អ

## ក. សេចក្តីផ្តើម

អភិបាលកិច្ចល្អ គឺជាកិច្ចដំណើរការនៃការអនុវត្តសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រងការងាររបស់ស្ថាប័នរដ្ឋ ឬស្ថាប័នឯកជន ឬអង្គការសង្គមស៊ីវិលនានា ដោយផ្អែកលើគោលការណ៍សំខាន់ៗជាទូទៅនៃអភិបាលកិច្ចល្អ រួមមានដូចជា ការចូលរួម គណនេយ្យភាព តម្លាភាព ការឆ្លើយតប នីតិរដ្ឋ សមធម៌និងបរិយាប័ន្នសង្គម ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព ជាដើម។ ក្នុងន័យនេះ ផអ៣ទី៣ ប្រកាន់ខ្ជាប់គុណតម្លៃនៃអភិបាលល្អសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលរួមមាន ភាពជាតំណាង ស្វ័យភាពមូលដ្ឋាន ការចូលរួម ការឆ្លើយតប គណនេយ្យភាព តម្លាភាព បរិយាប័ន្ននិងសមធម៌សង្គម និងការប្រឆាំងអំពើពុករលួយនិងការរំលោភអំណាច។

ជាមួយគ្នាដែរ ផអ៣ទី៣នឹងផ្តោតទៅលើការពង្រឹងទំនាក់ទំនងសំខាន់ៗផ្សេងគ្នាចំនួន៣គឺ ៖

- ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយថ្នាក់ជាតិ។

## ខ. វឌ្ឍនភាព និងបញ្ហាប្រឈម

តាមរយៈការអនុវត្តផអ៣ទី១ និងផអ៣ទី២ នីតិវិធីអនុវត្តការងារជាច្រើនត្រូវបានបង្កើតឡើងសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុកក្នុងការដាក់ចេញដីកា ការរៀបចំកិច្ចប្រជុំ និងវេទិកានានា ការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងសង្គមស៊ីវិល ការលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋានជាដើម។ សមាគមនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ផលប្រយោជន៍រួមរបស់ក្រុមប្រឹក្សា។

ចាប់តាំងពីឆ្នាំ២០១៥មក ផែនការយុទ្ធសាស្ត្រ និងកម្មវិធីស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានរៀបចំ និងអនុវត្តក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលនានា។ កម្មវិធីនេះបានបង្កលក្ខណៈក្នុងការផ្តល់នូវព័ត៌មានដ៏មានសារសំខាន់ៗ មានលក្ខណៈសាមញ្ញ និងងាយយល់ពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកា ការផ្តល់សេវា និងការអនុវត្តគម្រោងនានារបស់រដ្ឋបាលមូលដ្ឋាន និងបង្កលក្ខណៈឱ្យមានការចូលរួមតាមដានត្រួតពិនិត្យ និងផ្តល់យោបល់ពីប្រជាពលរដ្ឋនៅតាមមូលដ្ឋាននានា។ ជាមួយគ្នានេះដែរ គោលការណ៍ និងនីតិវិធី

នានាសម្រាប់ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម និងយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងធ្វើសេចក្តីសម្រេចចិត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានដាក់ចេញ និងកំពុងអនុវត្តផងដែរ។

ទោះបីមានវឌ្ឍនភាពជាច្រើនក៏ដោយ ក៏យើងនៅមានបញ្ហាប្រឈមពាក់ព័ន្ធនឹងគោលការណ៍មួយចំនួននៃអភិបាលកិច្ចល្អដែលត្រូវបន្តដោះស្រាយ។ ទីមួយ គឺរដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានលទ្ធភាពបំពេញគណនេយ្យភាពច្បាស់លាស់ក្នុងការផ្តល់សេវាចាំបាច់នានាដោយផ្ទាល់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដោយសារសេវាទាំងនោះភាគច្រើនស្ថិតនៅក្រោមការទទួលខុសត្រូវ និងការអនុវត្តរបស់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នជំនាញនៅឡើយ។ ទីពីរ ការចូលរួម និងការផ្តល់យោបល់របស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតនៅឡើយ។ បញ្ហានេះអាចកើតឡើងដោយសារតែកិច្ចដំណើរការនៃការរៀបចំឱ្យមានការចូលរួម និងផ្តល់យោបល់នៅពុំទាន់បង្កលក្ខណៈឱ្យបានសមស្រប ឬក៏ដោយសារប្រជាពលរដ្ឋនៅពុំទាន់មានជំនឿជាក់លើលទ្ធភាពដោះស្រាយបញ្ហារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទីបី ទោះបីមានការដាក់ចេញនូវគោលការណ៍ លិខិតបទដ្ឋានគតិយុត្ត និងកម្មវិធីដើម្បីលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមក៏ដោយ ក៏ប៉ុន្តែកិច្ចការនេះបានអនុវត្តភាគច្រើនតែលើបញ្ហាយេនឌ័រ ដោយពុំបានយកចិត្តទុកដាក់ឱ្យបានច្រើនទៅលើបញ្ហាយុវជន ជនពិការ ចាស់ជរា ជនជាតិដើមភាគតិចនៅឡើយ។ បញ្ហាប្រឈមចុងក្រោយ គឺពាក់ព័ន្ធនឹងការលើកកម្ពស់តម្លាភាព តាមរយៈការអនុវត្តការងារគណនេយ្យភាពសង្គមដែលបានអនុវត្តជាបណ្តើរៗតែនៅក្នុងវិស័យមួយចំនួនប៉ុណ្ណោះនៅថ្នាក់ឃុំគោលដៅនានា។ ជាមួយគ្នានេះដែរ ការងារនេះនៅពុំទាន់បានធ្វើសមាហរណកម្មពេញលេញទៅក្នុងប្រព័ន្ធកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលឃុំ និងអង្គភាពពាក់ព័ន្ធនានា (សាលារៀន និងមណ្ឌលសុខភាព) នៅឡើយ។

## គ. សមិទ្ធផលរំពឹងទុក និងលទ្ធផលរំពឹងទុក

សមិទ្ធផល និងលទ្ធផលរំពឹងទុកនៃសមាសភាគទី២នេះមានបរិយាយដូចខាងក្រោម ៖

**សមិទ្ធផលរំពឹងទុក ២.១ ៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានការទទួលខុសត្រូវ និងឆ្លើយតបចំពោះប្រជាពលរដ្ឋកាន់តែល្អប្រសើរ**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន២ដូចខាងក្រោម ៖

### លទ្ធផលរំពឹងទុក ២.១.១ ៖ ការងារគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងពង្រីក

***គោលដៅ***

- ការលើកកម្ពស់ការទទួលបាននូវព័ត៌មាន និងការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីព័ត៌មានសាធារណៈ

- ការបង្កើតយន្តការនានាសម្រាប់ប្រជាពលរដ្ឋត្រួតពិនិត្យ តាមដាន និងចូលរួមផ្ដល់យោបល់ ប្រកបដោយការស្ថាបនាដល់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពង្រឹងការផ្ដល់សេវា និងការកៀរគរធនធានសម្រាប់គាំទ្រអាទិភាពនានារបស់ប្រជាពលរដ្ឋតាមរយៈការចូលរួមក្នុងការងារគណនេយ្យភាពសង្គម។

***សកម្មភាពជាចម្បង***

- ការអនុវត្តការងារគណនេយ្យភាពសង្គម ស្របតាមផែនការយុទ្ធសាស្ត្រ និងសៀវភៅណែនាំកិច្ចប្រតិបត្តិការស្ដីពីការងារគណនេយ្យភាពសង្គម
- ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រស្ដីពីនិរន្តរភាពនៃការងារគណនេយ្យភាពសង្គម
- ការកំណត់អំពីមធ្យោបាយនានាដើម្បីពង្រឹងការចូលរួម និងការផ្ដល់យោបល់របស់អង្គការសង្គមស៊ីវិល និងការចូលរួមកាន់តែសកម្មរបស់ប្រជាពលរដ្ឋ
- ការពិនិត្យ និងកែសម្រួលផ្ទាំងផ្សព្វផ្សាយព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C) ឱ្យមានព័ត៌មានសំខាន់ៗគ្រប់គ្រាន់ជាងមុនសម្រាប់ការអនុវត្តការងារគណនេយ្យភាពសង្គម ដំណាក់កាលបន្ទាប់
- ការធ្វើសមាហរណកម្មការងារគណនេយ្យភាពសង្គមទៅក្នុងការរៀបចំផែនការ និងគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធ ដើម្បីធានាការផ្ដល់មូលនិធិដល់ការអនុវត្ត "ផែនការសកម្មភាពរួមគ្នាស្ដីពីគណនេយ្យភាព" (JAAPs)
- ការរៀបចំផែនការអនុវត្តការងារគណនេយ្យភាពសង្គមដំណាក់កាលបន្ទាប់ ដោយពង្រីកការគ្របដណ្ដប់ទៅលើវិស័យផ្សេងៗទៀត (ផ្សារភ្ជាប់ជាមួយនឹងការផ្ទេរមុខងារ) និងថ្នាក់រដ្ឋបាលផ្សេងទៀតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ក្រុង ស្រុក ព្រមទាំងកែលម្អនីតិវិធីនានា ដើម្បីធានាដល់ការដោះស្រាយនូវតម្រូវការជាក់លាក់របស់ក្រុមជនងាយរងគ្រោះផ្សេងៗដូចជា ក្រុមជនពិការ ចាស់ជរា។ល។
- ការរៀបចំលិខិតបទដ្ឋាននានា ដើម្បីធានាដល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ការរៀបចំ និងការអនុម័តផែនការអនុវត្តការងារគណនេយ្យភាពសង្គម ដំណាក់កាលបន្ទាប់ | ✓ | | |
| ការរៀបចំ និងអនុម័តលិខិតបទដ្ឋានស្ដីពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន | | | ✓ |
| ភាគរយនៃការប្រមូល និងបញ្ចូលទិន្នន័យនៃការផ្ដល់សេវាដែលបានគ្រោងនៅក្នុងផ្ទាំងផ្សព្វផ្សាយព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C) នៃការងារគណនេយ្យភាពសង្គម | ៩០% | ៩៥% | ៩៥% |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ផែនការអនុវត្តការងារគណនេយ្យភាពសង្គមនឹងបន្តគ្រប់គ្រងតាមបែបផែនដាច់ដោយឡែកពីគ្នារវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ និងក្រោមការសម្របសម្រួលដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងរួមគ្នាមួយ។

**លទ្ធផលរំពឹងទុក ២.១.២ ៖ យន្តការទទួលនិងសម្រុះសម្រួលដោះស្រាយមតិយោបល់ និងបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកែសម្រួល និងអនុវត្ត ដើម្បីបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ**

***គោលដៅ***

- ការលើកកម្ពស់ការផ្តល់សេវា និងគណនេយ្យភាពរបស់បុគ្គលិក តាមរយៈការរៀបចំ ចាត់ចែង និងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋក្នុងការផ្តល់ព័ត៌មានត្រឡប់
- ការលើកកម្ពស់លទ្ធភាពសម្រាប់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់យន្តការទទួលនិងសម្រុះសម្រួលដោះស្រាយមតិយោបល់ និងបណ្តឹងតវ៉ា
- ការឆ្លើយតប និងសម្រុះសម្រួលដោះស្រាយមតិយោបល់ និងបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរឡើង តាមរយៈយន្តការទទួល និងសម្រុះសម្រួលដោះស្រាយមតិយោបល់ និងបណ្តឹងតវ៉ា។

***សកម្មភាពជាចម្បង***

- ➢ ការរៀបចំបង្កើតយន្តការទទួល និងសម្រុះសម្រួលដោះស្រាយមតិយោបល់ និងបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព បរិយាប័ន្ននិងសមធម៌សង្គម និងមានភាពងាយស្រួលប្រើប្រាស់
- ➢ ការអនុវត្តសាកល្បង និងពង្រីកការអនុវត្តយន្តការដែលទទួលបានជោគជ័យ និងពិនិត្យនិងកែសម្រួលតាមការចាំបាច់
- ➢ ការអនុវត្តសកម្មភាពនានាពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព និងការប្រាស្រ័យទាក់ទងនិងការផ្សព្វផ្សាយព័ត៌មានដោយមានកិច្ចសហការជាមួយសង្គមស៊ីវិល ដើម្បីជំរុញលើកទឹកចិត្តការប្រើប្រាស់យន្តការ និងបង្កើតឡើងនូវ "វប្បធម៌នៃការផ្តល់យោបល់" មួយ ដើម្បីប្រែក្លាយកិច្ចដំណើរការនេះឱ្យទៅជាកាតព្វកិច្ចមួយរបស់ប្រជាពលរដ្ឋ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| យន្តការទទួល និងសម្រុះសម្រួលមតិយោបល់ និងបណ្តឹងតវ៉ាថ្មីបានរៀបចំ កែលម្អ ប្រើប្រាស់ និងវាយតម្លៃ | រៀបចំ | អនុវត្ត | វាយតម្លៃ |

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនមតិយោបល់ និងបណ្តឹងតវ៉ាដែលបានសម្រុះសម្រួលដោះស្រាយ | ៥០០ | ១.៥០០ | ២.០០០ |
| ភាគរយនៃមតិយោបល់ និងបណ្តឹងតវ៉ាដែលទទួលបានតាមរយៈទូរស័ព្ទ ឬវែបសាយ | | ២០% | ៣០% |
| ភាគរយមតិយោបល់ និងបណ្តឹងតវ៉ាមានលក្ខណៈសមស្របដែលបានឆ្លើយតប និងសម្រុះសម្រួលដោះស្រាយតាមពេលវេលាដែលបានសន្យា | ៥០% | ៦០% | ៧០% |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លទ្ធផលរំពឹងទុកនេះនឹងទទួលខុសត្រូវអនុវត្តដោយក្រសួងមហាផ្ទៃ។

## សមិទ្ធផលរំពឹងទុក ២.២ ៖ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតជាតំណាងប្រជាពលរដ្ឋ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងគោលនយោបាយនានា

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន១ដូចខាងក្រោម ៖

### លទ្ធផលរំពឹងទុក ២.២.១ ៖ កម្មវិធីនានាត្រូវបានរៀបចំ និងអនុវត្តដើម្បីពង្រឹងតួនាទីរបស់ក្រុមប្រឹក្សារបស់រដ្ឋបាលក្រុង ស្រុក និងពង្រឹងទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់

***គោលដៅ***

- ការពង្រឹងតួនាទីរបស់សមាជិកក្រុមប្រឹក្សា ដើម្បីបំពេញតួនាទីជាឱ្យបានកាន់តែល្អប្រសើរក្នុងនាមជាតំណាងប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះនានា និងដើម្បីបង្កើនប្រសិទ្ធភាពនៃការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តទាំងនោះ ព្រមទាំងជួយឱ្យក្រុមប្រឹក្សាក្លាយជាអ្នកដឹកនាំរបស់រដ្ឋបាលក្រុង ស្រុកដ៏មានប្រសិទ្ធភាព
- ការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុក ក្នុងការឆ្លើយតបចំពោះបញ្ហា និងតម្រូវការជាអាទិភាពនានារបស់ឃុំ សង្កាត់។

***សកម្មភាពជាចម្បង***

- ការរៀបចំបែបបទ និងនីតិវិធីដែលមានលក្ខណៈសាមញ្ញងាយស្រួលអំពីវិធីសាស្ត្រនៃការប្រាស្រ័យទាក់ទងរវាងក្រុមប្រឹក្សាជាមួយប្រជាពលរដ្ឋ ដើម្បីធានាដល់ការប្រមូលមតិយោបល់ត្រឡប់ និងការនាំយកមតិយោបល់ទាំងនោះដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សា និងការផ្សារភ្ជាប់កិច្ចដំណើរការនេះទៅនឹងការផ្ទេរមុខងារ និងការងារគណនេយ្យភាពសង្គម តាមភាពសមស្រប។
- ការពិនិត្យ និងកែសម្រួលប្រព័ន្ធកសាងផែនការ និងប្រព័ន្ធគ្រប់គ្រងរបស់ក្រុមប្រឹក្សាដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាក្រុង ស្រុក

ពិសេសពាក់ព័ន្ធនឹងការកំណត់អំពីបញ្ហាជាអាទិភាពនានា និងពង្រឹងគណនេយ្យភាពរបស់គណៈអភិបាលចំពោះក្រុមប្រឹក្សា។

- ការពិនិត្យ និងកែសម្រួលប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអាចមានលទ្ធភាពក្នុងការវិភាជធនធានទៅឱ្យក្រុមប្រឹក្សាសម្រាប់បំពេញតួនាទីរបស់ខ្លួន
- ការគាំទ្រការអនុវត្តនានាដែលជានាឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន តាមរយៈការអភិវឌ្ឍសមត្ថភាព និងការប្រាស្រ័យទាក់ទងនិងការផ្សព្វផ្សាយព័ត៌មាន រួមបញ្ចូលទាំងកម្មវិធីពង្រឹងសមាជិកក្រុមប្រឹក្សាជាស្ត្រី និងសមាជិកក្រុមប្រឹក្សាមកពីក្រុមងាយរងគ្រោះផ្សេងៗទៀត។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ការកែសម្រួលបែបបទ និងនីតិវិធីសម្រាប់ពង្រឹងការប្រាស្រ័យទាក់ទងរវាងក្រុមប្រឹក្សាជាមួយប្រជាពលរដ្ឋ និងទំនាក់ទំនងរវាង ឃុំ សង្កាត់ និងក្រុង ស្រុក | បញ្ចប់ការពិនិត្យឡើងវិញ | បញ្ចប់ការកែសម្រួល | |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងទទួលខុសត្រូវក្នុងការដឹកនាំការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានការគាំទ្រពីក្រសួងមហាផ្ទៃ និងអគ្គលេខាធិការដ្ឋាននៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

**សមិទ្ធផលរំពឹងទុក ២.៣ ៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាព និងអនុវត្តបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្ត និងស្តង់ដានានារបស់ថ្នាក់ជាតិ ដោយផ្សារភ្ជាប់នឹងការទទួលធនធាន និងការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើលទ្ធផលការងារ**

សមិទ្ធផលរពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន២ដូចខាងក្រោម ៖

**លទ្ធផលរំពឹងទុក ២.៣.១ ៖ អធិការកិច្ច ដែលមានលក្ខណៈជាប្រព័ន្ធទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តលិខិតបទដ្ឋានរបស់ក្រសួង ស្ថាប័នត្រូវបានរៀបចំ និងអនុវត្ត**

***គោលដៅ***

- ការទប់ស្កាត់ឥរិយាបថមិនសមរម្យរបស់មន្ត្រីក្នុងបំពេញការងារ តាមរយៈកិច្ចដំណើរការ

អធិការកិច្ចគួរជឿជាក់ និងទុកចិត្ត

- ការធានាថា លិខិតបទដ្ឋាន និងស្តង់ដារនានាត្រូវបានអនុវត្តតាម
- ការលើកកម្ពស់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការផ្សារភ្ជាប់នូវការអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋាននានាជាមួយនឹងការលើកទឹកចិត្តនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

***សកម្មភាពជាចម្បង***

- ការសិក្សាបទពិសោធន៍ពីបណ្តាប្រទេសនានាស្តីពីប្រព័ន្ធអធិការកិច្ចទៅលើរដ្ឋបាលមូលដ្ឋាន និងប្រព័ន្ធផ្តល់មូលនិធិផ្អែកលើលទ្ធផលការងារ
- ការរៀបចំក្របខ័ណ្ឌការងារ និងសេចក្តីណែនាំបច្ចេកទេសសម្រាប់ការធ្វើអធិការកិច្ចលើការរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តលិខិតបទដ្ឋានរបស់ក្រសួង ស្ថាប័ន និងការបំពេញការងារផ្សេងទៀត
- ការរៀបចំផែនការចុះធ្វើអធិការកិច្ចជាទៀងទាត់របស់ក្រសួងមហាផ្ទៃទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការសាកល្បង និងការពង្រីកគោលដៅបន្ថែមច្បាស់លាស់ ដោយមានការកំណត់នូវសូចនាករ មធ្យោបាយផ្ទៀងផ្ទាត់ កិច្ចដំណើរការ ការរៀបចំយន្តការ និងប្រព័ន្ធដាក់ពិន្ទុឱ្យបានច្បាស់លាស់
- ការពិនិត្យ និងកែសម្រួលឡើងវិញនូវប្រព័ន្ធអធិការកិច្ចទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន ដើម្បីធានាដល់ការគ្របដណ្តប់ទាំងការងារគ្រប់គ្រងធនធានមនុស្ស ការកសាងផែនការ និងការងារហិរញ្ញវត្ថុថែមទៀត
- ការពិនិត្យ និងកែសម្រួលឡើងវិញនូវផែនការធ្វើអធិការកិច្ចជាទៀងទាត់ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យ ដើម្បីធានាថា ការអនុវត្តមុខងារទាំងនោះសមស្របតាមលិខិតបទដ្ឋាននានា
- ការពិនិត្យ និងកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធអង្គភាពអធិការកិច្ចរបស់ក្រសួង ស្ថាប័ននានា រួមបញ្ចូលទាំងការធ្វើប្រតិភូកម្មនូវការទទួលខុសត្រូវលើការងារអធិការកិច្ចរបស់ក្រសួងស្ថាប័នទាំងនោះទៅឱ្យរដ្ឋបាលខេត្ត ការបែងចែកការងារអធិការកិច្ចឱ្យបានច្បាស់លាស់ និងដាច់ដោយឡែកពីការងារដទៃទៀត និងការធានាឱ្យមានបុគ្គលិកគ្រប់គ្រាន់ ព្រមទាំងការចូលរួមរបស់អង្គការសង្គមស៊ីវិល ឬវិស័យឯកជននានាក្នុងការងារអធិការកិច្ច
- ការកំណត់អំពីបែបផែននៃការរៀបចំស្ថាប័ន ដើម្បីបង្កើត និងដាក់ឱ្យដំណើរការនូវ "គណៈកម្មការអធិការកិច្ចរួមគ្នា" មួយ ឬអង្គភាពមួយសម្រាប់សម្របសម្រួលការអនុវត្តការងារ និងរបៀបធ្វើរបាយការណ៍របស់អង្គភាពអធិការកិច្ចនៃក្រសួង ស្ថាប័ននានា។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនសរុបនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើអធិការកិច្ចដោយក្រសួងមហាផ្ទៃសម្រាប់ការអនុវត្តតាមច្បាប់ និងការបំពេញការងារ | | ១០ | ២០ |
| ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិបានធ្វើអធិការកិច្ចដោយក្រសួងមហាផ្ទៃទទួលបានពិន្ទុគួរឱ្យពេញចិត្ត ឬបំពេញបាននូវល័ក្ខខ័ណ្ឌអប្បបរមា | | ២០% | ៣០% |
| ចំនួនសរុបនៃក្រសួង ស្ថាប័ន (លើកលែងក្រសួងមហាផ្ទៃ) ដែលបានធ្វើអធិការកិច្ចលើការបំពេញការងារ និងការអនុវត្តតាមច្បាប់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ០ | ២ | ៤ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវដឹកនាំក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានការសម្របសម្រួលជាមួយក្រសួង ស្ថាប័នផ្សេងទៀត។ ក្រសួង ស្ថាប័នជំនាញពិនិត្យមើល និងកែសម្រួលឡើងវិញនូវផែនការអធិការកិច្ច និងរចនាសម្ព័ន្ធអង្គភាពអធិការកិច្ចរបស់ខ្លួន។ លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការវិភាគ និងការរៀបចំសេចក្តីណែនាំពាក់ព័ន្ធនានា។

## លទ្ធផលរំពឹងទុក ២.៣.២ ៖ ការវាយតម្លៃប្រចាំឆ្នាំលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ធៀបទៅនឹងស្តង់ដាត្រូវបានអនុវត្ត និងផ្សារភ្ជាប់ជាមួយការលើកទឹកចិត្ត

***គោលដៅ***

ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការត្រួតពិនិត្យលើការបំពេញការងារធៀបនឹងស្តង់ដានានា និងការផ្សារភ្ជាប់រវាងការសម្រេចបានតាមស្តង់ដាជាមួយនឹងការផ្តល់ការលើកទឹកចិត្ត ឬការផ្តល់មូលនិធិបន្ថែមនានា។

***សកម្មភាពជាចម្បង***

- ការរៀបចំ និងអនុម័តនូវក្របខ័ណ្ឌវាយតម្លៃប្រចាំឆ្នាំអំពីការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិច្បាស់លាស់មួយ ដោយមានការចូលរួមផ្តល់យោបល់ពីអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា រួមបញ្ចូលទាំងការកំណត់នូវចំណុចដៅ និងសូចនាករនានា និងការចាប់ផ្តើមអនុវត្តតាមរយៈការសាកល្បង
- ការរៀបចំនីតិវិធីសម្រាប់ការផ្តល់យោបល់ដល់រដ្ឋបាលរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើលទ្ធផលវាយតម្លៃ ដែលនីតិវិធីនេះនឹងជួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំនូវផែនការកែលម្អការបំពេញការងាររបស់ខ្លួន
- ការរៀបចំទិន្នន័យសម្រាប់ការវាយតម្លៃតាមប្រព័ន្ធកុំព្យូទ័រ ព្រមទាំងផ្សព្វផ្សាយលទ្ធផលនានាជាសាធារណៈ

➢ ការផ្សារភ្ជាប់លទ្ធផលនៃការវាយតម្លៃប្រចាំឆ្នាំទៅនឹងការផ្តល់រង្វាន់លើកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ បន្ទាប់ពីពេលដែលប្រព័ន្ធវាយតម្លៃការបំពេញការងារអាចដំណើរការបាន។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ក្របខ័ណ្ឌវាយតម្លៃលទ្ធផលនៃការបំពេញការងារប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | អនុម័ត | | |
| ចំនួនរដ្ឋបាលក្រុង ស្រុកដែលមានផែនការកែលម្អការអនុវត្តការងាររបស់ខ្លួន ផ្អែកតាមលទ្ធផលនៃការវាយតម្លៃធៀបនឹងស្តង់ដារ | | ៣០ | ៨០ |
| ប្រព័ន្ធផ្តល់មូលនិធិលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | | រៀបចំតាក់តែង | សាកល្បង |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវដឹកនាំក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានការចូលរួមពីក្រសួង ស្ថាប័ននានាដែលពាក់ព័ន្ធនឹងការផ្ទេរមុខងារ។

## សមិទ្ធផលរំពឹងទុក ២.៤ ៖ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រងការងាររបស់ខ្លួនបានល្អប្រសើរ និងមានប្រសិទ្ធភាព

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន៤ដូចខាងក្រោម ៖

### លទ្ធផលរំពឹងទុក ២.៤.១ ៖ ការពិនិត្យមើលប្រចាំឆ្នាំរួមគ្នាទៅលើប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត

***គោលដៅ***

- ការស្តាប់យោបល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីមានការយល់ដឹងកាន់តែល្អប្រសើរអំពីការប្រើប្រាស់ និងភាពសមស្របនៃប្រព័ន្ធគ្រប់គ្រងនានា
- ការពិនិត្យកែសម្រួល និងកែលម្អប្រព័ន្ធនានា ដើម្បីធ្វើឱ្យប្រព័ន្ធទាំងនោះកាន់តែមានភាពសមស្រប សមញ្ញងាយស្រួលក្នុងការប្រើប្រាស់ និងកាន់តែមានប្រសិទ្ធភាព។

***សកម្មភាពជាចម្បង***

➢ ការរៀបចំតាក់តែង ការអនុវត្តសាកល្បង និងការពង្រីកនូវកិច្ចដំណើរការមួយ ដើម្បីរួមគ្នាពិនិត្យមើលឡើងវិញ និងគាំទ្រដល់ការប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវប្រព័ន្ធគ្រប់គ្រងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

➢ ការផ្តល់អនុសាសន៍នានាដើម្បីកែលម្អការរៀបចំតាក់តែង និងការប្រើប្រាស់ប្រព័ន្ធទាំងនោះផ្អែកលើលទ្ធផលនៃការពិនិត្យឡើងវិញរួមគ្នា

- ការពិនិត្យមើលឡើងវិញ និងកែសម្រួលនូវរចនាសម្ព័ន្ធ និងការរៀបចំបុគ្គលិករបស់ក្រសួងមហាផ្ទៃ ដើម្បីផ្តល់ការគាំទ្រផ្នែកគ្រប់គ្រងដល់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយជំនាញវិជ្ជាជីវៈ និងគុណភាពខ្ពស់។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ការពិនិត្យឡើងវិញរួមគ្នាទៅលើប្រព័ន្ធគ្រប់គ្រងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | រៀបចំ និងសាកល្បង | អនុវត្ត | |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវដឹកនាំការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ លទ្ធផលរំពឹងនេះ និងលទ្ធផលរំពឹងទុក៣ទៀត (២.៤.២ ដល់ ២.៤.៤) អាចដាក់ក្រោមការគ្រប់គ្រងក្នុងបែបផែនជា **គម្រោងតែមួយ។**

## លទ្ធផលរំពឹងទុក ២.៤.២ ៖ ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ និងប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងអនុវត្ត

***គោលដៅ***

- ការធ្វើឱ្យប្រសើរឡើងនូវការធ្វើសេចក្តីសម្រេចចិត្តរបស់ថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់ និងការពង្រឹងការប្រើប្រាស់នូវទិន្នន័យ និងភស្តុតាងនានាដែលបានមកពីព័ត៌មានដែលចាត់ចែង និងគ្រប់គ្រងដោយក្រុង ស្រុក។

***សកម្មភាពជាចម្បង***

- ការប្រើប្រាស់បច្ចេកទេសរៀបចំកម្មវិធីទំនើបមួយដើម្បីពិនិត្យ និងកែសម្រួលនូវប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ និងប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងរបស់ក្រុង ស្រុកដោយមានការចូលរួមពីអ្នកប្រើប្រាស់និងធានាថាប្រព័ន្ធថ្មីនេះឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់។
- ការធ្វើវិមជ្ឈការមុខងារស្តីពីការប្រមូល និងការគ្រប់គ្រងទិន្នន័យទៅឱ្យក្រុង ស្រុក។
- ការបន្តពិនិត្យ និងកែសម្រួលជាបណ្តើរៗនូវប្រព័ន្ធការងារនានាតាមកុំព្យូទ័ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ប្រព័ន្ធប្រមូល និងគ្រប់គ្រងព័ត៌មានត្រូវបានធ្វើវិមជ្ឈការទៅឱ្យថ្នាក់ក្រុង ស្រុក | PID និងប្រព័ន្ធកសាងផែនការ | CDB | MIS វិស័យយ៉ាងតិចចំនួន១ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវដឹកនាំការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយក្រសួងផែនការ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

### លទ្ធផលរំពឹងទុក ២.៤.៣ ៖ ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនិវឌ្ឍបន្ថែម

***គោលដៅ***

- ផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្តោតលើការរៀបចំសកម្មភាព និងការប្រើប្រាស់ថវិកាដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋ។

***សកម្មភាពជាចម្បង***

- ការវាយតម្លៃទៅលើគុណភាព និងប្រសិទ្ធភាពនៃការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយការវាយតម្លៃទៅលើប្រសិទ្ធភាពនៃការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ និងបរិយាប័ននិងសមធម៌សង្គម
- ការពិនិត្យ ការកែសម្រួល និងការអនុវត្តសាកល្បងនូវប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពិនិត្យ ការកែសម្រួល និងការបែងចែកការទទួលខុសត្រូវក្នុងការរៀបចំ និងការគ្រប់គ្រងទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនរដ្ឋបាលក្រុង ស្រុកមានលទ្ធផលរំពឹងយ៉ាងតិចចំនួន៥ សូចនាករចំនួន៤ និងលទ្ធផលរំពឹងទុកមិនមែនរចនាសម្ព័ន្ធចំនួន៣ នៅក្នុងផែនការរបស់ខ្លួន | ២០% | ៥០% | ៩០% |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងផែនការទទួលខុសត្រូវក្នុងការសម្របសម្រួលអនុវត្តលទ្ធផលរំពឹងទុកនេះដោយសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងពាក់ព័ន្ធ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

### លទ្ធផលរំពឹងទុក ២.៤.៤ ៖ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួល និងអនុវត្ត

***គោលដៅ***

- ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តប្រកបដោយប្រសិទ្ធភាព និងធានាបាននូវគុណតម្លៃថវិកា

- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុគាំទ្រដល់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមតម្រូវការជាអាទិភាពរបស់សហគមន៍មូលដ្ឋាន។

***សកម្មភាពជាចម្បង***

➢ ការបញ្ចប់ការសិក្សាវាយតម្លៃលើគុណភាព និងប្រសិទ្ធភាព និងភាពសក្តិសិទ្ធនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ រួមបញ្ចូលទាំងការកំណត់នូវបញ្ហាប្រឈមជាគន្លឹះនៃកិច្ចប្រតិបត្តិការ

➢ ការពិនិត្យ ការកែសម្រួល ការអនុវត្តសាកល្បង និងការអនុវត្តពេញលេញនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដែលបានកែសម្រួល

➢ ការបង្កើតគេហទំព័រសម្រាប់ប្រព័ន្ធទិន្នន័យថវិកា និងការចំណាយរបស់រដ្ឋបាលថ្នាក់ជាតិដែលមានលទ្ធភាពផ្សព្វផ្សាយជាសាធារណៈ និងការយល់ដឹងរបស់ស្ថាប័នសាធារណៈផ្សេងៗទៀត និងសាធារណជនទូទៅ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានកែសម្រួល និងដាក់ឱ្យអនុវត្ត | ការសិក្សាវិភាគ | ការអនុវត្តសាកល្បង | ការអនុវត្តពេញលេញ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

## សមិទ្ធផលរំពឹងទុក ២.៥ ៖ រដ្ឋបាលថ្នាក់ក្រោមជាតដោះស្រាយ និងលើកកម្ពស់សុខុមាលភាពរបស់ក្រុមជនងាយរងគ្រោះនានា

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន៤ដូចខាងក្រោម ៖

### លទ្ធផលរំពឹងទុក ២.៥.១ ៖ កម្មវិធីនានាត្រូវបានអនុវត្តដោយមានការយកចិត្តទុកដាក់ដល់ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម តាមរយៈការដឹកនាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដ៏ល្អប្រសើរ

***គោលដៅ***

- អ្នកដឹកនាំប្រកាន់យកនូវវិធានការនានាដើម្បីលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមនៅក្នុងរាល់ការធ្វើសេចក្តីសម្រេចចិត្តនានារបស់ខ្លួន
- សេចក្តីសម្រេចចិត្តនានាត្រូវបានធ្វើឡើងប្រកបដោយលក្ខណៈកាន់តែល្អប្រសើរ តាមរយៈការដឹកនាំប្រកបដោយការពិចារណាលើគ្រប់រូបភាព និងការចូលរួមពីបុគ្គលិកពាក់ព័ន្ធនានា។

### សកម្មភាពជាចម្បង

- ការអនុវត្តផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពង្រីកការអនុវត្តនូវគោលការណ៍នានានៃផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្របដណ្តប់ទៅលើក្រុមជនងាយរងគ្រោះផ្សេងៗទៀត រួមមានដូចជា ក្រុមជនពិការ និងក្រុមជនជាតិដើមភាគតិច។
- ការរៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចជារៀងរាល់ឆ្នាំអំពីយេនឌ័រសម្រាប់ថ្នាក់ដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលទាំងការត្រួតពិនិត្យតាមដាននូវដំណោះស្រាយជាក់លាក់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗពាក់ព័ន្ធនឹងបរិយាប័ន្ន និងសមធម៌សង្គម
- ការរៀបចំយុទ្ធសាស្ត្រ ដើម្បីបង្កើនចំនួនស្ត្រីក្នុងមុខតំណែងមិនមែនថ្នាក់ដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងការជ្រើសរើសតាមសាកលវិទ្យាល័យ និងការផ្តល់នូវឱកាសក្នុងការធ្វើកម្មសិក្សា។

### ចំណុចដៅ

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| មូលដ្ឋានទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យាដើម្បីត្រួតពិនិត្យសមាសភាពតាមមុខតំណែង និងកូតារបស់បុគ្គលិកទាំងពីរភេទត្រូវបានរៀបចំ | សិក្សាវិភាគ | អនុវត្តសាកល្បង | អនុវត្ត |
| យុទ្ធសាស្ត្រដើម្បីលើកកម្ពស់ស្ត្រីក្នុងមុខតំណែងមិនមែនថ្នាក់ដឹកនាំនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | រៀបចំ | អនុវត្ត | អនុវត្ត |
| ភាគរយអភិបាល អភិបាលរងបានបញ្ចប់វគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចអំពីអំពីយេនឌ័រ | ៩៥% | ៩៥% | ៩៥% |
| ភាគរយស្ត្រីនៅក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត | | | |
| ភាគរយស្ត្រីនៅក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | ២០% | ២២% | ២៥% |

### ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត

ក្រសួងកិច្ចការនារីទទួលខុសត្រូវដឹកនាំការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

## លទ្ធផលរំពឹងទុក ២.៨.២ ៖ បរិយាប័ន្ន និងសមធម៌សង្គមត្រូវបានបញ្ជ្រាបទៅក្នុងកិច្ចប្រតិបត្តិការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### គោលដៅ

- ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមនឹងមានភាពប្រសើរឡើងតាមរយៈការអនុវត្តគោលនយោបាយ និងកម្មវិធីនានាដែលបានបញ្ជ្រាបកិច្ចការទាំងនេះ ។

***សកម្មភាពជាចម្បង***

- ការបញ្ជ្រាបការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមទៅក្នុងរាល់គោលនយោបាយ កម្មវិធីការអភិវឌ្ឍសមត្ថភាព ការផ្ដល់សេវា និងសកម្មភាពចម្បងៗដទៃទៀតនៃផអ៣ទី៣
- ការពង្រីកវិសាលភាពនៃការធ្វើសវនកម្មយេនឌ័រ ដោយដាក់បញ្ចូលនូវបញ្ហារបស់ក្រុមជនងាយរងគ្រោះដទៃទៀត ដើម្បីលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម
- ការរៀបចំកម្មវិធីជាក់លាក់នានាដោយមានការកំណត់អំពីការចំណាយច្បាស់លាស់ ដើម្បីគាំទ្រដល់ក្រុមយុវជន ជនពិការ ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងៗទៀត ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| កម្មវិធីជាក់លាក់នានាក្នុងការលើកកម្ពស់យុវជន ជនពិការ ជនជាតិដើមភាគតិច នឹងក្រុមជនងាយរងគ្រោះផ្សេងៗទៀតត្រូវបានអនុវត្ត | រៀបចំ | អនុវត្តកម្មវិធីចំនួន១ | អនុវត្តកម្មវិធីចំនួន២ |
| ភាគរយនៃពិន្ទុនៃការបញ្ជ្រាបយេនឌ័រក្នុងរបាយការណ៍សវនកម្មយេនឌ័រមានការកើនឡើង | | | ១៥% |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប ទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយសហការជាមួយក្រសួងកិច្ចការនារី និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

### លទ្ធផលរំពឹងទុក ២.៥.៣ ៖ តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់សេវាសុវត្ថិភាពសង្គមត្រូវបានគាំទ្រ

***គោលដៅ***

- ការពង្រឹងសេវាសុវត្ថិភាពសង្គមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

***សកម្មភាពជាចម្បង***

- កិច្ចសហការជាមួយសហគមន៍ សង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីកំណត់ និងអនុវត្តនូវសេវាសុវត្ថិភាពសង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការធានាការផ្ទេរមុខងារ និងធនធានពាក់ព័ន្ធនឹងការងារសង្គមកិច្ចប្រកបដោយប្រសិទ្ធភាព
- ការសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដើម្បីសម្របសម្រួលការផ្ដល់សេវាសុវត្ថិភាពសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ការផ្តល់មូលនិធិដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការផ្តល់សេវាសុវត្ថិភាពសង្គម (គិតលានដុល្លារ) | ១ | ២ | ៣ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប.ទទួលខុសត្រូវក្នុងការដឹកនាំការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយសហការជាមួយក្រសួងកិច្ចការនារី និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

## ***លទ្ធផលរំពឹងទុក ២.៨.៤ ៖ ការអភិវឌ្ឍសមត្ថភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងបរិយាប័ន្ន និងសមធម៌សង្គមត្រូវបានគាំទ្រ***

***គោលដៅ***

- រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពក្នុងការអនុវត្តសកម្មភាពនានាពាក់ព័ន្ធនឹងបរិយាប័ន្ន និងសមធម៌សង្គម
- បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិភាគច្រើនយល់ដឹងអំពីបរិយាប័ន្ន និងសមធម៌សង្គម។

***សកម្មភាពជាចម្បង***

- ការរៀបចំ និងអនុវត្តនូវការអភិវឌ្ឍសមត្ថភាពដែលផ្តល់អាទិភាពដល់ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម
- ការរៀបចំបណ្តាញ និងបែបផែននានានៃការត្រួតពិនិត្យតាមដាន ដើម្បីផ្លាស់ប្តូរមេរៀន និងបទពិសោធន៍ល្អៗ
- ការពង្រឹងស្ថាប័នសំខាន់ៗដូចជា គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមាររបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមការងារបញ្ជ្រាបយេនឌ័ររបស់ក្រសួង ស្ថាប័ន។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបានវិភាជថវិកាគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមការងារបញ្ជ្រាបយេនឌ័ររបស់ក្រសួង ស្ថាប័ន | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយក្រសួងកិច្ចការនារី និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

## ឃ. គម្រោងថវិកាប៉ាន់ស្មាន

ថវិកាប៉ាន់ស្មានសម្រាប់ការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗនៃសមាសភាគនេះ រួមមានដូចខាងក្រោម ៖

**តារាងទី៨ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់សមាសភាគទី២**

| លទ្ធផលរំពឹងទុក | ថវិកា | | | |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | សរុប |
| ២.១.១. ការងារគណនេយ្យភាពសង្គមត្រូវបានពង្រឹង និងពង្រីក | 8,177,600 | 8,152,600 | 7,979,800 | **24,310,000** |
| ២.១.២. យន្តការទទួលនិងសម្រុះសម្រួលដោះស្រាយមតិយោបល់ និងបណ្ដឹងតវ៉ារបស់ប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកែសម្រួល និងអនុវត្ត ដើម្បីបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ | 214,500 | 300,000 | 280,000 | **794,500** |
| ២.២.១. កម្មវិធីនានាត្រូវបានរៀបចំ និងអនុវត្តដើម្បីពង្រឹងតួនាទីរបស់ក្រុមប្រឹក្សារបស់រដ្ឋបាល ក្រុង ស្រុក និងពង្រឹងទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ | 142,400 | 142,000 | 160,000 | **444,400** |
| ២.៣.១. អធិការកិច្ច ដែលមានលក្ខណៈជាប្រព័ន្ធទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តលិខិតបទដ្ឋានរបស់ក្រសួងស្ថាប័នត្រូវបានរៀបចំ និងអនុវត្ត | 271,300 | 381,300 | 543,300 | **1,195,900** |
| ២.៣.២. ការវាយតម្លៃប្រចាំឆ្នាំលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិធៀបទៅនឹងស្តង់ដា ត្រូវបានអនុវត្ត និងផ្សារភ្ជាប់ជាមួយការលើកទឹកចិត្ត | 99,000 | 275,500 | 275,500 | **650,000** |
| ២.៤.១. ការពិនិត្យមើលប្រចាំឆ្នាំរួមគ្នាទៅលើប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបាន អនុវត្ត | 152,400 | 245,350 | 71,000 | **468,750** |
| ២.៤.២. ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ និងប្រព័ន្ធព័ត៌សម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោម ជាតិត្រូវបានរៀបចំ និងអនុវត្ត | 115,400 | 160,400 | 102,800 | **378,600** |
| ២.៤.៣. ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអភិវឌ្ឍបន្ថែម | 126,200 | 126,200 | 103,100 | **355,500** |
| ២.៤.៤. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួលបន្ថែម និងអនុវត្ត | 135,000 | 162,500 | 135,000 | **432,500** |
| ២.៥.១. កម្មវិធីនានាត្រូវបានអនុវត្តដើម្បីលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈភាពជាអ្នកដឹកនាំដ៏ល្អរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 359,200 | 375,700 | 375,700 | **1,110,600** |
| ២.៥.២. បរិយាប័ន្ន និងសមធម៌សង្គមត្រូវបានបញ្ជ្រាបទៅក្នុងកិច្ចប្រតិបត្តិការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 344,200 | 386,000 | 325,500 | **1,055,700** |
| ២.៥.៣. តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសុវត្ថិភាពសង្គមត្រូវបានគាំទ្រ | 1,028,900 | 1,248,900 | 1,211,500 | **3,489,300** |
| ២.៥.៤. ការអភិវឌ្ឍសមត្ថភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 298,100 | 298,100 | 275,000 | **871,200** |

| លទ្ធផលរំពឹងទុក | ថវិកា | | | |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | សរុប |
| ពាក់ព័ន្ធនឹងបរិយាប័ន្ន និងសមធម៌សង្គមត្រូវបានគាំទ្រ | | | | |
| សរុប | 11,464,200 | 12,254,550 | 11,838,200 | 35,556,950 |

## ខ. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ

ហានិភ័យសំខាន់ៗនៃសមាសភាគនេះ រួមជាមួយនឹងវិធានការកាត់បន្ថយហានិភ័យទាំងនេះត្រូវបានកំណត់ដូចខាងក្រោម ៖

**តារាងទី៩៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគទី២**

| ល.រ | ហានិភ័យ | កម្រិត | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|
| ១. | ការងារគណនេយ្យភាពសង្គមមិនអាចដោះស្រាយបញ្ហាធំៗជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ បច្ចុប្បន្ននេះ ការងារគណនេយ្យភាពសង្គមអាចចូលរួមដោះស្រាយបានតែបញ្ហាងាយៗ។ ប្រការនេះនឹងនាំឱ្យប្រជាពលរដ្ឋពុំមានទឹកចិត្តក្នុងការចូលរួមផ្តល់យោបល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | ខ្ពស់ | ➢ ការសិក្សារៀនសូត្របទពិសោធន៍ល្អៗដែលជាផ្នែកមួយនៃផែនការអនុវត្តការងារគណនេយ្យភាពសង្គម ត្រូវផ្តោតទៅលើអាទិភាពនានាដែលបានកំណត់ក្នុងផែនការសកម្មភាពរួមនៃការងារគណនេយ្យភាពសង្គម<br>➢ ការផ្សារភ្ជាប់សកម្មភាពនានានៃការងារគណនេយ្យភាពសង្គមនៅមូលដ្ឋានជាមួយ នឹងគោលនយោបាយជាតិ |
| ២. | សមាជិកក្រុមប្រឹក្សាមិនសូវមានគំនិតផ្តួចផ្តើមគ្រប់គ្រាន់។ ការលើកកម្ពស់ការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋអាស្រ័យទៅលើសមាជិកក្រុមប្រឹក្សានានាដែលជាតំណាងឱ្យផលប្រយោជន៍របស់ខ្លួន។ ក្នុងន័យនេះ ការពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាពិតជាកិច្ចការដ៏សំខាន់មួយនៃការងារកំណែទម្រង់។ | មធ្យម | ➢ ការអភិវឌ្ឍសមត្ថភាព និងវិធីសាស្ត្រនៃការ ប្រាស្រ័យទាក់ទង និងផ្សព្វផ្សាយព័ត៌មានរបស់ ផអ៣ទី៣ ត្រូវផ្តោតទៅលើការផ្លាស់ប្តូរឥរិយាបទក្នុងការបំពេញការងារ។<br>➢ ការពិនិត្យ និងកែសម្រួលវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុងស្រុក និងការពង្រឹងសមត្ថភាពរបស់សមាគមក្រុមប្រឹក្សា។ |
| ៣. | ក្រសួង ស្ថាប័ននៅបន្តការគ្រប់គ្រង និងត្រួតពិនិត្យទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិច្រើនពេក។ កិច្ចការនេះ តម្រូវឱ្យមានការផ្លាស់ប្តូរទៅរកបែបផែនត្រឹមតែជាការត្រួតពិនត្យនីត្យនុកូលភាព និងការធ្វើអធិការកិច្ចដែលលក្ខណៈបង្កឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានស្វ័យភាពច្រើនក្នុងការអនុវត្តការងាររបស់ខ្លួន។ ការផ្លាស់ប្តូរបែបផែនការងារនេះមានសារសំខាន់ ប៉ុន្តែទាមទារពេលវេលាវែងសម | មធ្យម | ➢ ផែនការធ្វើអធិការកិច្ចជាទៀងទាត់នឹងត្រូវបានរៀបចំឡើងជាបណ្តើរៗ ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ<br>➢ ការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពដែលផ្តោតលើការផ្លាស់ប្តូរឥរិយាបថ និងការធ្វើឱ្យមានការយល់ដឹង និងការទទួលយកនូវវិធីសាស្ត្រថ្មីនេះផងដែរ។ |

| ល.រ | ហានិភ័យ | កម្រិត | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|
| | ស្របដើម្បីអនុវត្ត។ | | |
| ៤. | ការតាំងចិត្តក្នុងការចូលរួមលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមនៅពុំទាន់បានធ្វើឱ្យមានភាពជាក់ស្តែង និងពិតប្រាកដ។ ភាគីពាក់ព័ន្ធនីមួយៗតែងតែគូសបញ្ជាក់អំពីសារសំខាន់នៃបញ្ហានេះ ប៉ុន្តែជាក់ស្តែងពុំបានប្រកាន់យកនូវសកម្មភាពជាក់លាក់ក្នុងការដោះស្រាយនូវបញ្ហាពាក់ព័ន្ធនឹងបរិយាប័ន្ន និងសមធម៌សង្គមនេះឡើយ។ | មធ្យម | ➢ ពង្រឹងការចូលរួមរបស់សង្គមស៊ីវិល និងដៃគូនានា ដើម្បីផ្សព្វផ្សាយការងារនេះឱ្យបានទូលំទូលាយ<br>➢ វិភាជមូលនិធិក្នុងចំនួនសមស្របសម្រាប់ ការអនុវត្តសកម្មភាពលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម<br>➢ ខិតខំជំរុញឱ្យមានអ្នកដឹកនាំដែលមានការពិចារណាគ្រប់ជ្រុងជ្រោយ និងជាអ្នកដែលខិតខំបញ្ច្រាបជំនឿជឿជាក់លើការលើកកម្ពស់បរិយាប័ន្ននិងសមធម៌សង្គមក្នុងស្ថាប័នរបស់ខ្លួន |

# សមាសភាគទី ៣

# ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

## ក. សេចក្តីផ្តើម

ជាទូទៅ រដ្ឋបាលថ្នាក់ក្រោមជាតិមួយដែលអាចបំពេញការងារបានល្អ អាស្រ័យដោយរដ្ឋបាលនោះមានបុគ្គលិកគ្រប់គ្រាន់ បុគ្គលិកមានតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ មានជំនាញវិជ្ជាជីវៈ មានឥរិយាបថល្អ និងមានការលើកទឹកចិត្តសមស្រប និងដែលត្រូវបានគ្រប់គ្រង និងចាត់ចែងដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយភាពបត់បែន។ អាស្រ័យហេតុនេះ កម្មវិធីជាតិមានគោលដៅធ្វើវិមជ្ឈការការគ្រប់គ្រងធនធានមនុស្សទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ចាត់ចែងបុគ្គលិករបស់ខ្លួនប្រកបដោយភាពបត់បែន រួមបញ្ចូលទាំងបុគ្គលិកដែលត្រូវបានផ្ទេរភ្ជាប់ជាមួយនឹងការផ្ទេរមុខងារផងដែរ។ ទោះបីបុគ្គលិកទាំងនេះជាមន្ត្រីសាធារណៈក៏ដោយ ក៏បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជ្រើសរើសដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវមានគណនេយ្យភាពចំពោះថ្នាក់ដឹកនាំនៃរដ្ឋបាលរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងពុំអាចអនុវត្តអាណត្តិនានារបស់ខ្លួនក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធភាពឡើយ ប្រសិនបើគ្មានសិទ្ធិអំណាចក្នុងការគ្រប់គ្រងចាត់ចែងបុគ្គលិករបស់ខ្លួន។

ផអ៣ទី៣នឹងផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នគ្រប់ថ្នាក់ ដើម្បីធានាថា បុគ្គលិករបស់ស្ថាប័នទាំងនោះមានសមត្ថភាព និងមានជំនាញសមស្របក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ ផអ៣ទី៣ក៏នឹងផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក បើទោះបីជាការអភិវឌ្ឍសមត្ថភាពដ៏ទូលំទូលាយមួយក៏នឹងត្រូវផ្តល់ការគាំទ្រដល់រាជធានី ខេត្ត និងឃុំ សង្កាត់ក៏ដោយ។

## ខ. វឌ្ឍនភាព និងបញ្ហាប្រឈម

ជារួម រហូតមកដល់ពេលបច្ចុប្បន្ននេះ លិខិតបទដ្ឋានគតិយុត្តជាច្រើនស្តីពីការគ្រប់គ្រងធនធានមនុស្សបែបវិមជ្ឈការត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់។ សិទ្ធិអំណាច និងគោលការណ៍នានាសម្រាប់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ក្នុងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុម័តនៅពីថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦។ បន្ទាប់មក សេចក្តីណែនាំពាក់ព័ន្ធនានាកំពុងត្រូវបានគ្រោងរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០១៧។

នៅដើមឆ្នាំ២០១៧ ផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋ

បាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តដោយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាប្រធាន គ.ជ.អ.ប.** ហើយនៅដើមខែ ឧសភា ឆ្នាំ២០១៧ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក៏បានប្រកាសអំពីការតាំងចិត្តរបស់រាជរដ្ឋាភិបាលក្នុងការកំណត់ឱ្យមានស្ត្រីយ៉ាងតិចចំនួន០១រូបជាអភិបាលខេត្ត។

ផអ៣ទី១ បានផ្តោតការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈវគ្គបណ្តុះបណ្តាល ការសម្របសម្រួល និងការហ្វឹកហ្វឺនដែលភាគច្រើនពាក់ព័ន្ធតែទៅលើការអនុវត្តនូវប្រព័ន្ធគ្រប់គ្រងថ្មីនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីកិច្ចការនេះ គឺជាការចាប់ផ្តើមដ៏សំខាន់មួយក៏ដោយ ក៏បែបផែននៃការអភិវឌ្ឍសមត្ថភាពនេះត្រូវបានកែសម្រួលជាច្រើននៅក្នុងដំណាក់កាលនៃផអ៣ទី២។ បែបផែននៃការអភិវឌ្ឍសមត្ថភាពដោយផ្អែកលើតម្រូវការ និងបង្កើតឡើងនូវមណ្ឌលអភិវឌ្ឍធនធានមនុស្សរាជធានីខេត្តក្នុងដំណាក់កាលនៃផអ៣ទី២មានគោលបំណងកាត់បន្ថយនូវជំនួយបច្ចេកទេសជាបណ្តើរៗ។ ចាប់ពីឆ្នាំ២០១៦មក ការអភិវឌ្ឍសមត្ថភាពភាគច្រើនត្រូវបានអនុវត្តផ្អែកតាមតម្រូវការ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តបានផ្តល់ការបណ្តុះ បណ្តាលការហ្វឹកហ្វឺន និងណែនាំការងារនៅនឹងកន្លែងជាច្រើន រួមបញ្ចូលទាំងទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ ការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក ការបង្កើតបណ្តាញព័ត៌មានទាន់ហេតុការណ៍ និងការសម្របសម្រួលដល់ការរៀបចំផែនការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗផងដែរ។ បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិចំនួនប្រមាណ៦៤.០០០នាក់ទទួលបានការបណ្តុះបណ្តាលនៅក្នុងឆ្នាំ ២០១៦ ។ ជាមួយគ្នានេះដែរ អនុក្រឹត្យស្តីពីការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋានក៏ត្រូវបានអនុម័តនៅខែកញ្ញា ឆ្នាំ២០១៦។

ទោះបីមានវឌ្ឍនភាពជាច្រើនអំពីការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏នៅមានបញ្ហាប្រឈមសំខាន់មួយចំនួនដែលត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយក្នុងផអ៣ទី៣ ៖

- ការពុំទាន់បានបញ្ចប់នូវលិខិតបទដ្ឋាន និងសេចក្តីណែនាំមួយចំនួនពាក់ព័ន្ធនឹងការផ្ទេរវិមជ្ឈការការគ្រប់គ្រងធនធានមនុស្សទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ជារៀងរាល់ឆ្នាំ កម្មវិធីបានចំណាយថវិកាប្រមាណ៥លានដុល្លារសម្រាប់ការអភិវឌ្ឍសមត្ថភាព ក៏ប៉ុន្តែគុណភាព និងគុណតម្លៃថវិកានៃការអភិវឌ្ឍសមត្ថភាពនេះនៅតែពុំទាន់មានភាពសមស្រប ដែលចាំបាច់ត្រូវតែមានការលើកកម្ពស់បន្ថែមទៀត
- នៅក្នុងបែបផែនវិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពនាពេលបច្ចុប្បន្ន រួមមានបញ្ហាលំបាកមួយចំនួន ពោលគឺ ១.) នៅតែផ្អែកលើការបណ្តុះបណ្តាលមានលក្ខណៈជាផ្លូវការពេក និងមានលក្ខណៈជាការបណ្តុះបណ្តាលបន្ត ២.) ការបណ្តុះបណ្តាលភាគច្រើនពុំបានផ្តោតទៅលើការងារជាក់លាក់ ដែលជាហេតុធ្វើឱ្យពុំអាចមានលទ្ធភាពជួយអភិវឌ្ឍសមត្ថភាពជំនាញលើការងារជាក់លាក់ឱ្យបានគ្រប់គ្រាន់ និងពុំមានការតាមដានត្រួតពិនិត្យផងដែរ និង៣.) វគ្គបណ្តុះបណ្តាលទាំងនោះភាគច្រើនពុំដែលបានផ្សព្វផ្សាយ ឬពុំបានផ្តោតទៅលើការធ្វើឱ្យ

មានការផ្លាស់ប្តូរឥរិយាបថក្នុងការបំពេញការងារនោះឡើយ

- ការបណ្តុះបណ្តាលរបស់ថ្នាក់ជាតិពុំទាន់មានការសម្របសម្រួលគ្នាឱ្យបានល្អគ្រប់គ្រាន់ ហើយក៏នៅពុំទាន់មានស្តង់ដារគ្រប់គ្រាន់ ដើម្បីធានាគុណភាពនៃការអភិវឌ្ឍសមត្ថភាពទាំងនោះនៅឡើយ
- យុទ្ធសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពមានលក្ខណៈទូលំទូលាយពេក ដែលធ្វើឱ្យពិបាកយល់ និងពុំបានកំណត់ពីប្រធានបទជាអាទិភាពសម្រាប់ការអភិវឌ្ឍសមត្ថភាព
- ការទទួលខុសត្រូវរវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវាអភិវឌ្ឍសមត្ថភាពនៅមានភាពទន់ខ្សោយនៅឡើយ
- សមត្ថភាពនៃភាពជាអ្នកដឹកនាំនៅមានកម្រិត ដែលចាំបាច់ត្រូវមានការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍសមត្ថភាពនៃភាពជាអ្នកដឹកនាំជាបន្តបន្ទាប់បន្ថែមទៀត
- ស្ត្រីក្នុងមុខតំណែងជាអ្នកគ្រប់គ្រងនៅថ្នាក់ក្រោមជាតិនៅមានចំនួនតិចតួចនៅឡើយ
- និរន្តភាពនៃកិច្ចដំណើរការរបស់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ចាំបាច់ត្រូវបានយកចិត្តទុកដាក់ដោះស្រាយ រួមបញ្ចូលទាំងការធ្វើសមាហរណកម្មមុខងាររបស់មណ្ឌលទាំងនេះទៅក្នុងសាលាជាតិរដ្ឋបាលមូលដ្ឋាន និងទៅក្នុងរចនាសម្ព័ន្ធអង្គភាពជាក់លាក់របស់រដ្ឋបាលរាជធានី ខេត្ត
- សាលាជាតិរដ្ឋបាលមូលដ្ឋាននៅពុំទាន់បានដំណើរការនៅឡើយ។

## គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុក និងលទ្ធផលរំពឹងទុកនៃសមាសភាគទី៣នេះមានបរិយាយដូចខាងក្រោម ៖

**សមិទ្ធផលរំពឹងទុក ៣.១ ÷ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិអំណាច និងស្វ័យភាពក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន១ដូចខាងក្រោម ៖

**លទ្ធផលរំពឹងទុក ៣.១.១ ៖ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សបែបវិមជ្ឈការត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការតែងតាំង ការផ្ទេរ ការដាក់ពិន័យ និងកិច្ចការដទៃទៀតនៃការងារគ្រប់គ្រងបុគ្គលិករបស់ខ្លួន**

***គោលដៅ***

- រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងចាត់ចែងបុគ្គលិករបស់ខ្លួនដើម្បីធានាដល់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគុណភាព និង

ប្រសិទ្ធភាពខ្ពស់។ បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាពក្នុងការបំពេញការងាររបស់ខ្លួនចំពោះក្រុមប្រឹក្សា និងថ្នាក់ដឹកនាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពជ្រើសរើសមន្ត្រីដែលមានសមត្ថភាព និងអាចរក្សាទុកមន្ត្រីទាំងនោះឱ្យបំពេញការងារនៅក្នុងរដ្ឋបាលរបស់ខ្លួន។

***សកម្មភាពជាចម្បង***

- ការរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្ស ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការគ្រប់គ្រង ចាត់ចែងបុគ្គលិករបស់ខ្លួន (ចាប់ពីការជ្រើសរើសរហូតដល់ការចូលនិវត្តន៍)
- ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធវាយតម្លៃគុណផលរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចវាយតម្លៃទៅលើការបំពេញការងារផ្អែកលើការពិពណ៌នាការងារតាមមុខតំណែងនីមួយៗ ដោយរួមបញ្ចូលទាំងការលើកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម។ បន្ទាប់មក ត្រូវធ្វើបច្ចុប្បន្នភាពប្រព័ន្ធវាយតម្លៃគុណផលរបស់បុគ្គលិកនេះ ដើម្បីផ្សារភ្ជាប់ការបំពេញការងាររបស់បុគ្គលិកទៅនឹងចំណុចដៅនានារបស់ស្ថាប័ន ដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការផ្ទេរបុគ្គលិកពីក្រសួង ស្ថាប័ននានាទៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពេលដែលមុខងារនានាត្រូវបានផ្ទេរ
- ការរៀបចំនូវប្រព័ន្ធទិន្នន័យគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជាប្រព័ន្ធអេឡិចត្រូនិចមួយ។ ប្រព័ន្ធទិន្នន័យនេះនឹងគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ
- ការពិនិត្យមើលឡើងវិញអំពីកម្រិតមុខតំណែង ព្រមទាំងការបង្កើតនូវប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រីនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក ដើម្បីជំរុញឱ្យមន្ត្រីស្ម័គ្រចិត្ត និងពេញចិត្តក្នុងការទៅបំពេញការងារនៅថ្នាក់ក្រុង ស្រុក។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានជ្រើសរើសបុគ្គលិកតាមបែបបទ និងនីតិវិធីគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | | ១០០% | ១០០% |
| ភាគរយនៃនាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានវាយតម្លៃដោយគណៈអភិបាលអំពីការបំពេញការងារផ្អែកលើការពិពណ៌នាការងាររបស់ខ្លួន | | ២៥% | ៧៥% |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមុខងារសាធារណៈទទួលខុសត្រូវក្នុងការដឹកនាំការអនុវត្តលទ្ធផលរំពឹងទុកនេះ។

**សមិទ្ធផលរំពឹងទុក ៣.២ ៖ មន្ត្រីរាជការរដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនគ្រប់គ្រាន់ មានចំណេះដឹង មានសមត្ថភាពសមស្រប និងមានក្រមសីលធម៌វិជ្ជាជីវៈល្អក្នុងការបំពេញការងារ និងការទទួលខុសត្រូវរបស់ខ្លួន**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន៣ដូចខាងក្រោម ៖

**លទ្ធផលរំពឹងទុក ៣.២.១ ៖ អនុក្រមនៃការអភិវឌ្ឍសមត្ថភាពត្រូវបានកែលម្អ ដោយរួមបញ្ចូលទាំងវិធីសាស្ត្រ ការធានាគុណភាព និងគណនេយ្យភាពរវាងអ្នកផ្តល់ និងអ្នកទទួលសេវាអភិវឌ្ឍសមត្ថភាព**

***គោលដៅ***

- ការកែលម្អវិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពឱ្យមានគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផលកាន់តែប្រសើរឡើង។

***សកម្មភាពជាចម្បង***

- ការបង្កើតស្តង់ដា និងគោលការណ៍ណែនាំនានាសម្រាប់ការអភិវឌ្ឍសមត្ថភាព
- ការរៀបចំកិច្ចដំណើរការនានានៃការអភិវឌ្ឍសមត្ថភាពផ្អែកលើតម្រូវការ រួមទាំងបញ្ចូលទាំងការរៀបចំនូវយន្តការមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកសំណើសុំការគាំទ្រលើប្រធានបទជាក់លាក់ណាមួយពីស្ថាប័នផ្តល់សេវាអភិវឌ្ឍសមត្ថភាព
- ការផ្សារភ្ជាប់នូវការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានជាមួយនឹងការអភិវឌ្ឍសមត្ថភាព
- ការរៀបចំ និងអនុវត្តសាកល្បងនូវប្រព័ន្ធផ្តល់ថវិកាសម្រាប់ការអភិវឌ្ឍសមត្ថភាពមួយដើម្បីគាំទ្រដល់មន្ត្រីដែលត្រូវចូលរួមវគ្គបណ្តុះបណ្តាល និងលើកទឹកចិត្តអ្នកផ្តល់សេវាអភិវឌ្ឍសមត្ថភាព
- ការរៀបចំប្រព័ន្ធត្រួតពិនិត្យការអភិវឌ្ឍសមត្ថភាព ដើម្បីតាមដានការអនុវត្ត និងលទ្ធផល។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| សេចក្តីណែនាំអំពីការអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាព និងបទពិសោធន៍ល្អៗត្រូវបានដាក់ឱ្យអនុវត្ត | រៀបចំ ប្រើប្រាស់ និងធ្វើរបាយការណ៍ដោយប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ | ប្រើប្រាស់ និង ធ្វើរបាយការណ៍ ដោយប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ | ប្រើប្រាស់ និង ធ្វើរបាយការណ៍ ដោយប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ |

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលថវិកាសម្រាប់អភិវឌ្ឍន៍សមត្ថភាព | ការរៀបចំប្រព័ន្ធផ្តល់ថវិកា | ២០ | ៤០ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

## លទ្ធផលរំពឹងទុក ៣.២.២ ៖ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពត្រូវបានអនុវត្ត

***គោលដៅ***

- ការលើកកម្ពស់ការយល់ដឹង អាកប្បកិរិយា និងជំនាញវិជ្ជាជីវៈរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែល្អប្រសើរឡើង ដើម្បីធានាការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

***សកម្មភាពជាចម្បង***

- ការរៀបចំសកម្មភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបផែននៃការអនុវត្តបណ្តើររៀនបណ្តើរ ឬហៅថាការបណ្តុះបណ្តាលនៅកន្លែងធ្វើការតែម្តង
- ការរៀបចំសកម្មភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបផែននៃការការហ្វឹកហាត់ការងារ ឬការផ្តល់ប្រឹក្សាយោបល់
- ការរៀបចំសកម្មភាពទស្សនកិច្ចសិក្សារបស់ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ខេត្ត ដើម្បីស្វែងយល់អំពីមតិយោបល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តការងាររបស់ខ្លួន សំដៅពិនិត្យ និងកែលម្អបែបផែននៃការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព
- ការរៀបចំសកម្មភាពសម្រាប់ការរៀនសូត្រពីគ្នាទៅវិញទៅមក តាមរយៈសិក្ខាសាលានានា
- ការរៀបចំវេទិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាក្រុង ស្រុក
- ការរៀបចំទស្សនកិច្ចសិក្សារបស់តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិនៅតាមមូលដ្ឋានដែលបានអនុវត្តការងារបានល្អ ឬអនុវត្តបានជោគជ័យនូវគំនិតច្នៃប្រឌិតនានា
- ការបន្តរៀបចំវគ្គបណ្តុះបណ្តាលនៅក្រៅកន្លែងធ្វើការអំពីជំនាញវិជ្ជាជីវៈថ្មីៗ និងដើម្បីធ្វើឱ្យមានការផ្លាស់តរិយាបថ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| %នៃឃុំ សង្កាត់ដែលបានបញ្ចប់សកម្មភាពនានា រួមមាន៖ ការបណ្តុះបណ្តាលចំនួន១លើក ការរៀនសូត្រពីគ្នាទៅវិញទៅមកចំនួន១លើក ការហ្វឹកហាត់ការងារនៅនឹងកន្លែងធ្វើការចំនួន២លើក និងការចុះសិក្សាស្តាប់យោបល់នៅឃុំ សង្កាត់ចំនួន១លើក | ៥០% | ៧០% | ៩០% |

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| %នៃក្រុង ស្រុកដែលបានបញ្ចប់សកម្មភាពនានា រួមមាន៖ ការបណ្តុះបណ្តាលចំនួន២លើក ការរៀនសូត្រពីគ្នាទៅវិញទៅមកចំនួន២លើក វេទិការបស់ក្រុមប្រឹក្សាក្រុង ស្រុកចំនួន១លើក ការហ្វឹកហាត់ការងារនៅនឹងកន្លែងធ្វើការចំនួន២លើក និងការចុះសិក្សាស្តាប់យោបល់នៅថ្នាក់ក្រុង ស្រុកចំនួន១លើក | ៥០% | ៧០% | ៩០% |
| %នៃរាជធានី ខេត្តដែលបានបញ្ចប់សកម្មភាពនានារួមមាន៖ ការបណ្តុះបណ្តាលចំនួន២លើក ការរៀនសូត្រពីគ្នាទៅវិញទៅមកចំនួន២លើក វេទិការបស់ក្រុមប្រឹក្សារាជធានី ខេត្តចំនួន១លើក ការហ្វឹកហាត់ការងារនៅនឹងកន្លែងធ្វើការចំនួន១លើក និងការចុះសិក្សាស្តាប់យោបល់នៅថ្នាក់រាជធានី ខេត្តចំនួន១លើក | ៥០% | ៧០% | ៩០% |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

## លទ្ធផលរំពឹងទុក ៣.២.៣ ៖ ស្ថាប័នទទួលខុសត្រូវលើការអភិវឌ្ឍសមត្ថភាពត្រូវបានរៀបចំ រួមបញ្ចូលទាំងការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន

***គោលដៅ***

- ស្ថាប័នអភិវឌ្ឍសមត្ថភាពនានាផ្តល់សេវាអភិវឌ្ឍសមត្ថភាពប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងនិរន្តរភាព ដើម្បីគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

***សកម្មភាពជាចម្បង***

- ការពង្រឹងសមត្ថភាពនាយកដ្ឋានបណ្តុះបណ្តាលនៃក្រសួងមហាផ្ទៃ ដើម្បីអាចអនុវត្តនូវតួនាទីរបស់ខ្លួនក្នុងការសម្របសម្រួល ការធានាគុណភាព និងការត្រួតពិនិត្យនិងវាយតម្លៃលើការអភិវឌ្ឍសមត្ថភាព
- ការរៀបចំបង្កើតទីចាត់អភិវឌ្ឍសមត្ថភាពនៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីទទួលខុសត្រូវលើការអភិវឌ្ឍសមត្ថភាពជំនួសមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត សំដៅធានានិរន្តរភាពនៃការអភិវឌ្ឍសមត្ថភាព
- ការពង្រឹងសមត្ថភាពសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់ការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព
- ការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| រចនាសម្ព័ន្ធស្ថាប័នផ្តល់សេវាអភិវឌ្ឍសមត្ថភាពត្រូវបានរៀបចំឡើងវិញ និងពង្រឹង | ទីចាត់ការអភិវឌ្ឍន៍សមត្ថភាពរាជធានីខេត្តត្រូវបានបង្កើត | អនុសាសន៍ទទួលបានពីការសិក្សាស្ដាប់យោបល់អំពីការអភិវឌ្ឍសមត្ថភាពត្រូវបានអនុវត្ត | សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវបានដំណើរការ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ឃ. គម្រោងថវិកាប៉ាន់ស្មាន

ថវិកាប៉ាន់ស្មានសម្រាប់ចំណាយលើការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗនៃសមាសភាគនេះ រួមមានដូចខាងក្រោម ៖

**តារាងទី១០ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់សមាសភាគទី៣**

| លទ្ធផលរំពឹងទុក | ថវិកា | | | |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | សរុប |
| ៣.១.១. ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សបែបវិមជ្ឈការត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការតែងតាំង ការផ្ទេរ ការដាក់ពិន័យនិងកិច្ចការដទៃទៀតនៃការងារគ្រប់គ្រងបុគ្គលិករបស់ខ្លួន | 77,918 | 99,369 | 56,470 | **233,757** |
| ៣.២.១. អភិក្រមនៃការអភិវឌ្ឍសមត្ថភាពត្រូវបានកែលម្អ ដោយរួមបញ្ចូលទាំងវិធីសាស្ត្រ ការធានាគុណភាព និងគណនេយ្យភាពរវាងអ្នកផ្តល់ និងអ្នកទទួលសេវាអភិវឌ្ឍសមត្ថភាព | 309,500 | 390,800 | 493,000 | **1,193,300** |
| ៣.២.២. កម្មវិធីអភិវឌ្ឍន៍សមត្ថភាពត្រូវបានអនុវត្ត | 5,092,080 | 4,826,080 | 4,460,080 | **14,378,240** |
| ៣.២.៣. ស្ថាប័នទទួលខុសត្រូវលើការអភិវឌ្ឍសមត្ថភាពត្រូវបានរៀបចំ រួមបញ្ចូលទាំងការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន | 6,519,500 | 3,500,000 | 2,500,000 | **12,519,500** |
| **សរុប** | **11,998,998** | **8,816,249** | **7,509,550** | **28,324,797** |

## ង. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ

ហានិភ័យសំខាន់ៗ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគនេះត្រូវបានកំណត់ដូចខាងក្រោម ៖

## តារាងទី១១៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគទី៣

| ល.រ | ហានិភ័យ | កម្រិត | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|
| ១. | នីតិវិធីនានាស្តីពីការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់មានលក្ខណៈវិមជ្ឈការពេញលេញ ដែលនាំឱ្យមានភាពមិនច្បាស់លាស់នូវគណនេយ្យភាពរបស់បុគ្គលិកចំពោះក្រុមប្រឹក្សា និងគណអភិបាលរបស់ខ្លួន | ទាប | ➢ ការរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីបែបបទ នីតិវិធីគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន |
| ២. | គោលការណ៍នានានៃវិធីសាស្ត្រថ្មីៗសម្រាប់ការអភិវឌ្ឍសមត្ថភាព និងការរៀបចំស្ថាប័នទទួលខុសត្រូវកិច្ចការនេះមានលក្ខណៈមហិច្ឆតាធំធេង ដែលអាចនឹងពិបាកក្នុងការអនុវត្តឱ្យបានសម្រេច | មធ្យម | ➢ នាយកដ្ឋានបណ្តុះបណ្តាលនៃក្រសួងមហាផ្ទៃមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរនូវវិធីសាស្ត្រថ្មីៗទាំងនេះ។ ដោយឡែក ដោយសារសារសំខាន់នៃការអភិវឌ្ឍសមត្ថភាព ទំហំនៃការវិនិយោគ និងវិសាលភាពដ៏ធំធេងនៃការធ្វើឱ្យមានការផ្លាស់ប្តូរ អាស្រ័យហេតុនេះត្រូវមានការគាំទ្រផ្នែកជំនួយបច្ចេកទេសក្នុងចំនួនដ៏សមស្របមួយ<br>➢ ទោះបីជា ការផ្លាស់ប្តូរនេះមានមហិច្ឆិតាធំធេង ក៏ប៉ុន្តែវានឹងធ្វើឱ្យមានការផ្លាស់ប្តូរជាបណ្តើរៗតាមរយៈការអនុវត្តវិធីសាស្ត្រថ្មីៗ<br>➢ ទោះបីជា ការផ្លាស់ប្តូរនេះមានមហិច្ឆិតាធំធេង ក៏ប៉ុន្តែការផ្លាស់ប្តូរនេះមានសារសំខាន់ និងចាំបាច់ត្រូវតែប្រកាន់យកដោយមិនអាចចៀសវាងបាន។ |

# សមាសភាគទី ៤
# ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន

## ក. សេចក្តីផ្តើម

ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះត្រូវការចាំបាច់នូវសិទ្ធិអំណាចជាឆន្ទានុសិទ្ធិដ៏សមស្របដើម្បីមានលទ្ធភាពក្នុងការឆ្លើយតបនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ សិទ្ធិអំណាចសំខាន់ៗទាំងនោះរួមមាន ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងជាពិសេសសិទ្ធិអំណាចក្នុងការដោះស្រាយតម្រូវការនានារបស់សហគមន៍ ការធ្វើសេចក្តីសម្រេច ការផ្តួចផ្តើមគំនិត និងការផ្តល់សេវានានាដែលជាតម្រូវការដ៏ចាំបាច់បំផុតរបស់ប្រជាពលរដ្ឋ។

ជាគោលការណ៍ ការផ្ទេរមុខងារ គឺជាការផ្ទេរការទទួលខុសត្រូវក្នុងការផ្តល់សេវាពីក្រសួង ស្ថាប័ន ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការផ្ទេរមុខងារមានគោលបំណងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវា តាមរយៈការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងការលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្ត និងការវិភាជធនធាននៅមូលដ្ឋាន។

ជាទូទៅ នៅក្នុងប្រព័ន្ធវិមជ្ឈការមួយរួមមាន៖

- ក្រសួង ស្ថាប័នកំណត់អំពីចក្ខុវិស័យ រៀបចំគោលនយោបាយ រៀបចំនិងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្ត និងស្តង់ដានានា។ ក្នុងន័យនេះ ក្រសួង ស្ថាប័នត្រូវមានគណនេយ្យភាពចំពោះការធានាឱ្យមានលទ្ធភាពក្នុងការទទួលបានសេវា ព្រមទាំងគុណភាព និងប្រសិទ្ធិភាពនៃសេវា។ ក្រសួង ស្ថាប័នក៏ត្រូវផ្តល់ការគាំទ្រ និងត្រួតពិនិត្យនីត្យនុកូលភាពនៃការអនុវត្តមុខងារនានា តាមរយៈខេត្ត។
- រដ្ឋបាលមូលដ្ឋានជាអ្នកផ្តល់សេវានានាជូនប្រជាពលរដ្ឋ និងជាអ្នកគ្រប់គ្រងចាត់ចែងសេវាទាំងនោះក្នុងកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន ក៏ដូចជាការចាត់ចែងប្រើប្រាស់បុគ្គលិក និងធនធាននានាក្នុងការផ្តល់សេវាទាំងនោះ។

មុខងារភាគច្រើនដែលបច្ចុប្បន្នកំពុងអនុវត្តដោយការិយាល័យជំនាញរបស់ក្រសួង ស្ថាប័ននៅថ្នាក់ក្រុង ស្រុកនឹងរំពឹងថា ត្រូវបានផ្ទេរទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក។ កិច្ចដំណើរការនឹងធ្វើឱ្យមានការផ្លាស់ប្តូរនូវខ្សែគណនេយ្យភាពរបស់មន្ត្រីនានា ដែលពីមុនមកធ្លាប់មានគណនេយ្យភាពចំពោះក្រសួង ស្ថាប័នរបស់ខ្លួន មកត្រូវមានគណនេយ្យភាពចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិវិញ។ កន្លងមក រដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំរចនាសម្ព័ន្ធ និងបុគ្គលិកឡើងវិញ ក្នុងគោលបំណងធ្វើឱ្យរដ្ឋបាលទាំងនោះអាចផ្តល់នូវសេវានានាដែលបានផ្ទេរពីក្រសួង ស្ថាប័ន។

**មុខងារជាអាណត្តិទូទៅ** នឹងផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវឆន្ទានុសិទ្ធក្នុងការជ្រើសរើស ការ

ទទួលខុសត្រូវ និងកាតព្វកិច្ចក្នុងការដោះស្រាយនូវតម្រូវការជាអាទិភាពចាំបាច់បំផុតនានានៅក្នុងសហគមន៍របស់ខ្លួន។ មុខងារនេះត្រូវបានកំណត់ថា ជាសិទ្ធិក្នុងការផ្តួចផ្តើមគំនិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងការអនុវត្តជាក់ស្តែង មុខងារទាំងនេះរួមមានតែចំនួនតិចតួចប៉ុណ្ណោះ ឧទាហរណ៍ដូចជា ការគ្រប់គ្រងមត្តេយ្យសហគមន៍ជាដើម។ ម្យ៉ាងទៀត មុខងារទាំងនេះអាចជាតម្រូវការជាអាទិភាពមួយដែលក្រសួង ស្ថាប័នណាមួយមិនមានលទ្ធភាពដោះស្រាយបានសមស្រប ឧទាហរណ៍ដូចជាក្នុងករណីដែលសាលាបឋមសិក្សាមួយត្រូវការនូវថ្នាក់រៀនថ្មីមួយ ឬត្រូវការសៀវភៅសិក្សាបន្ថែមទៀត។ ជាទូទៅមុខងារជាអាណត្តិទូទៅត្រូវបានផ្តល់ហិរញ្ញប្បទាន តាមរយៈមូលនិធិគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ ( មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់) ចំណូលផ្ទាល់នៅមូលដ្ឋាន និងចំណូលចែករំលែកពីការប្រមូលពន្ធ។ ជាមួយគ្នានេះដែរ មុខងារជាអាណត្តិទូទៅក៏អាចអនុវត្តក្នុងភាពជាដៃគូជាមួយសហគមន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជននានាផងដែរ។

បច្ចុប្បន្នមាន**សេវារដ្ឋបាល**ជាច្រើនប្រភេទកំពុងត្រូវបានផ្តល់ជូនប្រជាជន តាមរយៈការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ យន្តការនេះជាកន្លែងប្រមូលផ្តុំតែមួយដែលប្រជាពលរដ្ឋអាចមកស្នើសុំ និងទទួលសេវារដ្ឋបាលនានា។ ដោយឡែក ការគាំទ្រផ្នែករដ្ឋបាលក៏ត្រូវបានផ្តល់ឱ្យពីថ្នាក់រដ្ឋបាលមួយទៅថ្នាក់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការគាំទ្រផ្នែករដ្ឋបាលនេះ មានសារសំខាន់ចំពោះរដ្ឋបាលឃុំ សង្កាត់ដែលមានបុគ្គលិករដ្ឋបាលតិចតួច។ យន្តការនេះត្រូវបានបង្កើតឡើងតាមរយៈការបង្កើតនូវការិយាល័យគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក ដើម្បីផ្តល់ការគាំទ្រផ្នែករដ្ឋបាលដល់ឃុំ សង្កាត់។

## ២. វឌ្ឍនភាព និងបញ្ហាប្រឈម

នាពេលកន្លងមក ទោះបីមានវឌ្ឍនភាពជាច្រើនក្នុងកិច្ចដំណើរការរៀបចំផ្ទេរមុខងារក៏ដោយ ក៏ប៉ុន្តែជាក់ស្តែងរួមមានមុខងារមួយចំនួនតូចប៉ុណ្ណោះដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចាប់តាំងពីឆ្នាំ២០១៣ រួមមាន ក្រសួង ស្ថាប័នចំនួន៥បានបញ្ចប់ការវិភាគ និងការពិនិត្យមើលឡើងវិញនូវមុខងារ ព្រមទាំងបានកំណត់នូវមុខងារតូចៗមួយចំនួនដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្ទាប់មកមុខងារផ្តល់សេវាអនាម័យជនបទ និងសេវាថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅជនបទត្រូវបានផ្ទេរក្នុងលក្ខណៈជាការអនុវត្តសាកល្បង។ ផ្អែកលើការពិភាក្សាគ្នាជាបន្តបន្ទាប់ ក្រសួងបរិស្ថានបានសម្រេចចិត្តផ្ទេរមុខងារការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលក្រុង ស្រុក ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចចិត្តផ្ទេរមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុក និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានសម្រេចចិត្តផ្ទេរមុខងារការគ្រប់គ្រងមណ្ឌលកុមារកំព្រាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយឡែក នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ មុខងារសំខាន់ៗចំនួន២៨នៃវិស័យអាទិភាពនានាត្រូវបានរាជរដ្ឋាភិបាលសម្រេចឱ្យរៀបចំផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

គោលការណ៍ នីតិវិធីនៃការគ្រប់គ្រង និងចាត់ចែងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់នៅក្នុងអនុក្រឹត្យលេខ២៨៥ ឆ្នាំ២០១៤។ ជាមួយគ្នានេះ ឯកសារបច្ចេកទេសស្ដីពីការអនុវត្តមុខងារជាជម្រើសក៏ត្រូវបានរៀបចំ និងបណ្ដុះបណ្ដាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងឆ្នាំ២០១៥ផងដែរ។

រហូតមកទល់ចុងឆ្នាំ២០១៦ ការិយាល័យច្រកចេញចូលតែមួយចំនួន៤៦នៅថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ និងបានផ្ដល់សេវារដ្ឋបាលចំនួន២៣២ប្រភេទ ជូនអតិថិជនបានចំនួន៦៦៧.៨១៦នាក់ (មានស្ត្រី២៤%) ដោយប្រមូលចំណូលបានជាង៤លានដុល្លារអាមេរិក។

ដោយសារយន្តការនេះ ត្រូវបានរៀបចំឱ្យមានលក្ខណៈស្ដង់ដាត្រឹមត្រូវសម្រាប់តែនៅតំបន់ដែលមានតម្រូវការសេវារដ្ឋបាលច្រើន អាស្រ័យហេតុនេះ នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវអនុក្រឹត្យដើម្បីផ្ដល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀតអាចបង្កើតនូវយន្តការច្រកចេញចូលតែមួយតាមបែបផែនផ្សេងៗ តាមស្ថានភាពជាក់ស្ដែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនៅទូទាំងប្រទេស។

ទោះបីមានវឌ្ឍភាពជាច្រើនដូចបានរៀបរាប់ខាងលើ ក៏ប៉ុន្តែនៅមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលផអ៣ទី៣ត្រូវដោះស្រាយ រួមមានដូចខាងក្រោម ៖

- ការយល់ដឹងអំពីការផ្ទេរមុខងារនៅមានកម្រិត និងនៅមានបញ្ហាខ្វែងគំនិតគ្នាអំពីបញ្ហានេះ
- ទោះបីមុខងារមួយចំនួនបានផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ ក៏ប៉ុន្តែក្រសួងភាគច្រើននៅពុំទាន់បានរៀបចំផែនការសកម្មភាព និងកម្មវិធីច្បាស់លាស់សម្រាប់គាំទ្រការអនុវត្តមុខងារទាំងនោះនៅឡើយ
- កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការនៅពុំទាន់បានធ្វើសមាហរណកម្មទៅក្នុងកម្មវិធីកំណែទម្រង់ និងថវិការបស់វិស័យពាក់ព័ន្ធនានានៅឡើយ
- មុខងារជាអាណត្តិទូទៅភាគច្រើនអនុវត្តតែទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធនានា ជាជាងលើគម្រោងផ្ដល់សេវាសង្គមនានា ដោយសារការយល់ដឹងអំពីមុខងារជាអាណត្តិទូទៅនៅមានកម្រិត
- ការរៀបចំគោលនយោបាយ ស្ដង់ដារ និងកិច្ចដំណើរការធ្វើអធិការកិច្ចនិងវាយតម្លៃរបស់ក្រសួង ស្ថាប័នទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់ត្រូវបានរៀបចំតាក់តែងឱ្យសមស្របទៅនឹងគោលការណ៍នៃការផ្ដល់សេវាតាមបែបវិមជ្ឈការ
- សមត្ថភាព និងធនធាននានា (បុគ្គលិក និងថវិកា) ត្រូវបានផ្ដល់ភាគច្រើនទៅឱ្យថ្នាក់ខេត្តដែលមានតួនាទីជាស្ថាប័នគាំទ្រ ចំណែកឯរដ្ឋបាលក្រុង ស្រុកដែលមានតួនាទីជាអ្នកផ្ដល់សេវាផ្ទាល់ជូនប្រជាពលរដ្ឋត្រូវបានផ្ដល់សមត្ថភាព និងធនធានតិចតួច
- ប្រជាពលរដ្ឋនៅតំបន់មួយចំនួនពុំទាន់មានលទ្ធភាពទទួលបាននូវការផ្ដល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ

- សេវាគាំទ្រផ្នែករដ្ឋបាលមួយចំនួនដល់ថ្នាក់ឃុំ សង្កាត់ កំពុងត្រូវបានផ្តល់ដោយរដ្ឋបាលខេត្ត ដោយពុំបានផ្តល់ដោយផ្ទាល់ពីរដ្ឋបាលក្រុង ស្រុកនៅឡើយ។

## គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុក និងលទ្ធផលរំពឹងទុកនៃសមាសភាគទី៤នេះមានបរិយាយដូចខាងក្រោម ៖

**សមិទ្ធផលរំពឹងទុក ៤.១ ៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានការផ្តួចផ្តើមគំនិតដោះស្រាយបញ្ហាជាអាទិភាពនានារបស់មូលដ្ឋាន និងផ្តល់សេវានានាតាមរយៈមុខងារជាអាណត្តិទូទៅរបស់ខ្លួន**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន៥ដូចខាងក្រោម ៖

**លទ្ធផលរំពឹងទុក ៤.១.១ ៖ លិខិតបទដ្ឋាននានាសម្រាប់គាំទ្រដល់ការអនុវត្តមុខងារជាអាណត្តិទូទៅ និងការផ្តល់សេវារួមគ្នានៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ**

***គោលដៅ***

តាមរយៈការកែលម្អលិខិតបទដ្ឋានគតិយុត្តិនានាៈ

- រដ្ឋបាលថ្នាក់ក្រោមជាតិពង្រីកនូវវិសាលភាព បរិមាណ និងគុណភាពនៃសេវាដែលត្រូវផ្តល់
- រដ្ឋបាលថ្នាក់ក្រោមជាតិកៀរគរការចូលរួម និងធនធាននានាពីអង្គការសង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីពង្រីកនូវលទ្ធភាពក្នុងការផ្តល់សេវាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សេវានានាត្រូវបានផ្តល់ដោយមានកិច្ចសហការគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល សហគមន៍ និងផ្នែកឯកជនកាន់តែច្រើនឡើង។
- បែបផែននៃភាពជាដៃគូត្រូវបានធ្វើឱ្យប្រសើរឡើងដែលធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបាននូវការយល់ដឹង និងបទពិសោធន៍ល្អៗកាន់តែច្រើនឡើង ដែលអាចជួយពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវានានា។

***សកម្មភាពចម្បង***

- ការរៀបចំបញ្ចប់នូវការពិនិត្យមើលឡើងវិញលើបញ្ហាប្រឈមនានាដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានជួបប្រទះក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅ ដើម្បីឈានទៅដល់ការរៀបចំផែនការសកម្មភាពដែលមានការព្រមព្រៀងគ្នាមួយរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- ការកែសម្រួលនូវលិខិតបទដ្ឋាននានាដែលធ្វើឱ្យមានការលំបាកក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពិនិត្យ និងកែសម្រួលឡើងវិញនូវនីតិវិធី និងការរៀបចំសេចក្តីណែនាំនានាស្តីពីការ

លើកកម្ពស់នូវភាពជាដៃគូប្រកបដោយប្រសិទ្ធភាពជាមួយអង្គការសង្គមស៊ីវិល ផ្នែកឯកជន និងសហគមន៍ ដើម្បីគៀរគរធនធាននានា និងការរួមគ្នាក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| %នៃអនុសាសន៍នានាត្រូវបានអនុវត្តតាមរយៈផែនការសកម្មភាពរួម ដើម្បីដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការអនុវត្តមុខងារជាអាណត្តិទូទៅ | ការបញ្ចប់ការពិនិត្យឡើងវិញ | ២៥% | ៧៥% |
| %នៃកំណើនលើការចំណាយរបស់ក្រុង ស្រុក និងឃុំ សង្កាត់សម្រាប់អនុវត្តគម្រោងផ្តល់សេវាសង្គម និងសុវត្ថិភាពសង្គម (ធៀបនឹងទិន្នន័យឆ្នាំ២០១៧) | ២៥% | ១០០% | ២០០% |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប ជាស្ថាប័នដឹកនាំការសិក្សា ពិនិត្យឡើងវិញ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ អង្គការសង្គមស៊ីវិលនឹងចូលរួមក្នុងការសិក្សាវិភាគទៅលើកកម្ពស់ប្រសិទ្ធភាពនៃភាពជាដៃគូ និងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក។ ការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋាន និងនីតិវិធីនានាជាការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផែនការ។

## លទ្ធផលរំពឹងទុក ៤.១.២ ៖ សេចក្តីណែនាំស្តីពីបទពិសោធន៍ល្អផ្អែកលើភស្តុតាងជាក់លាក់ក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅត្រូវបានរៀបចំ និងផ្សព្វផ្សាយ

***គោលដៅ***

- ការពង្រឹងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខណ្ឌនៃមុខងារជាអាណត្តិទូទៅ តាមរយៈការផ្តល់នូវការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានដោយផ្អែកលើភស្តុតាងជាក់លាក់ និងការរៀបចំជាសេចក្តីណែនាំជាក់លាក់
- ការលើកកម្ពស់នូវការអនុវត្តតាមបទពិសោធន៍ល្អនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា ។

***សកម្មភាពជាចម្បង***

- ការប្រមូលចងក្រងជាបញ្ជីគម្រោង សកម្មភាពនៃការផ្តល់សេវាសំខាន់ៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការអនុវត្តមុខងារជាអាណត្តិទូទៅ តាមរយៈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា
- ការសម្រិតសម្រាំង និងជ្រើសរើសយកគម្រោង សកម្មភាពនានាដែលទទួលបានជោគជ័យ

- ការរៀបចំសេចក្ដីណែនាំជាក់លាក់សម្រាប់ការអនុវត្តនូវមុខងារជាអាណត្តិទូទៅ ដោយរួមបញ្ចូលនូវបញ្ជីសេវាសំខាន់ៗ បទពិសោធន៍ល្អៗ ព័ត៌មានសំខាន់ៗ និងអាសយដ្ឋានទំនាក់ទំនង
- ការអនុវត្តនូវសកម្មភាពអភិវឌ្ឍសមត្ថភាព ព្រមទាំងការប្រាស័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានដើម្បីធានាដល់ការប្រើប្រាស់នូវសេចក្ដីណែនាំនានា
- ការពិនិត្យ និងកែសម្រួលសេចក្ដីណែនាំស្ដីពីបទពិសោធន៍ល្អជារៀងរាល់ឆ្នាំ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនសរុបនៃបទពិសោធន៍ល្អៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងចងក្រងជាឯកសារសម្រាប់កម្មវិធីសិក្សារៀនសូត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ១៥ | ៣០ | ៤៥ |
| សេចក្ដីណែនាំអំពីបទពិសោធន៍ល្អៗនៃការអនុវត្តមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបាដាក់ឱ្យអនុវត្ត និងកែលម្អប្រចាំឆ្នាំ | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត |
| ចំនួនសរុបរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុវត្តតាមបទពិសោធន៍ល្អៗ | | ១០ | ៣០ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុក ៤.១.៣ ៖ ការផ្ដល់នូវកញ្ចប់ថវិកានានាសម្រាប់គាំទ្រដល់ការអនុវត្តមុខងារជាអាណត្តិទូទៅត្រូវបានអនុវត្តសាកល្បង រួមមានកញ្ចប់ថវិកាសម្រាប់ការផ្ដល់សេវាដែលជាគំនិតផ្ដួចផ្ដើមរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងផ្នែកឯកជន**

***គោលដៅ***

- ការជំរុញឱ្យមានគំនិតផ្ដួចផ្ដើមប្រកបដោយការច្នៃប្រឌិត និងការកំណត់អំពីបទពិសោធន៍ល្អៗនៃការអនុវត្តមុខងារជាអាណត្តិទូទៅដែលអាចយកមកធ្វើជាគំរូសម្រាប់អនុវត្តតាម
- ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ និងការកៀរគរធនធាននានា
- ការធ្វើឱ្យមុខងារជាអាណត្តិទូទៅកាន់តែមានប្រសិទ្ធភាពសម្រាប់រយៈពេលយូរអង្វែង តាមរយៈការកែលម្អនូវគោលនយោបាយនានាដែលផ្ដើមចេញពីការអនុវត្តសាល្បងនូវយន្តការផ្ដល់កញ្ចប់ថវិកានានា។

***សកម្មភាពជាចម្បង***

- ការរៀបចំឯកសារទស្សនាទាន និងសំណើគម្រោងទាំងឡាយសម្រាប់ការរៀបចំបង្កើតជាកញ្ចប់ថវិកានានា ដែលរួមមានការកំណត់អំពីគោលបំណង វិសាលភាព ការផ្តល់ហិរញ្ញប្បទានរួមគ្នា គោលការណ៍នៃកិច្ចប្រតិបត្តិការ លក្ខណៈសម្បត្តិដែលសមស្រប និងបែបផែននៃការគ្រប់គ្រង ព្រមទាំងការកំណត់អំពីតម្រូវការនៃការផ្តល់ហិរញ្ញប្បទានដែលអាចអនុវត្តសាកល្បង
- ការកៀរគរ ឬការស្វែងរកធនធានសម្រាប់កញ្ចប់ថវិកានីមួយៗ
- ការអនុវត្តសាកល្បងនូវការប្រើប្រាស់កញ្ចប់ថវិកានីមួយៗ និងការផ្សព្វផ្សាយអំពីមេរៀនបទពិសោធន៍ទាំងនោះ
- ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើការអនុវត្តកញ្ចប់ថវិកានីមួយៗ ដើម្បីធ្វើការសម្រេចចិត្តក្នុងការពង្រីក និងធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធរបស់រាជរដ្ឋាភិបាល។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនសរុបនៃគម្រោងសហគមន៍ដែលផ្តល់ហិរញ្ញប្បទានពីកញ្ចប់ថវិកានៃភាពជាដៃគូជាមួយសហគមន៍មូលដ្ឋាន | ០ | ៣០ | ៩០ |
| ចំនួនសរុបនៃគម្រោង សកម្មភាពជាគំនិតផ្តួចផ្តើមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានផ្តល់ហិរញ្ញប្បទានពីកញ្ចប់ថវិកានៃការផ្តួចផ្តើមគំនិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ០ | ១០ | ២០ |
| ចំនួនសរុបនៃគម្រោង សកម្មភាពអនុវត្តរួមគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលដែលបានផ្តល់ហិរញ្ញប្បទានពីកញ្ចប់ថវិកានៃភាពជាដៃគូជាមួយសង្គមស៊ីវិល | ០ | ៥ | ១០ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

ក្រសួងមហាផ្ទៃទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប និងដៃគូអភិវឌ្ឍន៍នានា។

## លទ្ធផលរំពឹងទុក ៤.១.៤ ៖ រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ត្រូវបានគាំទ្រ ដើម្បីលើកកម្ពស់ការអនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន

***គោលដៅ***

- រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់បំពេញមុខងារជាអាណត្តិទូទៅរបស់ខ្លួនកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់មានការយល់ដឹងអំពីមុខងារជាអាណត្តិទូទៅកាន់

តែប្រសើរឡើង និងមានការផ្តួចផ្តើមគំនិតកាន់តែច្រើនក្នុងការបំពេញមុខងារជាអាណត្តិទូទៅរបស់ខ្លួន។

***សកម្មភាពជាចម្បង***

- ការរៀបចំ និងអនុវត្តសាកល្បងនូវឯកសារបច្ចេកទេសនានាដើម្បីជួយគាំទ្រដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅ
- ការរៀបចំ និងអនុវត្តសាកល្បងនូវឯកសារបច្ចេកទេសនានាសម្រាប់វិស័យជាក់លាក់ ដូចជាការអប់រំបឋមសិក្សា និងសុខាភិបាល ដើម្បីជួយរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន សំដៅគាំទ្រដល់មុខងាររបស់ក្រសួង ស្ថាប័នពិសេសទៅលើមុខងារទាំងឡាយណាដែលរំពឹងថានឹងត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការសម្របសម្រួល ការហ្វឹកហាត់ការងារ ការផ្តល់ប្រឹក្សាយោបល់ និងការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីបំពេញមុខងារជាអាណត្តិទូទៅរបស់ខ្លួន
- ការវាយតម្លៃទៅលើប្រសិទ្ធភាពនៃកិច្ចដំណើរការសម្របសម្រួល គាំទ្រនានា និងការកែសម្រួលតាមការចាំបាច់។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនសរុបនៃរដ្ឋបាលឃុំ សង្កាត់ដែលត្រូវបានសម្របសម្រួលគាំទ្រដើម្បីបំពេញមុខងារជាអាណត្តិទូទៅឱ្យកាន់តែប្រសើរឡើង | ២៥ | ១៥០ | ៤០០ |
| ចំនួនសរុបនៃរដ្ឋបាលក្រុង ស្រុកដែលត្រូវបានសម្របសម្រួលគាំទ្រដើម្បីបំពេញមុខងារជាអាណត្តិទូទៅឱ្យកាន់តែប្រសើរឡើង | ២៥ | ១០០ | ១៨៥ |

**ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត**

ក្រសួងមហាផ្ទៃទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ។

## លទ្ធផលរំពឹងទុក ៤.១.៤ ៖ គម្រោងនៃការប្រែប្រួលអាកាសធាតុ សេវាសង្គម និងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានត្រូវបានអនុវត្ត និងដាក់បញ្ចូលទៅក្នុងប្រព័ន្ធរបស់រដ្ឋ

***គោលដៅ***

- រដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់នូវថវិការបស់ខ្លួនដើម្បីដោះស្រាយនូវតម្រូវការ និងបញ្ហានានាពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការផ្តល់សេវាសង្គម និងការប្រែប្រួលអាកាសធាតុនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

***សកម្មភាពជាចម្បង***

- ការបន្តអនុវត្តគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលមានបច្ចុប្បន្ន
- ការបន្តអនុវត្តគម្រោងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងគម្រោងសេវាសង្គមដែលមានបច្ចុប្បន្ន

- ការខិតខំកៀរគរមូលនិធិថ្មីៗបន្ថែមទៀតពីដៃគូអភិវឌ្ឍន៍នានា ជាពិសេសពីមូលនិធិអាកាសធាតុបៃតង
- ការកំណត់នូវគោលការណ៍ ឬល័ក្ខខ័ណ្ឌនានាដើម្បីធានាថា គម្រោងដោយឡែកៗទាំងនេះត្រូវបានសម្របសម្រួល និងធ្វើសុខដុមនីយកម្មបានយ៉ាងល្អប្រសើរ ហើយគម្រោងទាំងនេះអាចមាននិរន្តរភាពតាមរយៈការប្រើប្រាស់ប្រព័ន្ធ បែបបទ នីតិវិធី និងថវិការបស់រដ្ឋាភិបាល
- ការរៀបចំ និងអនុវត្តនូវវិធីសាស្ត្រមួយ ដើម្បីពង្រឹង និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តគម្រោង សកម្មភាពផ្តល់សេវាសង្គមនានា
- ការរៀបចំ និងអនុវត្តនូវវិធីសាស្ត្រមួយ ដើម្បីពង្រឹង និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តគម្រោង សកម្មភាពលុបបំបាត់អំពើហឹង្សាលើស្ត្រី និងកុមារ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| %នៃគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងសេវាសង្គមបានផ្ទេរថវិកាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយប្រើប្រាស់ប្រព័ន្ធរតនាគារជាតិ | ២០% | ៤០% | ៦០% |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ។

## សមិទ្ធផលរំពឹងទុក ៤.២ ៖ ប្រសិទ្ធភាពនៃការផ្តល់សេវាត្រូវបានបង្កើន តាមរយៈការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន៤ដូចខាងក្រោម៖

### លទ្ធផលរំពឹងទុក ៤.២.១ ៖ លិខិតបទដ្ឋានគតិយុត្ត និងឧបករណ៍នានាសម្រាប់ការផ្ទេរ និងការអនុវត្តមុខងារនានាត្រូវបានរៀបចំបញ្ចប់

***គោលដៅ***

ការធ្វើឱ្យប្រសើរឡើងនូវគុណភាព ប្រសិទ្ធភាព តម្លាភាព និងភាពងាយស្រួលក្នុងការទទួលបានសេវាសាធារណៈនានា តាមរយៈការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលមូលដ្ឋានចំពោះប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាទាំងនោះ។

***សកម្មភាពជាចម្បង***

- ការរៀបចំ និងអនុវត្តសាកល្បងនូវវិធីសាស្ត្រ និងឧបករណ៍នានាសម្រាប់សិក្សាវាយតម្លៃទៅលើការចំណាយ និងធនធាននានាដែលចាំបាច់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារដែលបានផ្ទេរ ដោយផ្អែកតាមស្តង់ដានៃការផ្តល់សេវា

- ការរៀបចំលិខិតបទដ្ឋានណែនាំសម្រាប់ការធ្វើប្រតិភូកម្មនូវមុខងារ និងលិខិតបទដ្ឋានណែនាំអំពីការផ្លាស់ប្តូរពីការធ្វើប្រតិភូកម្មមុខងារទៅជាការប្រគល់មុខងារ
- ការសិក្សាវិភាគដើម្បីរៀបចំការគាំទ្រដល់ការផ្ទេរមុខងារនីមួយៗ
- ការរៀបចំប្រកាស ឬអនុក្រឹត្យដើម្បីធ្វើប្រតិភូកម្ម ឬប្រគល់មុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំលិខិតបទដ្ឋាននានាសម្រាប់អនុវត្តប្រកាស ឬអនុក្រឹត្យទាំងនោះ

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនសរុបនៃការសិក្សាវាយតម្លៃនានាអំពីការចំណាយ និងធនធានសម្រាប់ការអនុវត្តមុខងារដែលត្រូវផ្ទេរ | ៤ | ១១ | ១១ |
| ចំនួនសរុបនៃក្រសួង ស្ថាប័នដែលបានរៀបចំបញ្ចប់ទាំងស្រុងនូវលិខិតបទដ្ឋាន និងឧបករណ៍នានាសម្រាប់ការធ្វើប្រតិភូកម្ម ឬការប្រគល់មុខងារ | ៥ | ១០ | ១៤ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងក្រសួង ស្ថាប័ននានាពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

## លទ្ធផលរំពឹងទុក ៤.២.២ ៖ ផែនការសកម្មភាព និងថវិកាត្រូវបានរៀបចំ និងអនុម័តសម្រាប់ការអនុវត្តអនុក្រឹត្យ ឬប្រកាស និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការផ្ទេរមុខងារ

***គោលដៅ***

រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ ឬការិយាល័យជំនាញដែលបានទទួលនូវមុខងារតាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្ម មានសមត្ថភាព មានផែនការច្បាស់លាស់ និងមានធនធានសមស្របសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរ។

***សកម្មភាពជាចម្បង***

- ការរៀបចំ និងអនុម័តផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តអនុក្រឹត្យ ឬប្រកាស និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការផ្ទេរមុខងារនីមួយៗ ដោយក្រសួង ស្ថាប័នសាមី និងមានការឯកភាពពីលេខាធិការដ្ឋាន គ.ជ.អ.ប។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនសរុបនៃផែនការសកម្មភាព និងថវិកាដែលបានអនុម័ត | ៦ | ១២ | ១៤ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួង ស្ថាប័នផ្ទេរមុខងារ និងលេខាធិការធិការដ្ឋាន គ.ជ.អ.ប។

### លទ្ធផលរំពឹងទុក ៤.២.៣ ៖ មុខងារដែលបានផ្ទេរត្រូវបានអនុវត្តតាមវិធីសាស្ត្រនៃការគ្រប់គ្រងតាមបែបផែនជាគម្រោង

#### សកម្មភាពជាចម្បង

- ការរៀបចំគម្រោង ឬកម្មវិធីដើម្បីអនុវត្តមុខងារដែលបានផ្ទេរស្របតាមផែនការសកម្មភាព និងថវិកា
- ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមស្របពេលដែលមុខងារត្រូវបានផ្ទេរ តាមរយៈការអភិវឌ្ឍន៍សមត្ថភាពរបស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ និងការិយាល័យពាក់ព័ន្ធដទៃទៀត ការផ្តល់ប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សា និងត្រួតពិនិត្យនូវផលប៉ះពាល់ផ្សេងៗពាក់ព័ន្ធនឹងមុខងារដែលបានផ្ទេរ
- ការត្រួតពិនិត្យ និងវាយតម្លៃទៅលើការផ្ទេរមុខងារនីមួយៗ ដោយប្រៀបធៀបទៅនឹងទិន្នន័យដើមគ្រា ព្រមទាំងប្រៀបធៀបនូវលទ្ធផលនៃការផ្តល់សេវារវាងតំបន់គោលដៅ និងតំបន់ក្រៅគោលដៅ។

#### ចំណុចដៅ

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនរដ្ឋបាលខេត្តដែលរដ្ឋបាលក្រុង ស្រុកបានអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរ | ០ | ១ | ២ |
| ចំនួនសរុបនៃរដ្ឋបាលស្រុកដែលអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | ៥ | ៥០ | ១០០ |
| ចំនួនសរុបនៃរដ្ឋបាលក្រុងដែលបានអនុវត្តមុខងារទីប្រជុំជនដែលបានផ្ទេរឱ្យយ៉ាងតិចចំនួន០២មុខងារ | | ១០ | ២៦ |
| ចំនួនធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌដែលផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ (គិតជាលានដុល្លារ) | ២ | ៤ | ៨ |

#### ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត

ក្រសួង ស្ថាប័នផ្ទេរមុខងារនីមួយៗទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានការសម្របសម្រួល និងការត្រួតពិនិត្យរួមគ្នាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប។

### លទ្ធផលរំពឹងទុក ៤.២.៤ ៖ យន្តការច្រកចេញចូលតែមួយត្រូវបានពង្រីកទាំងតំបន់គោលដៅ និងប្រភេទសេវា

#### គោលដៅ

- ការបង្កលក្ខណៈកាន់តែងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ
- ការលើកកម្ពស់ទាំងគុណភាព និងបរិមាណនៃសេវារដ្ឋបាលដែលបានផ្តល់
- ការធានានិរន្តរភាពនៃកិច្ចប្រតិបត្តិការរបស់យន្តការច្រកចេញចូលតែមួយ។

***សកម្មភាពចម្បង***

- ការពង្រីកយន្តការច្រកចេញចូលតែមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅដទៃទៀត
- ការបន្តពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ
- ការសិក្សាអំពីលទ្ធភាពក្នុងការរៀបចំការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (អនឡាញ) នៅយន្តការច្រកចេញចូលតែមួយ។
- ការសិក្សា និងវាយតម្លៃដើម្បីជាមូលដ្ឋានធានានិរន្តរភាពនៃកិច្ចប្រតិបត្តិការរបស់យន្តការច្រកចេញតែមួយនៅរដ្ឋបាលថ្នាក់ជាតិ

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនប្រជាពលរដ្ឋដែលទទួលបានសេវារដ្ឋបាលតាមរយៈយន្តការច្រកចេញចូលតែមួយ | ៧៥០.០០០ | ៩០០.០០០ | ១.៣០០០.០០០ |
| ចំនួនសរុបនៃប្រភេទសេវារដ្ឋបាលដែលផ្តល់ដោយយន្តការច្រកចេញចូលតែមួយ | ២៤០ | ២៤៥ | ២៥៥ |
| ចំនួនសរុបនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ | ១០០ | ១៥០ | ១៧៥ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

## សមិទ្ធផលរំពឹងទុក៤.៣៖ ក្រសួង ស្ថាប័ននានារៀបចំ និងអនុវត្តគោលនយោបាយ លិខិតបទដ្ឋាន និងស្តង់ដានានាស្របតាមគោលនយោបាយវិមជ្ឈការ

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន១ដូចខាងក្រោម ៖

### លទ្ធផលរំពឹងទុក ៤.៣.១ ៖ យុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងស្តង់ដានានារបស់ក្រសួង ស្ថាប័នត្រូវបានពិនិត្យមើល និងកែសម្រួលឡើងវិញស្របតាមគោលនយោបាយនៃវិមជ្ឈការ

***គោលដៅ***

- ក្រសួង ស្ថាប័នរៀបចំក្របខ័ណ្ឌគតិយុត្ត ដែលមានសមហេតុផល មានភាពពាក់ព័ន្ធ និងធានាឱ្យមានតុល្យភាពសមស្របរវាងការត្រួតពិនិត្យពីលើ និងស្វ័យភាពរបស់រដ្ឋបាលថ្នាក់

ក្រោមជាតិ

- ស្តង់ដានានារបស់ក្រសួង ស្ថាប័នក្នុងការផ្តល់សេវា ត្រូវបានប្រើប្រាស់សម្រាប់ការវិភាជថវិកាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្រសួង ស្ថាប័នសម្រេចបាននូវគោលដៅរបស់ខ្លួនតាមរយៈការរៀបចំនូវលិខិតបទដ្ឋាន និងស្តង់ដានានាដែលមានលក្ខណៈល្អប្រសើរ និងមានការលើកទឹកចិត្ត។

***សកម្មភាពជាចម្បង***

- ការធ្វើសមាហរណកម្មគោលនយោបាយវិមជ្ឈការទៅក្នុងយុទ្ធសាស្ត្រ កម្មវិធី ផែនការ និងថវិការបស់ក្រសួង ស្ថាប័ន
- ការសិក្សាវិភាគលើការបំពេញការងារផ្អែកលើស្តង់ដានាពេលបច្ចុប្បន្ន ដើម្បីរៀបចំឱ្យមានជាទិន្នន័យដើមគ្រាក្នុងគោលបំណងកែសម្រួលនូវស្តង់ដាឱ្យមានភាពសមស្រប
- ការអភិវឌ្ឍសមត្ថភាពរបស់ក្រសួង ស្ថាប័នក្នុងការរៀបចំគោលនយោបាយ លិខិតបទដ្ឋាននានាស្របនឹងគោលនយោបាយវិមជ្ឈការ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនសរុបនៃក្រសួង ស្ថាប័នដែលបានពិនិត្យ និងកែសម្រួលឡើងវិញនូវលិខិតបទដ្ឋាន និងស្តង់ដារនានាស្របនឹងគោលនយោបាយវិមជ្ឈការ | ១ | ៣ | ៥ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួង ស្ថាប័នផ្ទេរមុខងារនានាទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយមានកិច្ចសហការជាមួយគណៈកម្មាធិការកំណែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានគ.ជ.អ.ប ។

## សមិទ្ធផលរំពឹងទុក៤.៤ ៖ ខេត្តផ្តល់អន្តរាគមន៍ដល់ក្រុង ស្រុក និងឃុំ សង្កាត់ ដោយឡែកក្រុង ស្រុកផ្តល់ការគាំទ្រផ្នែករដ្ឋបាលដល់ឃុំ សង្កាត់

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន២ដូចខាងក្រោម ៖

### លទ្ធផលរំពឹងទុក ៤.៤.១ ៖ រចនាសម្ព័ន្ធ និងតួនាទីរបស់ខេត្តត្រូវបានកែសម្រួល និងពង្រឹងដើម្បីផ្តល់អន្តរាគមន៍ និងត្រួតពិនិត្យការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន

***គោលដៅ***

- ការកែលម្អគុណភាពនៃការផ្តល់សេវាគាំទ្រ និងការត្រួតពិនិត្យផ្តល់យោបល់របស់ខេត្ត
- មុខងារគាំទ្រត្រូវបានរៀបចំបានសមស្របតាមតម្រូវការរបស់រដ្ឋបាលក្រុង ស្រុក និងឃុំសង្កាត់

***សកម្មភាពជាចម្បង***

- ការកែសម្រួលរចនាសម្ព័ន្ធ តួនាទី ការទទួលខុសត្រូវ បុគ្គលិក ថវិកា និងប្រព័ន្ធរបាយការណ៍ របស់ស្ថាប័ននានានៅថ្នាក់ខេត្ត (រដ្ឋបាលខេត្ត និងមន្ទីរជំនាញនានា) ក្នុងនាមជាស្ថាប័នផ្តល់អន្តរាគមន៍ និងត្រួតពិនិត្យការបំពេញការងាររបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់
- ការកែលម្អនីតិវិធីនានានៃប្រព័ន្ធគាំទ្ររបស់ខេត្តដោយរាប់បញ្ចូលទាំងការផ្តល់ប្រឹក្សាយោបល់ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់
- ការសិក្សាវិភាគដើម្បីកែសម្រួលការវិភាជថវិកាទៅឱ្យខេត្តក្នុងនាមជាអ្នកគាំទ្រ និងត្រួតពិនិត្យ និងទៅឱ្យក្រុង ស្រុក និងឃុំ សង្កាត់ក្នុងនាមជាអ្នកផ្តល់សេវា។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| រចនាសម្ព័ន្ធ តួនាទី ការទទួលខុសត្រូវ បុគ្គលិក ថវិកា និងប្រព័ន្ធរបាយការណ៍របស់ស្ថាប័ននានានៅថ្នាក់ខេត្តត្រូវបានកែសម្រួល | បានបញ្ចប់ការសិក្សា | បានកែសម្រួល | |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយសហការជាមួយ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**លទ្ធផលរំពឹងទុក ៤.៤.២ ៖ រដ្ឋបាលក្រុង ស្រុកត្រូវបានពង្រឹងដើម្បីផ្តល់អន្តរាគមន៍ និងគាំទ្រផ្នែករដ្ឋបាលដល់ឃុំ សង្កាត់**

***គោលដៅ***

- ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាគាំទ្រផ្នែករដ្ឋបាលរបស់ក្រុង ស្រុក ដល់ឃុំ សង្កាត់

***សកម្មភាពជាចម្បង***

- ការពិនិត្យឡើងវិញនូវតួនាទីរបស់រដ្ឋបាលក្រុង ស្រុកក្នុងការគាំទ្រឃុំ សង្កាត់ ដោយរួមបញ្ចូលទាំងប្រព័ន្ធគ្រប់គ្រងព័ត៌មានដែលពេលបច្ចុប្បន្នបាននឹងកំពុងអនុវត្តនៅថ្នាក់ខេត្ត និងការកំណត់អំពីបញ្ហាប្រឈមនានារបស់ការិយាល័យគាំទ្រឃុំ សង្កាត់ក្នុងការអនុវត្តនូវតួនាទីរបស់ខ្លួន។
- ការពិនិត្យ និងកែសម្រួលឡើងវិញនូវប្រព័ន្ធ និងនីតិវិធីនៃការគាំទ្រផ្នែករដ្ឋបាលដល់ឃុំ សង្កាត់ ដែលត្រូវផ្ទេរពីថ្នាក់ខេត្តទៅឱ្យថ្នាក់ក្រុង ស្រុក។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| លិខិតបទដ្ឋានណែនាំអំពីបែបផែននៃការគាំទ្រផ្នែករដ្ឋបាលដល់ឃុំ សង្កាត់ត្រូវបានកែលម្អ | បញ្ចប់ការពិនិត្យមើលឡើងវិញ | លិខិតបទដ្ឋានដែលបានកែសម្រួលត្រូវបានអនុវត្ត | |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងមហាផ្ទៃទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ ដោយសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ឃ. គម្រោងថវិកាប៉ាន់ស្មាន

ថវិកាប៉ាន់ស្មានសម្រាប់ចំណាយលើការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗនៃសមាសភាគនេះ រួមមានដូចខាងក្រោម ៖

**តារាងទី១២ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់សមាសភាគទី៤**

| លទ្ធផលរំពឹងទុក | ថវិកា | | | |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | សរុប |
| ៤.១.១. លិខិតបទដ្ឋាននានាសម្រាប់គាំទ្រដល់ការអនុវត្តមុខងារជាអាណត្តិទូទៅ និងការ ផ្តល់សេវារួមគ្នានៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ | 140,400 | 76,050 | 46,800 | 263,250 |
| ៤.១.២. សេចក្តីណែនាំស្តីពីបទពិសោធន៍ល្អផ្អែកលើភស្តុតាងជាក់លាក់ក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅត្រូវបានរៀបចំ និងផ្សព្វផ្សាយ | 44,918 | 87,819 | 87,820 | 220,557 |
| ៤.១.៣. ការផ្តល់មូលនិធិគាំទ្រដល់ការអនុវត្តមុខងារជាអាណត្តិទូទៅត្រូវបានអនុវត្តសាកល្បង រួមបញ្ចូលទាំងធនធានសម្រាប់ការផ្តល់សេវារួមគ្នាដែលជាគំនិតផ្តួចផ្តើមរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន | 96,800 | 467,500 | 1,329,350 | 1,893,650 |
| ៤.១.៤. រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ត្រូវបានគាំទ្រដើម្បីលើកកម្ពស់ការអនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន | 95,800 | 31,450 | 31,450 | 158,700 |
| ៤.១.៥. គម្រោងនៃការប្រែប្រួលអាកាសធាតុ សេវាសង្គម និងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានត្រូវបាន អនុវត្ត និងដាក់បញ្ចូលទៅក្នុងប្រព័ន្ធរបស់រដ្ឋ | 31,065,268 | 34,588,139 | 40,865,451 | 106,518,857 |
| ៤.២.១. លិខិតបទដ្ឋានគតិយុត្ត និងឧបករណ៍នានាសម្រាប់ការផ្ទេរ និងការអនុវត្តមុខងារនានាត្រូវបានរៀបចំបញ្ចប់ | 468,300 | 481,500 | 135,000 | 1,084,800 |
| ៤.២.២. ផែនការសកម្មភាព និងថវិកាត្រូវបានរៀបចំ និងអនុម័តសម្រាប់ការអនុវត្តអនុក្រឹត្យ ឬប្រកាស និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការផ្ទេរមុខងារ | 150,000 | 150,000 | 50,000 | 350,000 |
| ៤.២.៣. មុខងារដែលបានផ្ទេរត្រូវបានអនុវត្តតាមវិធីសាស្ត្រនៃការគ្រប់គ្រងតាមបែបផែនជាគម្រោង | 198,000 | 946,000 | 1,562,000 | 2,706,000 |
| ៤.២.៤. យន្តការច្រកចេញចូលតែមួយត្រូវបានពង្រីកទាំងតំបន់គោលដៅ និងប្រភេទសេវា | 7,600,000 | 2,500,000 | 3,000,000 | 13,100,000 |

| លទ្ធផលរំពឹងទុក | ថវិកា | | | |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | សរុប |
| ៤.៣.១. យុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងស្តង់ដានានារបស់ក្រសួង ស្ថាប័នត្រូវបានពិនិត្យមើល និងកែសម្រួលឡើងវិញស្របតាមគោលនយោបាយនៃវិមជ្ឈការ | 113,850 | 227,700 | 227,700 | 569,250 |
| ៤.៤.១. រចនាសម្ព័ន្ធ និងតួនាទីរបស់ខេត្តត្រូវបានកែសម្រួល និងពង្រឹងដើម្បីផ្តល់អន្តរាគមន៍ និងត្រួតពិនិត្យការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន | 37,950 | 141,900 | 174,900 | 354,750 |
| ៤.៤.២. រដ្ឋបាលក្រុង ស្រុកត្រូវបានពង្រឹងដើម្បីផ្តល់អន្តរាគមន៍ និងគាំទ្រផ្នែករដ្ឋបាលដល់ឃុំ សង្កាត់ | 61,650 | 22,600 | 20,000 | 104,250 |
| **សរុប** | **40,072,936** | **39,720,658** | **47,530,471** | **127,324,064** |

## ខ. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ

ហានិភ័យសំខាន់ៗ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគនេះត្រូវបានកំណត់ និងមានរៀបរាប់ដូចខាងក្រោម ៖

**តារាងទី១៣៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគទី៤**

| ល.រ | ហានិភ័យ | កម្រិត | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|
| ១. | រដ្ឋបាលថ្នាក់ក្រោមជាតិពុំមានការផ្តួចផ្តើមគំនិតឱ្យបានច្រើនក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន | មធ្យម | ➢ ការរៀបចំផែនការឱ្យបានច្បាស់លាស់ក្នុងការអភិវឌ្ឍសមត្ថភាព ព្រមទាំងការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន ដើម្បីធានាឱ្យមានការផ្លាស់ប្តូរឥរិយាបថ<br>➢ ការរៀបចំមូលនិធិនានាដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តួចផ្តើមគំនិត និងការបង្កើតភាពជាដៃគូជាមួយសហគមន៍ និងសង្គមស៊ីវិល<br>➢ ការរៀបចំ និងអនុវត្តកម្មវិធីសម្រាប់គាំទ្រការអនុវត្តមេរៀន និងបទពិសោធន៍ល្អៗនានា<br>➢ ការកំណត់ និងដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការអនុវត្តមុខងារជាអាណត្តិទូទៅ<br>➢ ការបន្តរៀបចំ និងអនុវត្តគម្រោង កម្មវិធីនានាដើម្បីគាំទ្រដល់ការកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន ការប្រែប្រួលអាកាសធាតុ និងការផ្តល់សេវាសង្គម<br>➢ ការពង្រឹងភាពផ្សារភ្ជាប់គ្នារវាងមុខងារជាណត្តិទូទៅ និងសេវាសង្គមនានា ក្នុងពេលដែលមុខងារសេវាសង្គមនានាត្រូវបានផ្ទេរទៅឱ្យ |
| ២. | ក្រសួង ស្ថាប័ននៅមានភាពស្ទាក់ស្ទើរក្នុងការផ្ទេរមុខងារ | មធ្យម | ➢ ការគាំទ្រ និងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នដែលមានមានការតាំងចិត្តមុតមាំក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ<br>➢ ការបន្តគាំទ្រដល់ក្រសួង ស្ថាប័នផ្សេងទៀតៗដើម្បីធានាឱ្យមានការផ្ទេរមុខងារជាបណ្តើរៗតាមរយៈការធ្វើប្រតិភូកម្ម និងបន្ទាប់មកផ្លាស់ប្តូរទៅជាបែបផែននៃការប្រគល់មុខងារវិញ |

| ល.រ | ហានិភ័យ | កម្រិត | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|
| | | | ➢ ការគាំទ្រដល់ក្រសួង ស្ថាប័នក្នុងការរៀបចំលិខិតបទដ្ឋាន ស្តង់ដា ការធ្វើអធិការកិច្ច ការត្រួតពិនិត្យការអនុវត្តការងារ និងការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបន្សុីគ្នារវាងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនិងគោលនយោបាយរបស់ក្រសួង ស្ថាប័ននានា។ |
| ៣. | បុគ្គលិកល្អៗ និងធនធានហិរញ្ញវត្ថុភាគច្រើននៅតែបន្តស្ថិតនៅរដ្ឋបាលខេត្ត និងមន្ទីរជំនាញនានា | ខ្ពស់ | ➢ ការពង្រឹងកិច្ចសហការរវាងកម្មវិធីកំណែទម្រង់ទាំង៣ (កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ) ដើម្បីពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធនានានៅថ្នាក់ខេត្ត និងក្រុង ស្រុក<br>➢ ការសិក្សាវិភាគ ដើម្បីពិនិត្យមើលឡើងវិញនូវរូបមន្តនាពេលបច្ចុប្បន្ននៃការវិភាជធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ |

# សមាសភាគទី ៥
# វិមជ្ឈការហិរញ្ញវត្ថុ

## ក. សេចក្តីផ្តើម

នាពេលបច្ចុប្បន្ននេះ យន្តការនានានៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុត្រូវបានបង្កើតឡើង ដើម្បីផ្ទេរធនធានពីថ្នាក់ជាតិដែលជាអ្នកប្រមូលចំណូល ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលនឹងមានតួនាទីផ្តល់សេវាសាធារណៈកាន់តែច្រើនឡើង។ យន្តការនានានៃការផ្ទេរថវិកានាពេលបច្ចុប្បន្នមានសង្ខេបដូចខាងក្រោម៖

- **មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក** គឺជាការផ្តល់ធនធានជាឆន្ទានុសិទ្ធិ (គ្មានភ្ជាប់ល័ក្ខខ័ណ្ឌ)
- **ថវិកាខេត្ត** គឺជាធនធានដែលបានមកពីចំណូលចែករំលែកពីចំណូលពន្ធ និងមិនមែនសារពើពន្ធមួយចំនួន និងការផ្តល់ថវិកាបំពេញបន្ថែមពីថ្នាក់ជាតិ
- **ចំណូលផ្ទាល់នៅមូលដ្ឋាន** ជាចំណូលដែលបានពីចំណូលពន្ធចែករំលែក និងចំណូលដែលប្រមូលដោយរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានចំណូលមិនមែនសារពើពន្ធមួយចំនួន កម្រៃសេវានានា និងការចូលរួមវិភាគទានដោយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋ
- **មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ** ជាថវិកាដែលផ្តល់ឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារជាក់លាក់នីមួយៗដែលបានផ្ទេរទៅឱ្យ
- **មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ** ជាមូលនិធិដែលផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការស្នើសុំមូលនិធិបន្ថែមតាមរយៈសំណើគម្រោងសម្រាប់ការអភិវឌ្ឍគម្រោងមួយចំនួនដែលរដ្ឋបាលថ្នាក់ក្រោមជាតិពុំមានលទ្ធផលប្រើប្រាស់នូវមូលនិធិរបស់ខ្លួន។

ផអ៣ទី៣នឹងបន្តផ្តោតជាសំខាន់លើរដ្ឋបាលក្រុង ស្រុក។ ក្នុងការអនុវត្តកិច្ចការរបស់ខ្លួន ក្រុង ស្រុក ត្រូវការចាំបាច់នូវមូលនិធិឆន្ទានុសិទ្ធិក្នុងចំនួនសមស្រប ដើម្បីដោះស្រាយបញ្ហានានារបស់មូលដ្ឋាន និងឆ្លើយតបនឹងតម្រូវការនានានៃការផ្តល់សេវាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អាស្រ័យហេតុនេះ រដ្ឋបាលក្រុង ស្រុក ត្រូវការចាំបាច់នូវចំនួនថវិកាដែលអាចព្យាករណ៍បាន និងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការប្រើប្រាស់ថវិកានានាដែលបានផ្ទេរទៅឱ្យ រាប់បញ្ចូលទាំងមូលនិធិក្រុង ស្រុក មូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌ និងចំណូលផ្ទាល់នៅមូលដ្ឋាន។ អាស្រ័យហេតុនេះ ផអ៣ទី៣មានគោលបំណងពង្រឹងស្វ័យភាពផ្នែកហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងគណនេយ្យភាពក្នុងការបំពេញការងាររបស់ខ្លួនផងដែរ។

ជាទូទៅ ថ្នាក់ជាតិពិតជាពុំមានលទ្ធភាពក្នុងការវិភាជធនធានទៅឱ្យគ្រប់ស្ថាប័នទាំងអស់ ឬគ្រប់

វិស័យទាំងអស់ ឬសម្រាប់សេវាទាំងអស់ឱ្យបានត្រឹមត្រូវឥតខ្ចោះនោះឡើយ។ ក្នុងពេលដែលកិច្ចដំណើរវិមជ្ឈការមានការវិវត្តទៅមុខទៀត រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានផ្តល់លទ្ធភាពកាន់តែច្រើនឡើងក្នុងការកំណត់នូវអាទិភាពនានារបស់មូលដ្ឋាន និងផ្តោតការយកចិត្តទុកដាក់ទៅការចំណាយលើបញ្ហាដែលមានភាពចាំបាច់បំផុត។ ជាមួយគ្នានេះដែរ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់គាំទ្រវិស័យជាក់លាក់ និងអន្តរវិស័យ។ រដ្ឋបាលក្រុង ស្រុកនឹងត្រូវបានរំពឹងថា ប្រើប្រាស់នូវធនធានគ្មានភ្ជាប់លក្ខខ័ណ្ឌរបស់ខ្លួនកាន់តែច្រើនឡើងក្នុងការបំពេញបន្ថែមទៅលើការអនុវត្តមុខងារដែលក្រសួង ស្ថាប័នបានប្រគល់ឱ្យ។

## ខ. វឌ្ឍនភាព និងបញ្ហាប្រឈម

ជារួម ធនធាននានាដែលបានវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងជាលំដាប់។ ក្នុងអំឡុងជអ៣ទី១ មូលនិធិក្រុង ស្រុក ត្រូវបានបង្កើត និងមានការកើនឡើងជាភាគរយពី០,៨%ដល់១,០%នៃចំណូលចរន្តថវិកាជាតិ ឬមានការកើនឡើងពី១៤,៤លានដុល្លារក្នុងឆ្នាំ២០១៤ដល់៣៣,៤លានដុល្លារក្នុងឆ្នាំ២០១៧។

មូលនិធិឃុំ សង្កាត់បានកំណត់ចំនួន២,៨%នៃចំណូលចរន្តថវិកាជាតិ បានធ្វើឱ្យមានកើនឡើងពីចំនួន១២,៣លានដុល្លារក្នុងឆ្នាំ២០០៣ដល់ចំនួន៩២,៧លានដុល្លារក្នុងឆ្នាំ២០១៧ ដោយឡែកថវិកាខេត្តមានការកើនឡើងពីចំនួន១៨៦លានដុល្លារក្នុងឆ្នាំ២០១៥ដល់ចំនួន២៦៨លានដុល្លារក្នុងឆ្នាំ២០១៧។ គិតជាមធ្យម មូលនិធិឃុំ សង្កាត់មានការកើនឡើងប្រចាំឆ្នាំចំនួន១៦% ចាប់តាំងពីឆ្នាំ២០១៣មក មូលនិធិក្រុង ស្រុកមានការកើនឡើងប្រចាំឆ្នាំចំនួន៣២%ចាប់តាំងពីឆ្នាំ២០១៤មក និងថវិកាខេត្តបានកើនឡើងប្រចាំឆ្នាំ២០%ចាប់តាំងពីឆ្នាំ២០១៥មក។ ក្នុងឆ្នាំ២០១៦ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើង និងមានថវិកាសរុបចំនួន២០លានដុល្លារសម្រាប់ផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិពីឆ្នាំ២០១៧ដល់ឆ្នាំ២០១៩។

ទោះបីមានវឌ្ឍនភាពជាច្រើនអំពីការធ្វើវិមជ្ឈការហិរញ្ញវត្ថុក៏ដោយ ក៏ប៉ុន្តែនៅមានបញ្ហាប្រឈមសំខាន់ៗ មួយចំនួនដែលជអ៣ទី៣ ត្រូវបន្តដោះស្រាយមានដូចជា ៖

- ក្រុង ស្រុក និងឃុំ សង្កាត់នៅមានធនធានមិនទាន់សមស្រប ដែលមិនអាចបំពេញមុខងារជាអាណត្តិទូទៅរបស់ខ្លួនបានពេញលេញនៅឡើយ ដោយសារតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋមានចំនួនច្រើនលើសពីលទ្ធភាពធនធានរបស់រដ្ឋបាលក្រុង ស្រុក។
- ធនធានមួយចំនួននៃមូលនិធិក្រុង ស្រុកដែលគ្រោងប្រើប្រាស់សម្រាប់ការអនុវត្តនូវមុខងារជាអាណត្តិទូទៅរបស់ខ្លួនត្រូវបានយកទៅប្រើប្រាស់សម្រាប់ការអភិវឌ្ឍសមត្ថភាព ការសាងសង់ ឬជួសជុលអគារ និងការទិញសម្ភារការិយាល័យ។
- នៅក្នុងរូបមន្តដែលបានកំណត់សម្រាប់ការវិភាជមូលនិធិក្រុងស្រុក ការចំណាយផ្នែករដ្ឋបាលមានចំនួន២៤%នៃមូលនិធិសរុបដែលបានដកការចំណាយលើប្រាក់បៀវត្សរួចហើយ។

ប្រការនេះ នឹងបង្កឱ្យចំណាយរដ្ឋបាលមានការកើនឡើងជាបន្តបន្ទាប់។

- ការផ្តល់ហិរញ្ញប្បទានរបស់គូអភិវឌ្ឍន៍នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវបានកៀរគរបន្ថែមទៀត។ នាពេលបច្ចុប្បន្ននេះ ការផ្តល់ធនធានមានភ្ជាប់លក្ខខ័ណ្ឌនានារបស់ដៃគូអភិវឌ្ឍទៅឱ្យក្រុង ស្រុក និងឃុំ សង្កាត់គោលដៅមួយចំនួនក្នុងការអនុវត្តនូវគម្រោងសេវាសង្គម ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការប្រែប្រួលអាកាសធាតុជាដើម ត្រូវបានប្រើប្រាស់ជាមូលនិធិគ្មានភ្ជាប់លក្ខខ័ណ្ឌរបស់ក្រុង ស្រុក និងឃុំ សង្កាត់។
- ការវិភាជធនធាននានាចាំបាច់ត្រូវផ្តល់អាទិភាពសម្រាប់ការផ្តល់សេវា។ នៅពេលក្រុង ស្រុកដើរតួនាទីដ៏សំខាន់ក្នុងការផ្តល់សេវា ហើយរដ្ឋបាលខេត្តនឹងដើរតួនាទីជាអ្នកផ្តល់ការគាំទ្រ និងត្រួតពិនិត្យ នោះធនធានមួយចំនួនចាំបាច់ត្រូវបានបង្វែរពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក។

ផអ៣ទី២មានគោលបំណងកំណត់ការផ្តល់ហិរញ្ញប្បទានដល់ផ្នែកអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិក្រុង ស្រុកឱ្យបាន០,៥%នៃចំណូលចរន្តថវិកាជាតិ ក៏ប៉ុន្តែដោយសារប្រាក់បៀវត្សត្រូវបានបង្កើនជាបន្តបន្ទាប់ អាស្រ័យហេតុនេះ គោលបំណងនេះពុំអាចសម្រេចបានក្នុងអំឡុងពេលនៃផអ៣ទី២ (២០១៥-២០១៧) បានឡើយ ក៏ប៉ុន្តែអាចរំពឹងថានឹងសម្រេចបានក្នុងឆ្នាំ២០១៩។

## គ. សមិទ្ធផល និងលទ្ធផលរំពឹងទុក

សមិទ្ធផល និងលទ្ធផលរំពឹងទុកនានារបស់សមាសភាគទី៥នេះមានរៀបរាប់ ដូចខាងក្រោម ៖

**សមិទ្ធផលរំពឹងទុក ៥.១ ៖ ការផ្តល់ធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកទៅលើលទ្ធផលនៃការបំពេញការងារ ក្នុងលក្ខណៈឆន្ទានុសិទ្ធ ផ្តោតទៅលើការអភិវឌ្ឍ និងមានចំនួនសមស្របដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងស្តង់ដានៃការផ្តល់សេវា**

សមិទ្ធផលរំពឹងទុកនេះរួមមានលទ្ធផលរំពឹងទុកចំនួន៤ដូចខាងក្រោម ៖

**លទ្ធផលរំពឹងទុក ៥.១.១ ៖ មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ត្រូវបានវិភាជដោយផ្តោតលើការចំណាយផ្នែកអភិវឌ្ឍ**

***គោលដៅ***

- ការបង្កើនទំហំមូលនិធិផ្នែកអភិវឌ្ឍមូលដ្ឋាននៃមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់។

***សកម្មភាពជាចម្បង***

- ការពិនិត្យ និងកែសម្រួលឡើងវិញនូវលិខិតបទដ្ឋាននានានៃមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក ដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវនិយមន័យនៃការចំណាយផ្នែករដ្ឋបាល និងការចំណាយផ្នែកអភិវឌ្ឍមូលដ្ឋាន
- ការវិភាជថវិកាតាមរយៈថវិកាគាំទ្រដល់មូលនិធិក្រុង ស្រុក ដោយផ្អែកទៅតាមចំណុចដៅនៃក្របខ័ណ្ឌវាយតម្លៃកម្មវិធី
- ការពិនិត្យ និងកែសម្រួលឡើងវិញនូវការកំណត់អំពីភាគរយនៃចំនួនសរុបនៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ព្រមទាំងចំណែកនៃចំណាយរដ្ឋបាលនិងចំណាយសម្រាប់ការអភិវឌ្ឍឱ្យបានច្បាស់លាស់ ដើម្បីធានាថា កំណើននៃការចំណាយរដ្ឋបាលនឹងមិនបណ្តាលឱ្យមានការកាត់បន្ថយការចំណាយលើផ្នែកអភិវឌ្ឍ
- ការពិនិត្យ និងកែសម្រួលនូវរូបមន្តវិភាជមូលនិធិក្រុង ស្រុក ដើម្បីឱ្យមានសមធម៌ក្នុងការបែកចែកមូលនិធិ ដោយផ្អែកទៅលើចំណូលខុសៗគ្នារបស់រដ្ឋបាលដែលបានមកពីចំណូលនៃទ្រព្យសម្បត្តិរបស់ខ្លួន និងចំណូលចែករំលែកផ្សេងៗទៀត
- ការរៀបចំ និងអនុវត្តគម្រោងសាកល្បងនូវការផ្តល់ធនធានតាមរយៈមូលនិធិផ្អែកលើលទ្ធផលនៃការបំពេញការងាររបស់រដ្ឋបាលក្រុង ស្រុក ដោយផ្អែកលើការវាយតម្លៃលើលទ្ធផលនៃការអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួន%នៃផ្នែកអភិវឌ្ឍរបស់មូលនិធិក្រុង ស្រុក ធៀបនឹងចំណូលចរន្តជាតិ | ០,៣៧% | ០,៥% | ០,៥% |
| វិធីសាស្ត្រក្នុងការបែកចែកមូលនិធិក្រុង ស្រុក ត្រូវបានកែសម្រួល | | ប្រព័ន្ធបែកចែកដោយសមធម៌ត្រូវបានអនុវត្ត | មូលនិធិផ្អែកលើលទ្ធផលនៃការបំពេញការងារត្រូវបានសាកល្បង |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះដោយមានកិច្ចសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

## លទ្ធផលរំពឹងទុក ៥.១.២ ៖ បែបផែនចំណូលចែករំលែក (ពន្ធ និងមិនមែនពន្ធ) ត្រូវបានពិនិត្យ និងកែសម្រួល ដើម្បីបង្កើនការផ្តល់ធនធានក្រុង ស្រុក និងឃុំ សង្កាត់

***គោលដៅ***

- ក្រុង ស្រុកមានចំណូលផ្ទាល់សមស្របសម្រាប់អនុវត្តនូវមុខងារជាអាណត្តិទូទៅរបស់ខ្លួន

***សកម្មភាពជាចម្បង***

- ការសិក្សាវាយតម្លៃមានលក្ខណៈគ្រប់ជ្រុងជ្រោយទៅលើយន្តការបែងចែកធនធានរវាងរាជធានី ខេត្ត និងក្រុង ស្រុក និងឃុំ សង្កាត់
- ការពិនិត្យ និងកែសម្រួលប្រព័ន្ធចែករំលែកចំណូលពន្ធ និងចំណូលមិនមែនសារពើពន្ធនាពេលបច្ចុប្បន្ន។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| %នៃពន្ធលើអចលនទ្រព្យត្រូវបានចែករំលែកពីខេត្តទៅឱ្យក្រុង និងសង្កាត់ | ៤០% | ៤៥% | ៥០% |
| ចំណូលមិនមែនសារពើពន្ធផ្សេងទៀតបានចែករំលែកពីខេត្តទៅឱ្យក្រុង ស្រុក (គិតជាលានដុល្លារ) | | ១ | ១,៥ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះដោយមានកិច្ចសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

### លទ្ធផលរំពឹងទុក ៥.១.៣ ៖ មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌត្រូវបានដាក់ឱ្យដំណើរការ ដើម្បីអនុវត្តមុខងារដែលបានផ្ទេរ

***គោលដៅ***

- ទំហំនៃមូលនិធិមានភ្ជាប់លក្ខខណ្ឌ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវឆ្លុះបញ្ចាំងអំពីការចំណាយយ៉ាងពិតប្រាកដសម្រាប់ការផ្តល់សេវា ដោយផ្អែកតាមស្តង់ដាសេវាដែលបានកំណត់

***សកម្មភាពជាចម្បង***

- ការរៀបចំការសិក្សាអំពីតម្លៃចំណាយនៃការផ្តល់សេវាសំខាន់ៗដែលបានផ្ទេរ ដោយផ្អែកតាមស្តង់ដាសេវានីមួយៗដែលបានកំណត់។
- ការកៀរគរធនធានដើម្បីអនុវត្តសាកល្បង និងវាយតម្លៃអំពីប្រព័ន្ធផ្តល់ធនធានមានភ្ជាប់លក្ខខណ្ឌផ្អែកលើលទ្ធផលនៃការបំពេញការងារ។
- ការកែសម្រួលរូបមន្ត និងបទប្បញ្ញត្តិនានាសម្រាប់ការបែងចែកមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌដោយផ្អែកលើលទ្ធផលនៃការអនុវត្តសាកល្បង ។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| ចំនួនរដ្ឋបាលក្រុង ស្រុកទទួលបានមូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារជាក់លាក់ | ០ | ១៥ | ៤០ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះដោយមានកិច្ចសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**លទ្ធផលរំពឹងទុក ៥.១.៤ ៖ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដាក់ឱ្យដំណើរការ ដើម្បីគាំទ្រគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

***សកម្មភាពជាចម្បង***

- ការបន្តអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍នានាបន្ថែមទៀតដើម្បីពង្រីកវិសាលភាពនៃគាំទ្រការអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងវិស័យផ្សេងៗទៀត
- ការពិនិត្យ និងកែសម្រួលសេចក្តីណែនាំ និងកិច្ចដំណើរការវាយតម្លៃសំណើគម្រោង ដើម្បីលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម
- នៅឆ្នាំ២០២០ កំណត់អំពីជម្រើសនានាដើម្បីធានាដល់ការធ្វើស្ថាប័នភាវូបនីយកម្ម និងនិរន្តរភាពនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលអនាគត។

***ចំណុចដៅ***

| ចំណុចដៅ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|
| តម្លៃសរុបនៃគម្រោងដែលបានអនុវត្តតាមរយៈមូលនិធិវិនិយោគរដ្ឋបាល ថ្នាក់ក្រោមជាតិ (គិតជាលានដុល្លារ) | ៣,៥ | ១០,៥ | ១៧,៥ |

***ស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត***

លេខាធិការដ្ឋាននៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការអនុវត្តលទ្ធផលរំពឹងទុកនេះ។

## ឃ. ថវិកាប៉ាន់ស្មាន

ថវិកាប៉ាន់ស្មានសម្រាប់ចំណាយលើការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗនៃសមាសភាគនេះ រួមមានដូចខាងក្រោម ៖

**តារាងទី១៤ ៖ ថវិកាចំណាយប៉ាន់ស្មានសម្រាប់សមាសភាគទី៥**

| លទ្ធផលរំពឹងទុក | ថវិកា | | | |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | សរុប |
| ៥.១.១. មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ត្រូវបានវិភាជដោយផ្តោតលើការចំណាយផ្នែកអភិវឌ្ឍន៍ | 125,400 | 56,100 | 102,300 | 283,800 |
| ៥.១.២. បែបផែនចំណូលចែករំលែក ពន្ធ និងមិនមែន) (ពន្ធត្រូវបានពិនិត្យ និងកែសម្រួល ដើម្បីបង្កើន | 57,200 | 34,100 | 91,300 | 182,600 |

| លទ្ធផលរំពឹងទុក | ថវិកា | | | |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | សរុប |
| ការផ្តល់ធនធានក្រុង ស្រុក និងឃុំ សង្កាត់ | | | | |
| ៥.១.៣. មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌត្រូវបានដាក់ឱ្យដំណើរការ ដើម្បីអនុវត្តមុខងារដែលបានផ្ទេរ | 34,100 | 176,000 | 497,200 | 707,300 |
| ៥.១.៤. មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដាក់ឱ្យដំណើរការ ដើម្បីគាំទ្រគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 5,913,762 | 10,640,991 | 11,543,330 | 28,098,082 |
| **សរុប** | **6,130,462** | **10,907,191** | **12,234,130** | **29,271,782** |

## ខ. ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យ

ហានិភ័យសំខាន់ៗ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគនេះ ត្រូវបានកំណត់ និងមានរៀបរាប់ដូចខាងក្រោម ៖

**តារាងទី១៥៖ ហានិភ័យ និងវិធានការកាត់បន្ថយហានិភ័យនៃសមាសភាគទី៥**

| ល.រ | ហានិភ័យ | កម្រិត | វិធានការកាត់បន្ថយហានិភ័យ |
|---|---|---|---|
| ១. | មូលនិធិគ្មានភ្ជាប់ល័ក្ខខ័ណ្ឌមានចំនួនមិនសមស្រប សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន | មធ្យម | ➢ ពិនិត្យ និងកែសម្រួលមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ផ្អែកតាមចំណុចដៅដែលបានកំណត់<br>➢ ចៀសវាងការផ្ទេរមុខងារណាដែលពុំមានធនធាន<br>➢ ជំរុញកិច្ចដំណើរការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីផ្តល់មូលនិធិបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>➢ ពិនិត្យ និងកែសម្រួលបែបផែននៃចំណូលចែករំលែកដើម្បីបង្កើនធនធានក្រុង ស្រុក និងឃុំ សង្កាត់<br>➢ ពង្រឹងការបែងចែកធនធាននានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយសមធម៌។ |
| ២. | ចំណូលមិនមែនសារពើពន្ធនៅតែរបស់ខេត្ត ដោយមិនបានចែករំលែកទៅឱ្យថ្នាក់ក្រុង ស្រុក | មធ្យម | ➢ ពិនិត្យ និងកែសម្រួលឡើងវិញតួនាទី និងធនធានថវិការបស់ខេត្ត ផ្អែកតាមតួនាទីរបស់ខ្លួនក្នុងនាមជាអ្នកគាំទ្រ និងតាមដានត្រួតពិនិត្យ។ |

# ផ្នែកទី៣

# ការគ្រប់គ្រងកម្មវិធី

## គ. ការរៀបចំស្ថាប័នគ្រប់គ្រងកម្មវិធី

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) គឺជាគណៈកម្មាធិការអន្តរក្រសួង ដែលមានតួនាទីដ៏សំខាន់ក្នុងការផ្តល់ការណែនាំផ្នែកគោលនយោបាយ ការអនុម័ត និងការត្រួតពិនិត្យមើលការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការធានាការអនុវត្តច្បាប់នេះ ដោយរួមបញ្ចូលទាំងការពិនិត្យមើលឡើងវិញមុខងារនានារបស់ក្រសួង ស្ថាប័ន និងការអនុម័តផែនការ ថវិកា និងរបាយការណ៍នានា។ ច្បាប់នេះត្រូវបានអនុវត្តតាមរយៈកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ អាស្រ័យហេតុនេះ គ.ជ.អ.ប. គឺជាស្ថាប័នដែលទទួលខុសត្រូវក្នុងការដឹកនាំ សម្របសម្រួលដល់ការអនុវត្តកម្មវិធី ការសម្រេចបាននូវសមិទ្ធផលរំពឹងទុកនានា ព្រមទាំងការធានាដល់គុណភាព និងពេលវេលានៃការបំពេញការងាររបស់ស្ថាប័នអនុវត្តនានា។

ផអ៣ទី៣ នឹងត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនានា។ ជារួមមានស្ថាប័នអនុវត្តសំខាន់ៗចំនួន៤៦ ដែលក្នុងនោះរួមមាន ស្ថាប័ននៅថ្នាក់ជាតិចំនួន២១ និងរាជធានីខេត្តចំនួន២៥។

លេខាធិការដ្ឋាន គ.ជ.អ.ប. មានតួនាទីជាសេនាធិការគាំទ្រដល់ គ.ជ.អ.ប. និងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប ក្នុងការគ្រប់គ្រងចាត់ចែងការអនុវត្តកម្មវិធីផអ៣ទី៣ប្រចាំថ្ងៃ។ ភារកិច្ចសំខាន់ៗរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. រួមមាន ៖

- សម្របសម្រួល និងគាំទ្រដល់ការធ្វើវិមជ្ឈការ
- សម្របសម្រួល រៀបចំតាក់តែង និងធ្វើរបាយការណ៍អំពីកម្មវិធី
- សិក្សាវិភាគ អនុវត្តសាកល្បង និងវាយតម្លៃនូវគោលនយោបាយ និងលិខិតបទដ្ឋាននានា ជាពិសេសគោលនយោបាយ និងលិខិតបទដ្ឋានដែលពុំស្ថិតក្រោមការទទួលខុសត្រូវដាច់ដោយឡែករបស់ក្រសួង ស្ថាប័នណាមួយ
- លើកកម្ពស់ការត្រួតពិនិត្យ និងការវាយតម្លៃរបស់ គ.ជ.អ.ប និងរបស់ស្ថាប័នអនុវត្តនានា និងការវិភាគទៅលើគុណភាព និងផលប៉ះពាល់នៃការអនុវត្តកម្មវិធី
- កៀរគរធនធាន ប្រាស្រ័យទាក់ទង និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា
- សម្របសម្រួល និងធ្វើសុខដុមនីយកម្មគម្រោង និងកម្មវិធីដាច់ដោយឡែកនានា
- គ្រប់គ្រង ចាត់ចែងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុនៃផអ៣ទី៣ និង
- បំពេញការងារផ្នែករដ្ឋបាលនានាដើម្បីគាំទ្រ គ.ជ.អ.ប. និងកិច្ចប្រជុំរបស់ គ.ជ.អ.ប។

## ៦. កិច្ចដំណើរការគ្រប់គ្រងសំខាន់ៗរបស់លេខាធិការដ្ឋាន គ.ជ.អ.ប

ជារួម លេខាធិការដ្ឋាន គ.ជ.អ.ប. មានតួនាទីក្នុងការរៀបចំផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងគម្រោង ការត្រួតពិនិត្យតាមដាននិងវាយតម្លៃ ការសិក្សាវិភាគគោលនយោបាយ និងការរៀបចំរបាយការណ៍។

**១. ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (ផ.ស.ថ.)**

ជារៀងរាល់ឆ្នាំ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវសម្របសម្រួលជាមួយស្ថាប័នអនុវត្តនានាដើម្បីរៀបចំតាក់តែងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដោយផ្អែកលើផអ៣។ កិច្ចដំណើរការរៀបចំ ផ.ស.ថ ត្រូវធានាឱ្យមានការចូលរួម និងផ្តល់ឱកាសសមស្របដល់ស្ថាប័នអនុវត្តទាំងអស់ក្នុងការត្រួតពិនិត្យ និងមានការយល់ដឹងច្បាស់លាស់អំពីសមិទ្ធផល និងលទ្ធផលរំពឹងទុកនានានៃផអ៣ ហើយបន្ទាប់មកត្រូវរៀបចំតាក់តែងនូវលទ្ធផលរំពឹងទុក និងសកម្មភាពនានាប្រចាំឆ្នាំ ដែលធានាដល់ការសម្រេចបានគោលដៅ និងចំណុចដៅទាំងឡាយដែលបានគ្រោងទុក។ ជាទូទៅ ការផ្សារភ្ជាប់រវាងលទ្ធផលរំពឹងទុកនានារបស់ ផ.ស.ថ និងផអ៣ ចាំបាច់ត្រូវធានាឱ្យបាននៅក្នុងកិច្ចដំណើរការនេះ។ លេខាធិការដ្ឋាន គ.ជ.អ.ប. មានតួនាទីត្រួតពិនិត្យវាយតម្លៃទៅលើសំណើលទ្ធផលរំពឹងទុក និងសកម្មភាពនានារបស់ស្ថាប័នអនុវត្តនីមួយៗ សំដៅធានាថា សំណើទាំងនេះមានភាពសមស្របទៅនឹងផអ៣។ បន្ទាប់ពីមានការព្រមព្រៀងគ្នាហើយ ស្ថាប័នអនុវត្តនានានឹងត្រូវបានផ្តល់ការទទួលខុសត្រូវតាមរយៈការចុះហត្ថលេខាលើ "សេចក្តីសម្រេចរួម" ជាមួយ គ.ជ.អ.ប. ក្នុងការអនុវត្ត ការតាមដាន និងការធ្វើរបាយការណ៍ ។ ជាទូទៅ សេចក្តីសម្រេចរួមទាំងនោះ រួមមាននូវការកំណត់អំពីសូចនាករ លទ្ធផលរំពឹងទុក សកម្មភាព និងថវិកា។ សេចក្តីសម្រេចទាំងនោះ ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ ផ.ស.ថ. ដែលប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការធ្វើរបាយការណ៍របស់ស្ថាប័នអនុវត្តនីមួយៗឱ្យបានលឿនទាន់ពេលវេលា និងសម្រាប់ការត្រួតពិនិត្យតាមដានទៅលើការអនុវត្តសេចក្តីសម្រេចរួម។

ក្នុងសេចក្តីសម្រេចរួមរវាងគ.ជ.អ.ប និងរដ្ឋបាលរាជធានី ខេត្តនីមួយៗរួមមានបញ្ចូលនូវផែនការសកម្មភាព និងថវិការបស់ក្រុង ស្រុក ខណ្ឌផងដែរ។ អភិបាលរាជធានី ខេត្តក្នុងនាមលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងរៀបចំពិនិត្យ និងចុះហត្ថលេខាលើសេចក្តីសម្រេចរួមជាមួយអភិបាលក្រុង ស្រុក ខណ្ឌ។

កិច្ចដំណើរការនៃការរៀបចំតាក់តែង ផ.ស.ថ. និងសេចក្តីសម្រេចរួមត្រូវអនុវត្តតាមសៀវភៅណែនាំស្តីពី "ការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ" របស់ គ.ជ.អ.ប.។

**២. ការគ្រប់គ្រងគម្រោង និងតារាងម៉ាទ្រិកស្តីពីទំនាក់ទំនងនៃយុទ្ធសាស្ត្រនានាក្នុងការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗ**

ជាទូទៅ និយមន័យនៃ "**គម្រោង**" គឺជាសំណុំសកម្មភាពមួយដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក និងត្រូវបានរៀបចំឡើងដើម្បីសម្រេចបាននូវគោលដៅជាក់លាក់ណាមួយ ឬគោលដៅជាក់លាក់មួយចំនួនក្នុងក្របខ័ណ្ឌពេលវេលា និងចំនួនថវិកាមួយច្បាស់លាស់។ ក្នុងក្របខណ្ឌនៃផអ៣ទី៣

ការគ្រប់គ្រងតាមបែបផែនគម្រោង គឺជាវិធីសាស្ត្រ និងបច្ចេកទេសដ៏មានសារសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត ដែលធានាបាននូវការប្រមូលផ្តុំរាល់សកម្មភាព អ្នកទទួលខុសត្រូវអនុវត្ត និងជំនាញវិជ្ជាជីវៈនានា ដើម្បីសម្រេចបាននូវគោលដៅរួមណាមួយ។ ក្នុងករណីនេះ ផអ៣ទី៣នឹងផ្លាស់ប្តូរបែបផែននៃការអនុវត្ត "លទ្ធផលរំពឹងទុកនានា" តាមបែបផែនជាការអនុវត្តគម្រោងមួយចំនួនក្នុងពេលដែលផអ៣ទី៣បានផ្លាស់ពីការរៀបចំគោលនយោបាយ ទៅជាការអនុវត្តជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លក្ខណៈសំខាន់ៗរបស់គម្រោងនានារួមមាន ដូចខាងក្រោម ៖

- ការកំណត់ច្បាស់លាស់នូវភាគីពាក់ព័ន្ធ ឬអ្នកទទួលផល (ភាគច្រើនរួមមានក្រុមនានារបស់ប្រជាពលរដ្ឋ)
- ការរៀបរាប់ឱ្យបានលម្អិតអំពីខ្លឹមសារនៃឯកសារ ឬយុទ្ធសាស្ត្រ ឬសេចក្តីណែនាំរបស់គម្រោង
- ការកំណត់អំពីលទ្ធផលរំពឹងទុកឱ្យបានច្បាស់លាស់ដែលត្រូវបានរៀបចំតាមខ្សែចង្វាក់នៃលទ្ធផល
- ការកំណត់នូវសកម្មភាពផ្សេងៗ និងដែលមានទំនាក់ទំនងគ្នា ព្រមទាំងអ្នកទទួលខុសត្រូវក្នុងការអនុវត្ត ឬដៃគូសហការនានា
- ការបង្កើតនូវគំនិតច្នៃប្រឌិតថ្មីៗ (ជាការសាកល្បងបណ្តោះអាសន្ន) ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរ។ ក្នុងករណីដែលគំនិតច្នៃប្រឌិតនោះទទួលបានជោគជ័យ នោះនឹងត្រូវយកមករៀបចំជាការអនុវត្តក្នុងលក្ខណៈជាប្រព័ន្ធ
- ការកំណត់ឱ្យបានច្បាស់លាស់នូវបែបផែននៃការសម្របសម្រួល អភិបាលកិច្ច ការគ្រប់គ្រង និងទំនាក់ទំនងគណនេយ្យភាព។ ក្នុងក្របខណ្ឌនៃការអនុវត្តផអ៣ទី៣ គម្រោងទាំងនេះត្រូវមានការកំណត់ឱ្យបានច្បាស់លាស់ពីអង្គភាព (នាយកដ្ឋាន ឬការិយាល័យ) នៃស្ថាប័នអនុវត្ត នីមួយៗក្នុងការទទួលខុសត្រូវលើការគ្រប់គ្រង និងអនុវត្តគម្រោងនីមួយៗ។ ប្រធានអង្គភាពទទួលខុសត្រូវនីមួយៗ អាចចាត់តាំងមន្ត្រីក្នុងមុខតំណែងណាមួយរបស់អង្គភាពឱ្យទទួលបន្ទុកបន្ថែមជានាយកគម្រោង។
- ការកំណត់ឱ្យបានច្បាស់លាស់នូវប្រព័ន្ធត្រួតពិនិត្យតាមដាន ផែនការសកម្មភាព និងសូចនាករ ឬស្តង់ដានៃគុណភាពសម្រាប់គ្រប់គ្រងលទ្ធផល។

តារាងម៉ាទ្រិកស្តីពីទំនាក់ទំនងនៃយុទ្ធសាស្ត្រនានាក្នុងការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗ ក្នុងបែបផែនជាគម្រោង (ដូចមាននៅក្នុងតារាងទី១៧នៅខាងក្រោម) បានបង្កើតឡើងនូវទំនាក់ទំនងគណនេយ្យភាព និងការរៀបចំរបាយការណ៍ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាមួយ។ ក្នុងន័យនេះ មន្ត្រី ដែលបានចាត់តាំងឱ្យទទួលខុសត្រូវលើគម្រោងត្រូវរាយការណ៍ជូនអង្គភាពជំនាញរបស់ខ្លួនផង និងជូននាយកគម្រោងផងដែរ។ ក្នុងផអ៣ទី៣រួមមាននូវលទ្ធផលរំពឹងទុកដែលមានចរិកលក្ខណៈផ្សេងៗគ្នាជាច្រើន ដូចជាលទ្ធផលនានាដែលរំពឹងថានឹងសម្រេចបាននៅចុងបញ្ចប់នៃកម្មវិធី ( ឧទាហរណ៍

លើកកម្ពស់ការអនុវត្តមុខងារជាអាណត្តិទូទៅ ឬការអនុវត្តការងារគណនេយ្យភាពសង្គម) និងលទ្ធផលនានាដែលមានមុខងារជាការគាំទ្រ (ឧទាហរណ៍ ការអភិវឌ្ឍសមត្ថភាព ការប្រាស្រ័យទាក់ទងនិងផ្សព្វផ្សាយ បរិយាប័ន្ននិងសមធម៌សង្គម ការត្រួតពិនិត្យតាមដាននិងវាយតម្លៃ ភាពជាដៃគូជាមួយសង្គមស៊ីវិល ព័ត៌មានវិទ្យា ការកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន និងការអនុវត្តសាកល្បងផ្នែកគោលនយោបាយ)។ លទ្ធផលនានាដែលមានមុខងារជាការគាំទ្រនឹងបម្រើឱ្យលទ្ធផលនានា ដែលរំពឹងថានឹងសម្រេចបាននៅចុងបញ្ចប់នៃកម្មវិធី។ គម្រោងដែលអាចរៀបចំសម្រាប់អនុវត្តលទ្ធផលរំពឹងទុកនានារួមមានក្នុងតារាងខាងក្រោម ដែលនឹងបន្តពិភាក្សា និងរៀបចំឱ្យបានជាក់លាក់ដោយស្ថាប័នអនុវត្តនានា ដោយមានការពិនិត្យ និងឯកភាពពីលេខាធិការដ្ឋាន គ.ជ.អ.ប.។

**តារាង១៦៖ បញ្ជីគម្រោងដែលអាចរៀបចំសម្រាប់អនុវត្តលទ្ធផលរំពឹងទុកនានា**

| ល.រ | គម្រោង | លទ្ធផលរំពឹងទុក | ការបរិយាយ |
|---|---|---|---|
| I | **គម្រោងដែលមានមុខងារជាការគាំទ្រ** | | |
| ១ | កែសម្រួលរចនាសម្ព័ន្ធ | | |
| ២ | ការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន | | |
| ៣ | ភាពជាដៃគូសង្គមស៊ីវិល | | |
| ៤ | ការពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងការវាយតម្លៃ | | |
| ៥ | ការអនុវត្តសាកល្បង និងការសិក្សារៀនសូត្រមេរៀន និងបទពិសោធន៍ល្អៗ | | |
| ៦ | ការពង្រឹងប្រព័ន្ធព័ត៌មានវិទ្យា | | |
| ៧ | ការអភិវឌ្ឍសមត្ថភាព | | |
| ៨ | ការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម | | |
| II | **គម្រោងដែលរំពឹងថានឹងសម្រេចបាននៅចុងបញ្ចប់នៃកម្មវិធី** | | |
| ១ | ការងារគណនេយ្យភាពសង្គម | | |
| ២ | ការពង្រឹងយន្តការទទួល និងដោះស្រាយបណ្តឹងតវ៉ា | | |
| ៣ | ការពង្រឹងប្រព័ន្ធអធិការកិច្ចលើរដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| ៤ | ការពង្រឹងប្រព័ន្ធត្រួតពិនិត្យតាមដានលទ្ធផលការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| ៥ | ការពង្រឹងប្រព័ន្ធគ្រប់គ្រងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ប្រព័ន្ធកសាងផែនការ គ្រប់គ្រងហិរញ្ញវត្ថុ...) | | |
| ៦ | ការអនុវត្តមុខងារជាអាណត្តិទូទៅ | | |
| ៧ | ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| ៨ | ការិយាល័យច្រកចេញចូលតែមួយ | | |

## តារាងទី១៧៖ តារាងម៉ាទ្រិកស្តីពីទំនាក់ទំនងនៃវិធីសាស្ត្រនានាក្នុងការអនុវត្តលទ្ធផលរំពឹងទុកនីមួយៗ

| សង្ខេបលទ្ធផលរំពឹងទុក | ការប្រាស្រ័យទាក់ទង | ការអភិវឌ្ឍសមត្ថភាព | ការត្រួតពិនិត្យវាយតម្លៃ | ព័ត៌មានវិទ្យា | ភាពជាដៃគូជាមួយសង្គមស៊ីវិល | បរិយាប័ន្ននិងសមធម៌សង្គម | ការកែសម្រួលរចនាសម្ព័ន្ធ | ការសាកល្បង |
|---|---|---|---|---|---|---|---|---|
| **សមាសភាគទី១ ៖ ការគ្រប់គ្រងការងារកំណែទម្រង់** | | | | | | | | |
| ១.១.១. ការកែសម្រួលរចនាសម្ព័ន្ធ | | | | | | | X | |
| ១.១.២. កម្មវិធីជាតិដំណាក់កាលបន្ទាប់ | | | X | | | X | | |
| ១.១.៣. យុទ្ធសាស្ត្រនិរន្តរភាពហិរញ្ញវត្ថុ | | | | | | | | |
| ១.២.១. កិច្ចពិភាក្សាកម្រិតនយោបាយ | | | | | | | | |
| ១.២.២. ការប្រាស្រ័យទាក់ទង | | | | | X | X | | |
| ១.២.៣. ការកសាងល្បងនិងការសិក្សារៀនសូត្រ | | | | | X | | | |
| ១.២.៤. ពង្រឹងសមាគមក្រុមប្រឹក្សា | X | | | | X | | | |
| ១.៣.១. ការរៀបចំ និងការអនុវត្តភាពជាដៃគូ | | | | | X | | | |
| ១.៤.១. ការគ្រប់គ្រងគម្រោង | | | X | | | X | | |
| ១.៤.២. សុខដុមនីយកម្ម | | | | | | | | |
| ១.៤.៣. ការគាំទ្ររដ្ឋបាល និងហិរញ្ញវត្ថុដល់កម្មវិធី | | | X | | | | | |
| **សមាសភាគទី២ ៖ អភិបាលកិច្ចល្អ** | | | | | | | | |
| ២.១.១. គណនេយ្យភាពសង្គម | X | X | X | X | X | X | | X |
| ២.១.២. ការដោះស្រាយបណ្តឹង | X | | | X | | X | | X |
| ២.២.១. ការពង្រឹងសិទ្ធិអំណាចសមាជិកក្រុមប្រឹក្សា | | X | | | | | X | |
| ២.៣.១. អធិការកិច្ចលើការអនុវត្តតាមច្បាប់ | | | X | | | | | |
| ២.៣.២. ការវាយតម្លៃអំពីកាអនុវត្តការងារ | | | X | | | | X | |
| ២.៤.១. ពិនិត្យនិងកែសម្រួលប្រព័ន្ធនានា | | X | X | X | | X | | |
| ២.៤.២. ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង | | X | | | | X | | X |
| ២.៤.៣. ការកសាងផែនការ | | X | | | | X | | X |
| ២.៤.៤. ការគ្រប់គ្រងហិរញ្ញវត្ថុ | | X | | | | | | X |
| ២.៥.១. ស្ត្រីក្នុងមុខតំណែងគ្រប់គ្រង | X | X | X | | X | X | | X |
| ២.៥.២. សមធម៌ និងបរិយាប័ន្នសង្គម | | X | | | | X | | |
| ២.៥.៣. សុវត្ថិភាពសង្គម | X | X | | | X | X | | |
| ២.៥.៤. សមធម៌ និងបរិយាប័ន្នសង្គមក្នុង CD | | X | | | X | X | | |
| **សមាសភាគទី៣ ៖ ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានមនុស្ស** | | | | | | | | |
| ៣.១.១. ការគ្រប់គ្រងធនធានមនុស្ស | X | X | X | | | X | X | X |
| ៣.២.១. វិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាព | X | X | X | | X | X | | X |
| ៣.២.២. អនុវត្តការអភិវឌ្ឍសមត្ថភាព | X | X | | | | X | | X |
| ៣.២.៣. ការបង្កើតសាលាជាតិ រដ្ឋបាលមូលដ្ឋាន | | X | | | | | X | |
| **សមាសភាគទី៤ ៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន** | | | | | | | | |
| ៤.១.១. ការវិភាគគោលន/ប អាណត្តិទូទៅ | | | | | | | | X |
| ៤.១.២. ការណែនាំអនុវត្តន៍អាណត្តិទូទៅ | X | X | | | | | | X |
| ៤.១.៣. មូលនិធិអាណត្តិទូទៅ | | | | | | | | |
| ៤.១.៤. ការអនុវត្តអាណត្តិទូទៅ | | | | | | | | |
| ៤.១.៥. អភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន សេវាសង្គម... | | X | X | | X | X | | |
| ៤.២.១. ការរៀបចំលិខិតបទដ្ឋានផ្ទេរមុខងារ | | X | | | | X | | X |
| ៤.២.២. ផែនការផ្ទេរមុខងារ | X | X | | | | X | | |
| ៤.២.៣. ការផ្ទេរមុខងារ | X | X | X | | | | X | X |
| ៤.២.៤. ការិយាល័យច្រកចេញចូលតែមួយ | X | X | | X | | X | X | |
| ៤.៣.១. គោល ន/ប និងស្តង់ដារនៃការផ្តល់សេវា | | X | X | | | | | X |
| ៤.៤.១. ខេត្តបំពេញតួនាទីគាំទ្រ និងត្រួតពិនិត្យ | X | | X | | | | | X |
| ៤.៤.២. ក្រុង ស្រុកផ្តល់សេវាគាំទ្រដល់ឃុំ សង្កាត់ | | | | | | | X | |

| សង្ខេបលទ្ធផលរំពឹងទុក | ការប្រាស្រ័យទាក់ទង | ការអភិវឌ្ឍសមត្ថភាព | ការត្រួតពិនិត្យវាយតម្លៃ | ព័ត៌មានវិទ្យា | ភាពជាដៃគូជាមួយសង្គមស៊ីវិល | បរិយាប័ន្ននិងសមធម៌សង្គម | ការកែសម្រួលរចនាសម្ព័ន្ធ | ការសាកល្បង |
|---|---|---|---|---|---|---|---|---|
| **សមាសភាគទី៥ ៖ វិមជ្ឈការហិរញ្ញវត្ថុ** | | | | | | | | |
| ៥.១.១. មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ | | | X | | | X | | |
| ៥.១.២. ចំណូលរដ្ឋបាលថ្នាក់ក្រោមជាតិ | | X | | | | | | X |
| ៥.១.៣. មូលនិធិមានភ្ជាប់លក្ខខណ្ឌ | | X | X | | | X | | X |
| ៥.១.៤. មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | | X | X | | | | | |

## ៣. ការរៀបចំបែបផែននានានៃអភិបាលកិច្ច

មកទល់បច្ចុប្បន្ននេះ បែបផែននានាក្នុងការគាំទ្រអភិបាលកិច្ច និងការគ្រប់គ្រងលទ្ធផលការងារត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីធានាដល់ការដឹកនាំសម្របសម្រួលរបស់ គ.ជ.អ.ប. ក្នុងការអនុវត្តនូវផអ៣នីមួយៗ ដែលមានការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នានាផងដែរ។

ជារួម រួមមានដៃគូអភិវឌ្ឍន៍ចំនួន១៧ដែលបានចូលរួមគាំទ្រដល់ការអនុវត្តផអ៣ទី៣ ដោយបានបង្កើតជាគម្រោង ឬកម្មវិធីមានលក្ខណៈដាច់ដោយឡែកៗចំនួន៣២។ គម្រោង ឬកម្មវិធីដាច់ដោយឡែកភាគច្រើនបានបង្កើតនូវគណៈគ្រប់គ្រងគម្រោងរបស់ខ្លួន។ ជាមួយគ្នានេះដែរ គម្រោង ឬកម្មវិធីទាំងនោះក៏មានវិធាន គោលការណ៍ ប្រព័ន្ធនិងនីតិវិធីហិរញ្ញវត្ថុ និងកាលវិភាគនៃការទូទាត់របស់ខ្លួនផ្សេងៗគ្នាផងដែរ។

ក្នុងអំឡុងពេលនៃការអនុវត្តផអ៣ទី១ និងផអ៣ទី២កន្លងមក គម្រោង និងកម្មវិធីដាច់ដោយឡែកៗទាំងនោះក៏ត្រូវបានសម្របសម្រួល និងគាំទ្រដោយថវិកាកញ្ចប់រួមរបស់ គ.ជ.អ.ប ដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍សំខាន់ៗមួយចំនួន។ ថវិកាកញ្ចប់រួមនាពេលបច្ចុប្បន្នកំពុងត្រូវបានផ្តល់ហិរញ្ញប្បទានដោយ ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិស៊ុយអែត (Sida) ទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍស្វីស (SDC) និង សហភាពអឺរ៉ុប (EU) ព្រមទាំងមានការចូលរួមផ្តល់ហិរញ្ញប្បទានសម្រាប់សកម្មភាពជាក់លាក់មួយចំនួនពីមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (UNICEF) មូលនិធិអភិវឌ្ឍមូលធនរបស់អង្គការសហប្រជាជាតិ (UNCDF) និងកម្មវិធីស្បៀងអាហារពិភពលោក (WFP) ផងដែរ។

ដៃគូអភិវឌ្ឍន៍ទាំងអស់ និងតំណាងអង្គការសង្គមស៊ីវិលមួយចំនួនដែលពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានចូលរួមកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យ ពិភាក្សា និងផ្តល់ការឯកភាពលើគម្រោងផែនការថវិកា និងរបាយការណ៍នានាពាក់ព័ន្ធនឹងការអនុវត្តផអ៣។ លក្ខខណ្ឌការងាររបស់ក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក៏ត្រូវបានកែសម្រួល ហើយយន្តការនេះក៏តែងបានកោះប្រជុំ២ដងក្នុងមួយឆ្នាំ និងបានប្រើប្រាស់នូវសូចនាករត្រួតពិនិត្យរួមគ្នា (JMI) ដើម្បីសម្របសម្រួលនូវការពិភាក្សាផ្នែកគោលនយោបាយផងដែរ។

## គ. ការគ្រប់គ្រងហិរញ្ញវត្ថុ

នីតិវិធីនានាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស និងកិច្ចការរដ្ឋបាលនៃមូលនិធិកញ្ចប់រួមត្រូវបានអនុវត្តតាមសៀវភៅណែនាំស្តីពីនីតិវិធីហិរញ្ញវត្ថុ និងរដ្ឋបាលរបស់ គ.ជ.អ.ប. នាពេលបច្ចុប្បន្ន។ សៀវភៅណែនាំនេះកំពុងត្រូវបានពិនិត្យ និងកែសម្រួលឡើងវិញ ដើម្បីធានាដល់ការគ្រប់គ្រង ចាត់ចែងការងារហិរញ្ញវត្ថុ ធនធានមនុស្ស និងកិច្ចការរដ្ឋបាលឱ្យកាន់តែល្អប្រសើរ ឆ្លើយតបទៅនឹងគោលការណ៍នានារបស់រាជរដ្ឋាភិបាល និងល័ក្ខខ័ណ្ឌនានារបស់ដៃគូអភិវឌ្ឍន៍។

សារធាតុសំខាន់ៗនៃវិធីសាស្ត្រគ្រប់គ្រងហិរញ្ញវត្ថុនៃផអ៣ទី៣រួមមាន៖

**ការទូទាត់ និងការងារគណនេយ្យ៖**

លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការកៀរគរ និងគ្រប់គ្រងចាត់ចែងថវិការបស់ផអ៣។ គណនីធនាគារនឹងត្រូវបានប្រើប្រាស់សម្រាប់ថវិកាកញ្ចប់រួម (រួមបញ្ចូលទាំងថវិកាដែលគាំទ្រEU តាមបែបផែនការទ្រទ្រង់ថវិកាដែលផ្តល់ឱ្យតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និងសម្រាប់គម្រោងនីមួយៗ។ ស្ថាប័នអនុវត្តនីមួយៗត្រូវបើកគណនីបំពេញបន្ថែមរបស់ខ្លួននៅធនាគារណាមួយ។ ផ្អែកតាមសេចក្តីសម្រេចរួម លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវផ្ទេរថវិកាទៅគណនីបំពេញបន្ថែមនៃស្ថាប័នអនុវត្តទាំងនេះ ដើម្បីប្រើប្រាស់សម្រាប់តែលើការអនុវត្តសកម្មភាពដែលបានឯកភាពគ្នា។ ថវិកាបុរេប្រទាននឹងត្រូវបានផ្តល់ទៅឱ្យស្ថាប័នអនុវត្តនានានៅដើមឆ្នាំនីមួយៗ ហើយបន្ទាប់មកនឹងផ្តល់ថវិកាបំពេញបន្ថែមដោយផ្អែកតាមរបាយការណ៍ហិរញ្ញវត្ថុ និងការត្រួតពិនិត្យពីវឌ្ឍនភាពការងារ តាមរយៈប្រព័ន្ធទិន្នន័យត្រួតពិនិត្យផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប។

**សវនកម្ម៖**

សុវត្ថភាពផ្នែកហិរញ្ញវត្ថុរួមមាន យន្តការត្រួតពិនិត្យផ្ទៃក្នុងនានា និងការធ្វើសវនកម្មផ្ទៃក្រៅ។ ការត្រួតពិនិត្យផ្ទៃក្នុងមានគោលបំណង៖ (១) ធានាដល់ការប្រើប្រាស់ធនធានថវិកាដោយមិនមានការខ្ជះខ្ជាយ មិនមានកំហុសឆ្គង និងគ្មានការអនុញ្ញាត (២) លើកម្ពស់នូវភាពត្រឹមត្រូវ និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ និងកំណត់ត្រាហិរញ្ញវត្ថុ និង (៣) ពង្រឹងការអនុវត្តត្រឹមត្រូវតាមបែបបទ និងនីតិវិធីនានាដែលបានកំណត់។

ផ្អែកតាមសៀវភៅណែនាំស្តីពីសវនកម្មផ្ទៃក្នុងរបស់ គ.ជ.អ.ប. (កំពុងកែសម្រួល) ក្រុមសវនករផ្ទៃក្នុងត្រូវចុះធ្វើសវកម្មយ៉ាងទៀតទាត់តាមពេលកំណត់ ធ្វើរបាយការណ៍អំពីលទ្ធផលនៃការធ្វើសវនកម្មជូនថ្នាក់ដឹកនាំ និងផ្តល់អនុសាសន៍នានាដើម្បីកែលម្អនីតិវិធីដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន។

ការធ្វើសវនកម្មឯករាជ្យពីខាងក្រៅទៅលើកិច្ចប្រតិបត្តិ និងគណនីនានានៃផអ៣ (គណនីថវិកាកញ្ចប់រួម និងគណនីរបស់គម្រោងគាំទ្រនានាដែលគ្រប់គ្រងដោយលេខាធិការដ្ឋាន គ.ជ.អ.ប) នឹងត្រូវបានអនុវត្តដោយក្រុមហ៊ុនសវនកម្មឯករាជ្យដែលមានជំនាញច្បាស់លាស់ តាមរយៈកិច្ចលទ្ធកម្មដែលមានលក្ខណៈប្រកួតប្រជែង។

គណៈកម្មាធិការសវនកម្មមួយ ត្រូវបានបង្កើតឡើងសម្រាប់ការគ្រប់គ្រងកម្មវិធីរបស់ផអ៣ទី៣ ដែលសមាសភាពនៃគណៈកម្មាធិការទាំងនេះរួមមានប្រធានលេខាធិការដ្ឋាន (ឬតំណាងរបស់ប្រធានលេខាធិការដ្ឋាន) ជាប្រធាន និងតំណាងដៃគូអភិវឌ្ឍន៍មួយចំនួន។ គណៈកម្មាធិការនេះនឹងទទួលខុសត្រូវលើ៖ (១) ការកំណត់អំពីវិសាលភាពនៃការធ្វើសវនកម្មលើកម្មវិធី (២) ការអនុម័តលើល័ក្ខខ័ណ្ឌការងារនៃការជ្រើសរើសក្រុមហ៊ុនសវនកម្មផ្ទៃក្រៅ (៣) ការពិនិត្យលើរបាយការណ៍ និងអនុសាសន៍នានារបស់សវនកម្មផ្ទៃក្រៅ និង(៤) ការត្រួតពិនិត្យតាមដានការអនុវត្តអនុសាសន៍ទាំងនោះ។

សវនកម្មផ្ទៃក្រៅស្វែងរកឱ្យឃើញអំពីកម្រិតនៃភាពដ៏ត្រឹមត្រូវយ៉ាងពិតប្រាកដដែលរួមមាននៅក្នុងកិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងវាយតម្លៃទៅលើភាពសមស្រប និងសុចរិតភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងត្រួតពិនិត្យលើការអនុវត្តស្របតាមនីតិវិធិហិរញ្ញវត្ថុ រួមបញ្ចូលទាំងកិច្ចលទ្ធកម្មផងដែរ។

**កិច្ចលទ្ធកម្ម៖**

កិច្ចលទ្ធកម្មត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីដែលមានចែងនៅក្នុងសៀវភៅណែនាំស្តីពីនីតិវិធីហិរញ្ញវត្ថុ និងរដ្ឋបាលរបស់ គ.ជ.អ.ប។ កិច្ចលទ្ធកម្មនានានឹងត្រូវអនុវត្តឱ្យបានទាន់ពេលវេលាដែលបានកំណត់ និងត្រូវជ្រើសរើសនូវបេក្ខជន ឬអ្នកផ្គត់ផ្គង់ដែលមានលក្ខណៈសម្បត្តិល្អជាងគេ។ កិច្ចលទ្ធកម្មជ្រើសរើសទីប្រឹក្សាបច្ចេកទេស និងអ្នកផ្គត់ផ្គង់នានានឹងត្រូវទទួលខុសត្រូវរួមគ្នារវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងស្ថាប័នអនុវត្តនានា ពោលគឺ ៖

- ស្ថាប័នអនុវត្តត្រូវរៀបចំសេចក្តីព្រាងលក្ខខណ្ឌការងារ ដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យមុនពេលប្រកាសផ្សាយជ្រើសរើស
- លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវពិនិត្យសេចក្តីព្រាងទាំងនោះ ហើយប្រសិនបើឯកភាព ត្រូវចេញលិខិតបញ្ជាក់ពី"**ភាពមិនជំទាស់**" ជូនទៅស្ថាប័នអនុវត្តវិញ
- ការផ្តល់អនុសាសន៍សម្រាប់ការជ្រើសរើសទីប្រឹក្សាបច្ចេកទេស ឬអ្នកផ្គត់ផ្គង់ត្រូវធ្វើឡើងដោយគណៈកម្មការត្រួតពិនិត្យមួយ ដែលមានតំណាងពីស្ថាប័នអនុវត្ត និងលេខាធិការដ្ឋាន គ.ជ.អ.ប
- ការជ្រើសរើសទីប្រឹក្សាបច្ចេកទេស ឬអ្នកផ្គត់ផ្គង់ត្រូវបានសម្រេចដោយគណៈកម្មាធិការលទ្ធកម្មរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- ស្ថាប័នអនុវត្តត្រូវទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យា និងសម្រេចអនុញ្ញាតឱ្យធ្វើការទូទាត់
- ផ្អែកលើការសម្រេចអនុញ្ញាតឱ្យធ្វើការទូទាត់របស់ស្ថាប័នអនុវត្ត លេខាធិការដ្ឋាន គ.ជ.អ.ប ទទួលខុសត្រូវក្នុងការទូទាត់លើការចំណាយទាំងនោះ។
- លេខាធិការដ្ឋាន គ.ជ.អ.ប ក៏ទទួលខុសត្រូវក្នុងការទូទាត់ដល់កិច្ចសន្យាទីប្រឹក្សាបច្ចេកទេសរយៈពេលវែងនានា តាមរយៈប្រព័ន្ធទិន្នន័យប្រាក់បៀវត្ស ដោយកាត់ចេញនូវចំណាយ

នេះពីថវិកាដែលបានវិភាជន៍ទៅឱ្យស្ថាប័នអនុវត្តពាក់ព័ន្ធ។ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវជូនដំណឹងទៅស្ថាប័នអនុវត្តអំពីការចំណាយដែលបានទូទាត់រួចហើយ និងតុល្យភាពថវិការបស់ស្ថាប័នអនុវត្តនោះ។

ប្រព័ន្ធ និងនីតិវិធីនានាសម្រាប់ប្រតិបត្តិការផអ៣ទី៣មានភាពសាំញ៉ាំ និងស្មុគស្មាញបំផុត ដោយសារនីតិវិធីទាំងនេះត្រូវអនុវត្តដោយផ្អែកលើលក្ខខណ្ឌផ្សេងៗគ្នានៃប្រភពធនធាននីមួយៗ ដែលពាក់ព័ន្ធនឹងការកសាងផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងការងាររដ្ឋបាល និងការរៀបចំរបាយការណ៍ ។ ជារួម ផអ៣ទី៣ត្រូវបានអនុវត្តតាមនីតិវិធី៤ប្រភេទផ្សេងៗគ្នាគឺ ៖

- **នីតិវិធីនៃការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**ត្រូវបានអនុវត្តក្នុងពេលដែលរដ្ឋបាលថ្នាក់ក្រោមជាតិ បានទទួលនូវការផ្ទេរថវិកាពីថ្នាក់ជាតិ និងពីចំណូលផ្ទាល់នៅមូលដ្ឋាននានា។ ឧទាហរណ៍ ផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុម័តដោយក្រុមប្រឹក្សា ការត្រួតពិនិត្យមើលពីលើត្រូវអនុវត្តដោយក្រុមប្រឹក្សា (ពុំមែនដោយលេខាធិការដ្ឋាន គ.ជ.អ.ប.) គម្រោងនានាត្រូវបានគ្រប់គ្រងចាត់ចែងផ្អែកតាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងរបស់រដ្ឋាភិបាល បណ្តឹងនានាត្រូវបានប្រមូល សម្រុះសម្រួល និងដោះស្រាយដោយរដ្ឋបាលថ្នាក់ក្រោមជាតិ គណនីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើសវនកម្មដោយអាជ្ញាធរសវនកម្មជាតិ។ នីតិវិធីទាំងនេះត្រូវបានធ្វើវិមជ្ឈការ។
- **នីតិវិធីរបស់ក្រសួង ស្ថាប័ន**មានលក្ខណៈខុសគ្នាពីនីតិវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងក្របខណ្ឌនៃការកសាងផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ អភិបាលកិច្ច ការធ្វើរបាយការណ៍ ។ល។
- **នីតិវិធីរបស់ថវិកាកញ្ចប់រួមរបស់ ផអ៣** ត្រូវបានអនុវត្តសម្រាប់ស្ថាប័នអនុវត្តទាំងអស់របស់ផអ៣ក្នុងការប្រើប្រាស់ថវិកាកញ្ចប់រួម។ នីតិវិធីទាំងនេះត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍នានារបស់រដ្ឋ ក៏ប៉ុន្តែចាំបាច់ត្រូវឆ្លើយតបទៅនឹងលក្ខខណ្ឌមួយចំនួនរបស់ដៃគូអភិវឌ្ឍន៍នានាបន្ថែមទៀត។ នីតិវិធីទាំងនេះត្រូវបានកំណត់នៅក្នុងសៀវភៅណែនាំស្តីពីនីតិវិធីហិរញ្ញវត្ថុ និងនីតិវិធីរដ្ឋបាល សៀវភៅណែនាំស្តីពីសវនកម្មផ្ទៃក្នុង យុទ្ធសាស្ត្រស្តីពីការត្រួតពិនិត្យនិងការវាយតម្លៃ និងសៀវភៅណែនាំស្តីពីការរៀបចំផែនការសកម្មភាព និងថវិកា របស់ គ.ជ.អ.ប.។
- **នីតិវិធីរបស់គម្រោងដាច់ដោយឡែក**ត្រូវបានរៀបចំតាក់តែងដោយដៃគូអភិវឌ្ឍន៍ និងផ្អែកទៅលើនីតិវិធីរបស់ដៃគូអភិវឌ្ឍន៍នានា រួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (WB) និងមូលនិធិអាកាសធាតុបៃតង (GCF) សម្រាប់ការពិនិត្យវាយតម្លៃ ការរៀបចំរបាយការណ៍ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោង។ល។

## ឃ. គម្រោងថវិកាកម្មវិធី

ថវិកាប៉ាន់ស្មានរបស់ផអ៣ទី៣រួមមាន ថវិកាសម្រាប់ការគាំទ្រសកម្មភាពស្នូលនៃកំណែទម្រង់ និងធនធានមូលនិធិដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ធនធានមូលនិធិដែលផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាល គឺសម្រាប់ចំណាយលើប្រាក់បៀវត្សរបស់បុគ្គលិក ចំណាយប្រតិបត្តិការ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ធនធាន មូលនិធិសម្រាប់បែងចែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានផ្ទេរជាដំណាក់កាលនីមួយៗជាប្រចាំតាមប្រព័ន្ធដែលបានបង្កើតឡើងរួចហើយ អាស្រ័យហេតុនេះ ធនធាននេះពុំត្រូវបានកំណត់ថាជាធនធានសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ឡើយ។ ជាទូទៅ ធនធានសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ត្រូវបានវិនិយោគទៅលើការផ្តួចផ្តើមគំនិតថ្មីៗនានា ជាពិសេសការវិនិយោគទៅលើការអភិវឌ្ឍសមត្ថភាព និងការកែលម្អគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានាសំដៅលើកកម្ពស់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ថវិកាសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ត្រូវបានហិរញ្ញប្បទានគាំទ្រពីប្រភពសំខាន់ៗចំនួន៤ ពោលគឺ (១) រាជរដ្ឋាភិបាលផ្តល់ហិរញ្ញប្បទានតាមរយៈថវិការបស់ស្ថាប័នអនុវត្តនានា (២) ដៃគូអភិវឌ្ឍន៍ផ្តល់ថវិកាឆន្ទានុសិទ្ធិក្នុងនាមជាកញ្ចប់ថវិការួមដល់ផអ៣ទី៣ (៣) រាជរដ្ឋាភិបាលអនុវត្តនូវគម្រោងកម្មវិធីអភិវឌ្ឍនានាដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និង (៤) រាជរដ្ឋាភិបាលទទួលយកហិរញ្ញប្បទានកម្ចីពីដៃគូអភិវឌ្ឍន៍នានាដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់ (ការចំណាយទៅលើបុគ្គលិក និងអាគារ សម្ភារ ឧបករណ៍នានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នអនុវត្តនានា មិនត្រូវបានគិតបញ្ចូលជាធនធានសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ឡើយ)។ ជារួម ក្នុងអំឡុងពេលនៃការអនុវត្តផអ៣ទី៣ ចំណាយសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ មានចំនួនប្រមាណ៧៧លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ដោយឡែកធនធានមូលនិធិសរុបទាំងសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ និងការផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនប្រមាណ៦៣០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ធនធាន និងចំណាយប៉ាន់ស្មានសរុបរបស់ ផអ៣ទី៣ មានដូចក្នុងតារាងខាងក្រោម។

**តារាងទី១៨៖ ទិដ្ឋភាពទូទៅនៃថវិកា ផអ៣ទី៣ (គិតជាលានដុល្លារអាមេរិក)**

| បរិយាយ | ថវិកាដែលមាន | | | | គម្រោងចំណាយ | | | ឱនភាពថវិកា | | |
|---|---|---|---|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | % | 2018 | 2019 | 2020 | 2018 | 2019 | 2020 |
| **សកម្មភាពស្នូលនៃកំណែទម្រង់** | 72.64 | 75.13 | 82.27 | 12.1% | 75.44 | 75.63 | 83.12 | -2.81 | -0.50 | -0.85 |
| • មូលនិធិឆន្ទានុសិទ្ធិ | 20.92 | 21.72 | 24.58 | 3.5% | 23.72 | 22.22 | 25.43 | -2.81 | -0.50 | -0.85 |
| – ថវិការាជរដ្ឋាភិបាល | 11.02 | 7.82 | 10.68 | 1.6% | | | | | | |
| – មូលនិធិកញ្ចប់រួម | 9.90 | 13.90 | 13.90 | 2.0% | | | | | | |
| • គម្រោងរបស់ដៃគូអភិវឌ្ឍ | 15.67 | 14.42 | 13.26 | 2.3% | 15.67 | 14.42 | 13.26 | 0.00 | 0.00 | 0.00 |
| • កម្ចីរបស់រាជរដ្ឋាភិបាល | 36.05 | 38.98 | 44.43 | 6.3% | 36.05 | 38.98 | 44.43 | 0.00 | 0.00 | 0.00 |
| **ធនធានមូលនិធិផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ** | 469.47 | 553.73 | 641.71 | 87.9% | 469.47 | 553.73 | 641.71 | 0.00 | 0.00 | 0.00 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| • រាជរដ្ឋាភិបាល | 465.47 | 553.73 | 641.71 | 87.6% | 465.47 | 553.73 | 641.71 | 0.00 | 0.00 | 0.00 |
| • សហភាពអឺរ៉ុប | 4.00 | 0.00 | 0.00 | 0.2% | 4.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| **សរុបរួម** | 542.11 | 628.86 | 723.98 | 100.0% | 544.92 | 629.36 | 724.83 | -2.81 | -0.50 | -0.85 |

តារាងខាងលើបានបង្ហាញឱ្យឃើញថា ថវិកាសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់មានចំនួនប្រមាណ១២,១%នៃធនធានប៉ាន់ស្មានសរុបរបស់ផអ៣ទី៣។ កញ្ចប់ថវិការួមដែលផ្តល់មូលនិធិគាំទ្រដោយដៃគូអភិវឌ្ឍន៍ (រួមបញ្ចូលទាំងការគាំទ្រថវិការបស់សហភាពអឺរ៉ុប) មានចំនួនប្រមាណ២%នៃធនធានសរុប។ គម្រោង កម្មវិធីដាច់ដោយឡែកនានាដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍នានាមានចំនួនប្រមាណ២,៣% និងថវិកាកម្ចីរបស់រាជរដ្ឋាភិបាលមានចំនួន៦,៣%។ ជារួម គម្រោងថវិការបស់ផអ៣ទី៣ បានបង្ហាញឱ្យឃើញនូវឱនភាពថវិកាចំនួនប្រមាណ២,៨លានដុល្លារក្នុងឆ្នាំ២០១៨ ចំនួនប្រមាណ០,៥លានដុល្លារក្នុងឆ្នាំ២០១៩ និងចំនួនប្រមាណ០,៨៥លានដុល្លារក្នុងឆ្នាំ២០២០ ដុល្លារ។ ថវិកាប៉ាន់ ស្មានលម្អិតត្រូវបានគណនា និងមានបរិយាយដូចខាងក្រោម។

## ១. ចំណាយប៉ាន់ស្មាន

ក្នុងការអនុវត្តផអ៣ទី៣ ថវិកាចំណាយសរុបសម្រាប់សកម្មភាពស្នូលនៃកំណែទម្រង់ត្រូវបានប៉ាន់ស្មានចំនួន៧២លានដុល្លារសម្រាប់ឆ្នាំ២០១៨ ចំនួន៧៥លានដុល្លារសម្រាប់ឆ្នាំ២០១៩ និងចំនួន៨២លានដុល្លារសម្រាប់ឆ្នាំ២០២០។ ថវិកាចំណាយទាំងនេះ បានមកពីការបូកសរុបនូវថវិកាចំណាយរបស់លទ្ធផលរំពឹងទុកទាំង៤៤នៃផអ៣ទី៣ ថវិកាចំណាយសម្រាប់គម្រោងដាច់ដោយឡែកនានា និងថវិកាកម្ចីដែលរាជរដ្ឋាភិបាលទទួលពីដៃគូនានា។ ថវិកាចំណាយរួមបញ្ចូលនូវថវិកាចំណាយសម្រាប់ទីប្រឹក្សានិងបុគ្គលិកកិច្ចសន្យារយៈពេលវែង ថវិកាចំណាយសម្រាប់កិច្ចប្រតិបត្តិការ និងថវិកាចំណាយសម្រាប់ការអនុវត្តសកម្មភាពជាចម្បងនានា។ ថវិកាចំណាយប៉ាន់ស្មានតាមលទ្ធផលរំពឹងទុកនីមួយៗមានសង្ខេបនៅក្នុងតារាងខាងក្រោម។

### តារាងទី១៩៖ ចំណាយប៉ាន់ស្មានតាមលទ្ធផលរំពឹងទុកនីមួយៗ (គិតជាដុល្លារ)

| ការបរិយាយ | ២០១៨ | ២០១៩ | ២០២០ | សរុប | ភាគរយ |
|---|---|---|---|---|---|
| ក. ការចំណាយលើសកម្មភាពស្នូលនៃកំណែទម្រង់ | | | | | |
| **សមាសភាគទី១ ៖ ការគ្រប់គ្រងការងារកំណែទម្រង់** | **5,777,696** | **3,930,746** | **4,007,296** | **13,715,738** | **5.9%** |
| ១.១.១. ការកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន | 161,200 | 209,600 | 348,200 | 719,000 | 0.3% |
| ១.១.២. កម្មវិធីជាតិដំណាក់កាលបន្ទាប់ | 0 | 99,000 | 236,500 | 335,500 | 0.1% |
| ១.១.៣. និរន្តរភាពហិរញ្ញវត្ថុនៃកម្មវិធី | 50,000 | 100,000 | 50,000 | 200,000 | 0.1% |
| ១.២.១. កិច្ចពិភាក្សាកម្រិតនយោបាយ | 489,900 | 489,900 | 489,900 | 1,469,700 | 0.6% |
| ១.២.២. ការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មាន | 328,100 | 446,250 | 523,200 | 1,297,550 | 0.6% |
| ១.២.៣. ការសាកល្បង និងការសិក្សារៀនសូត្រ | 2,524,800 | 153,500 | 153,500 | 2,831,800 | 1.2% |
| ១.២.៤. ពង្រឹងសមាគមក្រុមប្រឹក្សា | 416,596 | 389,096 | 289,096 | 1,094,788 | 0.5% |
| ១.៣.១. ភាពជាដៃគូជាមួយសង្គមស៊ីវិល | 135,900 | 135,900 | 66,600 | 338,400 | 0.1% |
| ១.៤.១. ការគ្រប់គ្រងគម្រោង | 491,820 | 665,520 | 534,420 | 1,691,760 | 0.7% |
| ១.៤.២. សុខដុមនីយកម្ម នៃគម្រោងនានា | 78,700 | 33,000 | 16,500 | 128,200 | 0.1% |
| ១.៤.៣. ការគាំទ្ររដ្ឋបាល និងហិរញ្ញវត្ថុកម្មវិធី | 1,100,680 | 1,208,980 | 1,299,380 | 3,609,040 | 1.5% |

| ការបរិយាយ | ២០១៨ | ២០១៩ | ២០២០ | សរុប | ភាគរយ |
|---|---|---|---|---|---|
| **សមាសភាគទី២ ៖ អភិបាលកិច្ចល្អ** | **11,464,200** | **12,254,550** | **11,838,200** | **35,556,950** | **15.2%** |
| ២.១.១. គណនេយ្យភាពសង្គម | 8,177,600 | 8,152,600 | 7,979,800 | 24,310,000 | 10.4% |
| ២.១.២. ការដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ | 214,500 | 300,000 | 280,000 | 794,500 | 0.3% |
| ២.២.១. ការពង្រឹងតួនាទីរបស់ក្រុមប្រឹក្សា | 142,400 | 142,000 | 160,000 | 444,400 | 0.2% |
| ២.៣.១. អធិការកិច្ចលើការអនុវត្តតាមច្បាប់ | 271,300 | 381,300 | 543,300 | 1,195,900 | 0.5% |
| ២.៣.២. ការវាយតម្លៃប្រចាំឆ្នាំអំពីការអនុវត្តការងារ | 99,000 | 275,500 | 275,500 | 650,000 | 0.3% |
| ២.៤.១. ពិនិត្យនិងកែសម្រួលប្រព័ន្ធនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 152,400 | 245,350 | 71,000 | 468,750 | 0.2% |
| ២.៤.២. ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង | 115,400 | 160,400 | 102,800 | 378,600 | 0.2% |
| ២.៤.៣. ប្រព័ន្ធកសាងផែនការ | 126,200 | 126,200 | 103,100 | 355,500 | 0.2% |
| ២.៤.៤. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ | 135,000 | 162,500 | 135,000 | 432,500 | 0.2% |
| ២.៥.១. បង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង | 359,200 | 375,700 | 375,700 | 1,110,600 | 0.5% |
| ២.៥.២. ការលើកកម្ពស់សមធម៌ និងបរិយាប័ន្នសង្គម | 344,200 | 386,000 | 325,500 | 1,055,700 | 0.5% |
| ២.៥.៣. សេវាសុវត្ថិភាពសង្គម | 1,028,900 | 1,248,900 | 1,211,500 | 3,489,300 | 1.5% |
| ២.៥.៤. ការអភិវឌ្ឍសមត្ថភាពអំពីសមធម៌ និងបរិយាប័ន្នសង្គម | 298,100 | 298,100 | 275,000 | 871,200 | 0.4% |
| **សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** | **11,998,998** | **8,816,249** | **7,509,550** | **28,324,797** | **12.1%** |
| ៣.១.១. ការគ្រប់គ្រងធនធានមនុស្ស | 77,918 | 99,369 | 56,470 | 233,757 | 0.1% |
| ៣.២.១. អភិក្រមនៃការអភិវឌ្ឍសមត្ថភាព | 309,500 | 390,800 | 493,000 | 1,193,300 | 0.5% |
| ៣.២.២. អនុវត្តការអភិវឌ្ឍសមត្ថភាព | 5,092,080 | 4,826,080 | 4,460,080 | 14,378,240 | 6.1% |
| ៣.២.៣. ការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន | 6,519,500 | 3,500,000 | 2,500,000 | 12,519,500 | 5.3% |
| **សមាសភាគទី៤ ៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន** | **40,072,936** | **39,720,658** | **47,530,471** | **127,324,064** | **54.4%** |
| ៤.១.១. លិខិតបទដ្ឋានសម្រាប់អនុវត្តមុខងារជាអាណត្តិទូទៅ | 140,400 | 76,050 | 46,800 | 263,250 | 0.1% |
| ៤.១.២. បទពិសោធល្អៗអំពីការអនុវត្តមុខងារជាអាណត្តិទូទៅ | 44,918 | 87,819 | 87,820 | 220,557 | 0.1% |
| ៤.១.៣. កញ្ចប់ថវិកាសម្រាប់អនុវត្តសាកល្បងមុខងារជាអាណត្តិទូទៅ | 96,800 | 467,500 | 1,329,350 | 1,893,650 | 0.8% |
| ៤.១.៤. ការអនុវត្តមុខងារជាអាណត្តិទូទៅ | 95,800 | 31,450 | 31,450 | 158,700 | 0.1% |
| ៤.១.៥. ការអនុវត្តគម្រោងប្រែប្រួលអាកាសធាតុ សេវាសង្គម... | 31,065,268 | 34,588,139 | 40,865,451 | 106,518,857 | 45.5% |
| ៤.២.១. ការរៀបចំលិខិតបទដ្ឋានសម្រាប់ការផ្ទេរមុខងារ | 468,300 | 481,500 | 135,000 | 1,084,800 | 0.5% |
| ៤.២.២. ផែនការសកម្មភាពផ្ទេរមុខងារ | 150,000 | 150,000 | 50,000 | 350,000 | 0.1% |
| ៤.២.៣. ការផ្ទេរមុខងារ | 198,000 | 946,000 | 1,562,000 | 2,706,000 | 1.2% |
| ៤.២.៤. យន្តការការិយាល័យច្រកចេញចូលតែមួយ | 7,600,000 | 2,500,000 | 3,000,000 | 13,100,000 | 5.6% |
| ៤.៣.១. គោលនយោបាយ និងស្តង់ដានៃការផ្តល់សេវា | 113,850 | 227,700 | 227,700 | 569,250 | 0.2% |
| ៤.៤.១. ខេត្តបំពេញតួនាទីគាំទ្រ និងត្រួតពិនិត្យ | 37,950 | 141,900 | 174,900 | 354,750 | 0.2% |
| ៤.៤.២. ក្រុង ស្រុកផ្តល់សេវាគាំទ្រដល់ឃុំ សង្កាត់ | 61,650 | 22,600 | 20,000 | 104,250 | 0.0% |
| **សមាសភាគទី៥ ៖ វិមជ្ឈការហិរញ្ញវត្ថុ** | **6,130,462** | **10,907,191** | **12,234,130** | **29,271,782** | **12.5%** |
| ៥.១.១. មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ | 125,400 | 56,100 | 102,300 | 283,800 | 0.1% |
| ៥.១.២. ចំណូលរដ្ឋបាលថ្នាក់ក្រោមជាតិ | 57,200 | 34,100 | 91,300 | 182,600 | 0.1% |
| ៥.១.៣. មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ | 34,100 | 176,000 | 497,200 | 707,300 | 0.3% |
| ៥.១.៤. មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | 5,913,762 | 10,640,991 | 11,543,330 | 28,098,082 | 12.0% |
| **សរុបរង** | **75,444,291** | **75,629,394** | **83,119,646** | **234,193,331** | **100%** |
| **ថវិកាដែលមាន** | **72,638,529** | **75,133,130** | **82,267,780** | **230,039,439** | |
| **ឱនភាពថវិកា** | **-2,805,762** | **-496,264** | **-851,866** | **-4,153,892** | |
| ខ. ការផ្ទេរធនធានមូលនិធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | |
| **ធនធានមូលនិធិរាជរដ្ឋាភិបាល** | 465,474,390 | 553,730,297 | 641,709,184 | 1,660,913,870 | |
| **ធនធានមូលនិធិគាំទ្រដោយសហភាពអឺរ៉ុប** | 4,000,000 | 0 | 0 | 4,000,000 | |
| **សរុបរង** | **469,474,390** | **553,730,297** | **641,709,184** | **1,664,913,870** | |
| **សរុបរួម** | **544,918,681** | **629,359,691** | **724,828,830** | **1,899,107,202** | |

ថវិកាចំណាយត្រូវបានបែងចែកជា៣ប្រភេទរួមមាន ចំណាយសម្រាប់ជំនួយបច្ចេកទេស ចំណាយសម្រាប់សកម្មភាពនានា និងចំណាយសម្រាប់កិច្ចប្រតិបត្តិការទូទៅ ដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម។

តារាងខាងក្រោមបង្ហាញឱ្យឃើញអំពី ៖

- ថវិកាចំណាយប៉ាន់ស្មានសម្រាប់ជំនួយបច្ចេកទេសរយៈពេលវែងមានការថយចុះយ៉ាងខ្លាំង គឺថយចុះរហូតដល់ចំនួនប្រមាណ**៣,៤**លានដុល្លារនៅក្នុងឆ្នាំ២០២០។
- ថវិកាសម្រាប់ការរៀបចំប្រព័ន្ធផ្ដល់ថវិកាសម្រាប់ការសាកល្បងមួយចំនួនត្រូវបានគ្រោង
- ថវិកាចំណាយប៉ាន់ស្មានសរុបសម្រាប់សេវាទីប្រឹក្សារយៈពេលខ្លីមានចំនួនប្រមាណ១,៧ លានដុល្លារក្នុងមួយឆ្នាំៗ ដែលក្នុងនោះថវិកាចំណាយមួយចំនួនរំពឹងថានឹងបានទទួលពីថវិកាបំពេញបន្ថែមនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុបស្ដីពីការគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២។

**តារាងទី២០៖ ប្រភេទចំណាយ (មិនគិតបញ្ចូលគម្រោងដាច់ដោយឡែក និងថវិកាកម្ចី) គិតជាដុល្លារ**

| ប្រភេទចំណាយ | ២០១៨ | ២០១៩ | ២០២០ | សរុប | ភាគរយ |
|---|---|---|---|---|---|
| ជំនួយបច្ចេកទេសរយៈពេលវែង | 4,254,480 | 3,853,680 | 3,377,280 | 11,485,440 | 16.09% |
| កិច្ចប្រតិបត្តិការ | 2,950,000 | 3,150,002 | 3,250,002 | 9,350,004 | 13.10% |
| សកម្មភាពនានា | 16,519,544 | 15,217,573 | 18,806,914 | 50,544,030 | 70.81% |
| - កញ្ចប់ថវិកាសម្រាប់ការសាកល្បង | 0 | 625,000 | 1,700,000 | 2,325,000 | 3.26% |
| - សេវាទីប្រឹក្សារយៈពេលខ្លី | 1,737,018 | 1,797,469 | 1,577,420 | 5,111,907 | 7.16% |
| - ផ្សេងទៀត | 14,782,526 | 12,795,104 | 15,529,494 | 43,107,123 | 60.39% |
| **សរុប** | **23,724,024** | **22,221,255** | **25,434,196** | **71,379,474** | **100%** |

## ២. ប្រភពនានានៃការផ្ដល់មូលនិធិគាំទ្រផអ៣ទី៣

ព័ត៌មានលម្អិតអំពីប្រភពនានានៃការផ្ដល់មូលនិធិគាំទ្រផអ៣ទី៣ មានរៀបរាប់ក្នុងតារាងខាងក្រោម ។

**តារាងទី២១៖ ប្រភពនានានៃការផ្ដល់មូលនិធិគាំទ្រ ផអ៣ទី៣ (គិតជាដុល្លារ)**

| ប្រភពមូលនិធិ | ២០១៨ | ២០១៩ | ២០២០ | សរុប | លទ្ធផល |
|---|---|---|---|---|---|
| ១. សកម្មភាពស្នូលនៃកំណែទម្រង់ | **72,638,529** | **75,133,130** | **82,267,780** | **230,039,439** | |
| ក. រាជរដ្ឋាភិបាល | **11,018,262** | **7,824,991** | **10,682,330** | **29,525,582** | |
| កិច្ចប្រតិបត្តិការរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | 370,000 | 370,000 | 370,000 | 1,110,000 | 1.2.1 |
| ថវិការបស់រាជធានី ខេត្តសម្រាប់ចំណាយប្រតិបត្តិការកម្មវិធី | 0 | 100,000 | 200,000 | 300,000 | 3.2.2 |
| ថវិការបស់ក្រុង ស្រុក ខណ្ឌសម្រាប់ចំណាយប្រតិបត្តិការកម្មវិធី | 0 | 60,000 | 120,000 | 180,000 | 3.2.3 |
| កិច្ចប្រតិបត្តិការរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | 500,000 | 1,000,000 | 2,000,000 | 3,500,000 | 3.2.3 |
| ថវិកាគាំទ្រគម្រោង LASED | 360,000 | 360,000 | 360,000 | 1,080,000 | 4.1.5 |
| ការរៀបចំលិខិតបទដ្ឋានស្ដីពីការផ្ទេរមុខងារ | 105,000 | 105,000 | 0 | 210,000 | 4.2.1 |
| ការរៀបចំផែនការសកម្មភាពស្ដីពីការអនុវត្តការផ្ទេរមុខងារ | 150,000 | 150,000 | 50,000 | 350,000 | 4.2.2 |
| ការអភិវឌ្ឍសមត្ថភាពក្រសួង ស្ថាប័នស្ដីពីការផ្ទេរមុខងារ | 0 | 500,000 | 1,000,000 | 1,500,000 | 4.2.3 |
| ការបង្កើតយន្តការច្រកចេញចូលតែមួយ | 7,100,000 | 1,500,000 | 1,500,000 | 10,100,000 | 4.2.4 |

| ប្រភពមូលនិធិ | ២០១៨ | ២០១៩ | ២០២០ | សរុប | លទ្ធផល |
|---|---|---|---|---|---|
| កិច្ចដំណើរការរបស់ OWSOs ដែលមានស្រាប់ | 500,000 | 1,000,000 | 1,500,000 | 3,000,000 | 4.2.4 |
| ការកែសម្រួលកំណែទម្រង់វិស័យដោយបញ្ចូលការងារ វ.វ | 19,500 | 39,000 | 39,000 | 97,500 | 4.3.1 |
| កិច្ចដំណើរការរបស់ SNIF | 1,913,762 | 2,640,991 | 3,543,330 | 8,098,082 | 5.1.4 |
| **ខ. ថវិកាកម្ចី** | **36,047,115** | **38,984,310** | **44,428,767** | **119,460,192** | |
| កិច្ចដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន ADB NASLA | 6,000,000 | 2,500,000 | 500,000 | 9,000,000 | 3.2.3 |
| ការប្រែប្រួលអាកាសធាតុ IFAD ASPIRE | 16,030,080 | 16,384,680 | 16,784,680 | 49,199,440 | 4.1.5 |
| ការបែងចែកដីសម្បទានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច (LASED) | 7,619,528 | 6,500,000 | 3,200,000 | 17,319,528 | 4.1.5 |
| ការកាត់បន្ថយភាពក្រីក្រតំបន់ជុំវិញបឹងទន្លេសាប ADB | 2,397,507 | 5,599,630 | 15,944,087 | 23,941,224 | 4.1.5 |
| មូលនិធិវិនិយោគរដ្ឋបាលមូលដ្ឋាន ADB SNIF | 4,000,000 | 8,000,000 | 8,000,000 | 20,000,000 | 5.1.4 |
| **គ. ថវិកាកញ្ចប់រួម** | **9,900,000** | **13,900,000** | **13,900,000** | **37,700,000** | |
| ទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិរបស់ប្រទេសស៊ុយអែដ | 3,000,000 | 3,000,000 | 3,000,000 | 9,000,000 | |
| ទីភ្នាក់ងារអភិវឌ្ឍន៍ និងសហប្រតិបត្តិការរបស់ប្រទេសស្វីស | 1,000,000 | 1,000,000 | 1,000,000 | 3,000,000 | |
| ថវិកាទ្រទ្រង់គាំទ្រដោយសហភាពអឺរ៉ុប | 5,900,000 | 9,900,000 | 9,900,000 | 25,700,000 | |
| **ឃ. មូលនិធិគម្រោង កម្មវិធីនានា** | **15,673,153** | **14,423,829** | **13,256,684** | **43,353,665** | |
| ថវិកាបំពេញបន្ថែមរបស់សហភាពអឺរ៉ុប (ការអភិវឌ្ឍសមត្ថភាព) | 500,000 | 500,000 | 500,000 | 1,500,000 | |
| កំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ) | 2,335,000 | 0 | 0 | 2,335,000 | 1.2.3 |
| គណនេយ្យភាពសង្គមផ្នែកតម្រូវការ (EU, World Bank) | 6,000,000 | 6,000,000 | 6,000,000 | 18,000,000 | 2.1.1 |
| គណនេយ្យភាពសង្គម សមាសភាគសិក្សារៀនសូត្រ(ADB) | 300,000 | 300,000 | 300,000 | 900,000 | 2.1.1 |
| ប្រជាពលរដ្ឋចូលរួមក្នុងការអភិវឌ្ឍ (PACT) | 700,000 | 700,000 | 700,000 | 2,100,000 | 2.1.1 |
| មូលនិធិប្រជាជនរបស់អង្គការសហប្រជាជាតិ (UNFPA) | 150,000 | 150,000 | 150,000 | 450,000 | 2.5.2 |
| សុវត្ថិភាពសង្គម DFAT ACCESS | 975,000 | 975,000 | 975,000 | 2,925,000 | 2.5.3 |
| ជំនួយរបស់ JICA សម្រាប់ការអភិវឌ្ឍសមត្ថភាព | 75,000 | 75,000 | 75,000 | 225,000 | 3.2.1 |
| សេវាសង្គមគាំទ្រដោយ UNICEF | 200,000 | 50,000 | 50,000 | 300,000 | 4.1.5 |
| ការប្រែប្រួលអាកាសធាតុ GCF | 1,000,000 | 3,000,000 | 3,000,000 | 7,000,000 | 4.1.5 |
| ការប្រែប្រួលអាកាសធាតុ Sida | 485,257 | 0 | 0 | 0 | 4.1.5 |
| ការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ (RED III) | 1,250,000 | 1,500,000 | 1,250,000 | 4,000,000 | 4.1.5 |
| ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (ADB/CDRR) | 481,913 | 0 | 0 | 481,913 | 4.1.5 |
| ជីវភាពធន់នឹងការប្រែប្រួលអាកាសធាតុ (UNDP SRL) | 1,220,983 | 1,173,829 | 256,684 | 2,651,495 | 4.1.5 |
| **២. ធនធានមូលនិធិផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** | **469,474,390** | **553,730,297** | **641,709,184** | **1,664,913,870** | |
| ធនធានមូលនិធិរាជរដ្ឋាភិបាល | 465,474,390 | 553,730,297 | 641,709,184 | 1,660,913,870 | |
| ធនធានមូលនិធិនៃសហភាពអឺរ៉ុបចំពោះមូលនិធិក្រុង ស្រុក | 4,000,000 | 0 | 0 | 4,000,000 | |
| **សរុបរួម** | **542,112,919** | **628,863,427** | **723,976,964** | **1,894,953,310** | |

ថវិកាចំណាយគាំទ្ររបស់រាជរដ្ឋាភិបាលរួមមាន (១) ថវិកាចំណាយប្រតិបត្តិការនានា (ក្រសួងមហាផ្ទៃ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ) (២) ថវិកាចំណាយរបស់ក្រសួង ស្ថាប័នសម្រាប់ការអនុវត្តកិច្ចដំណើរការ ផ្ទេរមុខងារ និង (៣) ថវិកាសម្រាប់កិច្ចដំណើរការរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ការបង្កើតយន្តការច្រក ចេញចូលតែមួយ និងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

ភាគច្រើននៃថវិកាចំណាយរបស់ផអ៣ទី៣ គឺជាថវិកាគាំទ្ររបស់រាជរដ្ឋាភិបាល ដែលក្នុងនោះមានចំនួន៦៥%នៃថវិកាសកម្មភាពស្នូលនៃកំណែទម្រង់ និងចំនួន៩៦%នៃថវិកាចំណាយសរុបរបស់កម្មវិធីទាំងមូល។

## ៣. ការផ្ទេរធនធានមូលនិធិ

ក្នុងអំឡុងពេលនៃផអ៣ទី៣ រាជរដ្ឋាភិបាលនឹងផ្ទេរធនធានមូលនិធិចំនួនប្រមាណជិត១.៧០០ លានដុល្លារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ថវិការាជធានី ខេត្តនឹងការមានការកើនឡើងក្នុងអត្រាជាមធ្យម១៧%ក្នុងមួយឆ្នាំ ថវិកាក្រុង ស្រុកមានការកើនឡើងក្នុងអត្រាជាមធ្យម១៥% និងថវិកាឃុំ សង្កាត់មានការកើនឡើងក្នុងអត្រាជាមធ្យម១៣%ក្នុងមួយឆ្នាំ។

**តារាងទី២២៖ ការផ្ទេរធនធានមូលនិធិរបស់រាជរដ្ឋាភិបាល (គិតជាដុល្លារ)**

| បរិយាយ | ប្រភពមូលនិធិ | ២០១៨ | ២០១៩ | ២០២០ | សរុប |
|---|---|---|---|---|---|
| ឃុំ សង្កាត់ | | | | | |
| • មូលនិធិឃុំ សង្កាត់ | រាជរដ្ឋាភិបាល | 107,170,650 | 123,246,247 | 141,733,184 | 372,150,081 |
| • ចំណូលពន្ធ | រាជរដ្ឋាភិបាល | 587,182 | 658,057 | 737,487 | 1,982,726 |
| • ចំណូលមិនមែនសារពើពន្ធ | រាជរដ្ឋាភិបាល | 2,413,210 | 2,775,191 | 3,330,230 | 8,518,631 |
| • មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ | រាជរដ្ឋាភិបាល | | | | |
| **សរុបរង** | | **110,171,042** | **126,679,495** | **145,800,901** | **382,651,438** |
| ក្រុង ស្រុក | | | | | |
| • មូលនិធិក្រុង ស្រុកគាំទ្រដោយសហភាពអឺរ៉ុប | | 4,000,000 | 0 | 0 | 4,000,000 |
| • រាជរដ្ឋាភិបាល ៖ | | 43,024,161 | 64,391,795 | 74,164,503 | 181,580,459 |
| – មូលនិធិក្រុង ស្រុក | រាជរដ្ឋាភិបាល | 38,275,232 | 58,982,133 | 67,829,453 | 165,086,818 |
| – ចំណូលពន្ធ | រាជរដ្ឋាភិបាល | 1,761,546 | 1,974,172 | 2,212,462 | 5,948,180 |
| – មិនមែនសារពើពន្ធ | រាជរដ្ឋាភិបាល | 2,987,383 | 3,435,490 | 4,122,588 | 10,545,461 |
| – មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ | រាជរដ្ឋាភិបាល | | | | |
| • មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ SNIF | រាជរដ្ឋាភិបាល | 5,413,762 | 9,640,991 | 10,543,330 | 25,598,082 |
| – រាជរដ្ឋាភិបាល | | 1,913,762 | 2,640,991 | 3,543,330 | 8,098,082 |
| – គម្រោង SNIF | ធនាគារ ADB | 3,500,000 | 7,000,000 | 7,000,000 | 17,500,000 |
| **សរុបរង** | | **52,437,923** | **74,032,786** | **84,707,833** | **211,178,541** |
| រាជធានី ខេត្ត | | | | | |
| • ថវិកាផ្ទេរពីថវិកាជាតិ | រាជរដ្ឋាភិបាល | 37,500,691 | 44,250,816 | 52,215,963 | 133,967,470 |
| • ចំណូលពន្ធ | រាជរដ្ឋាភិបាល | 264,654,388 | 306,325,303 | 354,654,210 | 925,633,901 |
| • ចំណូលមិនមែនសារពើពន្ធ | រាជរដ្ឋាភិបាល | 8,210,346 | 9,441,897 | 11,330,277 | 28,982,520 |
| • មូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ | រាជរដ្ឋាភិបាល | | | | |
| **សរុបរង** | | **310,365,425** | **360,018,016** | **418,200,450** | **1,088,583,891** |
| **សរុបរួម** | | **472,974,390** | **560,730,297** | **648,709,184** | **1,682,413,870** |
| • រាជរដ្ឋាភិបាល | រាជរដ្ឋាភិបាល | 465,474,390 | 553,730,297 | 641,709,184 | 1,660,913,870 |
| • មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | ធនាគារ ADB | 3,500,000 | 7,000,000 | 7,000,000 | 17,500,000 |
| • មូលនិធិគាំទ្រដោយសហភាពអឺរ៉ុប | សហភាពអឺរ៉ុប | 4,000,000 | 0 | 0 | 4,000,000 |